បណ្ណាល័យ
គ.ជ.អ.ប

# ការធ្វើអង្កេតបន្ត ស្តីអំពី អភិបាលកិច្ច
# CMB / 01 / R72/ RILG

ការអង្កេត អំពី ចំណេះដឹង ឥរិយាបថ ការអនុវត្តន៍ និង ជំនឿ លើបនដ្ឋាន
ស្តីពីអភិបាលកិច្ចល្អ ក្នុងប្រទេសកម្ពុជា
ដែលបានចាប់ផ្តើម
ពីថ្ងៃទី ២០ ខែ កញ្ញា ដល់ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤

របាយការណ៍រៀបចំដោយ

លោក ចន ហូឡូវ៉េ JOHN HOLLOWAY, លោក ជុំ សុខ CHOM SOK
និង បុគ្គលិកក្រុមចុះអង្កេតទាំងអស់ របស់អង្គការគ្រូសរ៉ូដស៍ ក្រុមផ្តល់យោបល់
Crossroads Consultancies Group និង បណ្ឌិត ហ្គាព្រៀល ពិកធិត
DR. GABRIEL PICTET ជាអ្នករៀបចំ Sample Framework

សំរាប់គណៈកម្មាធិការដឹកនាំការងារ នៃកម្មវិធីសិលាកម្ពុជា

352.74
HOL



library.ncdd.gov.kh
002432

[illegible]
[illegible]

# **បញ្ជីមាតិការឿង**

**ទំព័រ**


**ជំពូកទី១** .................................................. ៤

I. **សង្ខេប** .................................................. ៤

II. **សេចក្ដីផ្ដើម** .................................................. ១៤

- ជីវប្រវត្តិសង្ខេប .................................................. ១៤
- គោលបំណង នៃបេសសកកម្ម .................................................. ១៧

  (ក) តួនាទី និងភារកិច្ច .................................................. ១៧

- វិធីសាស្ត្រនៃបេសកកម្ម .................................................. ១៨

  (ក) ការជ្រើសរើសគំរូ ( តាមរបៀប Quantitative ) .................................................. ១៨

  (ខ) ការជ្រើសរើសគំរូ ( តាមរបៀប Qualitative ) .................................................. ១៩

  (គ) ចំណុចខ្លាំង និង ផលវិបាក .................................................. ២០

  (ឃ) ក្រុមចុះអង្កេត .................................................. ២២

  (ង) សកម្មភាពបេសកកម្ម .................................................. ២៣

  (ច) ការពិនិត្យឡើងវិញ នូវប្រភពបន្ទាប់បន្សំ .................................................. ២៤

- ការធ្វើការវកិច្ចតប .................................................. ២៤

III. **លទ្ធផលសំខាន់** ........................................................................ ២៥

(ក) ការពិនិត្យឡើងវិញ នូវនិយមន័យ នៃអភិបាលកិច្ចល្អ

សំរាប់មន្ត្រីរដ្ឋាភិបាលកម្ពុជា (ប្រការ ១) ........................................ ២៥

(ខ) និយមន័យនៃ បទដ្ឋានពាក់ព័ន្ធ សំរាប់ការអនុវត្តន៍អភិបាល

កិច្ចល្អនៅក្នុងប្រទេសកម្ពុជា (ប្រការ ២) ........................................ ២៦

(គ) ការធ្វើវិភាគ នូវការធ្វើអង្កេតបន្តឆ្នាំ ២០០៤ (ប្រការ ៣)...................... ៣១

(ឃ) ការធ្វើវិ ភាគ ប្រៀបធៀបរវាង ការធ្វើអង្កេតបន្តឆ្នាំ ២០០៤

និងការវាយតំលៃនៅឆ្នាំ ២០០១ ស្តីអំពីចំណេះដឹង ឥរិយាបថ ជំនឿ

និងការអនុវត្តន៍ ទៅលើអភិបាលកិច្ចល្អ (គោលបំណងទី៣)................... ៥១

(ង) ការប្រៀបធៀបលទ្ធផលនៅក្នុងខេត្តផ្សេងគ្នា ចំនួន ៧ ........................ ៨១

IV- **អនុសាសន៍** ........................................................................ ១០១

*. តារាងសំនួរសំរាប់ធ្វើការបំពេញ ........................................................ ១០៤

*. តារាងសំនួរសំរាប់សំភាសន៍ជាបុគ្គល .................................................. ១១៤

*. តារាងសំនួរសំរាប់សំភាសន៍ជាក្រុម .................................................. ១១៧

## ជំពូកទី១

## I- សង្ខេប

**ជីវៈប្រវត្តិ**

នៅឆ្នាំ ២០០១ ជាផ្នែកមួយនៃគំរោងអភិបាលកិច្ចមូលដ្ឋាន និងការវិនិយោគជនបទរបស់ធនាគារពិភពលោក តាមរយៈកម្មវិធីសិលា ការសិក្សាជាបន្តបន្ទាប់ត្រូវបានធ្វើឡើង និងផ្តល់ជាមូលនិធិដោយថវិកាបរិុងរបស់ PRHD ។ ការសិក្សាមួយ ក្នុងចំណោមការសិក្សាទាំងនេះ គឺជាការធ្វើអង្កេតស្តីអំពីចំណេះដឹង ឥរិយាបទ ការអនុវត្តន៍ និងជំនឿ (KAPB) ស្តីអំពីបទដ្ឋាន នៅក្នុងអភិបាលកិច្ចល្អ ។ ការធ្វើអង្កេតបន្តស្តីអំពីចំណេះដឹង ឥរិយាបទ ការអនុវត្តន៍ និងជំនឿ (KAPB) ស្តីអំពីបទដ្ឋាន នៅក្នុងអភិបាលកិច្ចល្អ នៅក្នុងប្រទេសកម្ពុជា តាមការអនុញ្ញាតពីគណៈកម្មាធិការដឹកនាំការងារកម្មវិធីសិលា និងត្រូវបានអនុវត្តចាប់ពីខែ កញ្ញា ដល់ខែ ធ្នូ ២០០៤ ។ ភារកិច្ចចំបង នៃការធ្វើអង្កេតនៅឆ្នាំ ២០០៤ នេះ គឺដើម្បីអនុវត្តនូវការធ្វើអង្កេតបន្ត ហើយប្រៀបធៀបលទ្ធផលដែលរកឃើញនៅឆ្នាំ ២០០១ ជាមួយនឹងលទ្ធផលដែលរកឃើញនៅឆ្នាំ ២០០៤ និងផ្តល់ជាអនុសាសន៍ផ្សេងៗ ។

**វិធីសាស្ត្រ**

ការធ្វើអង្កេតនៅឆ្នាំ ២០០៤ បានពិនិត្យទៅលើមន្ត្រីរដ្ឋាភិបាលកម្ពុជា សរុបចំនួន ១៩៩៨នាក់ ក្នុងនោះរួមទាំងមន្ត្រីក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលទើបនឹងជាប់ឆ្នោត និងមន្ត្រីតែងតាំងចាប់ពីថ្នាក់ឃុំ ថ្នាក់ស្រុក ថ្នាក់ខេត្ត ថ្នាក់ជាតិ (រួមទាំងស្មៀនឃុំ-សង្កាត់ផង) នៅក្នុងខេត្តតាកែវ បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង កំពង់ចាម កំពង់ស្ពឺ និង ទីក្រុងភ្នំពេញ នៅថ្នាក់ជាតិ និងសាលាក្រុងភ្នំពេញ។ ការធ្វើអង្កេតនេះ បានបំពេញនូវតំរូវការតាមតួនាទី និងភារកិច្ច ដោយបានជ្រើសរើសគំរូពីមន្ត្រីរាជការកម្ពុជា និងក្រុមប្រឹក្សាឃុំ-សង្កាត់ដែលទើបនឹងជាប់ឆ្នោត ដោយមានលំអៀងពីស្តង់ដារ ៨% និងទុកចិត្តបាន ៩៥% ។ ជាការពិតណាស់ ការធ្វើអង្កេត (Quantitative) នេះ ចំនួននៃអ្នកផ្តល់ពត៌មាន លើសពីតំរូវការ ចំនួន ៧០០នាក់ ហើយភាពលំអៀងពីស្តង់ដារ ក៏បានថយចុះច្រើនដែរ ។ មធ្យោបាយ នៃការធ្វើសំភាសន៍ គឺអោយមន្ត្រីរាជការ និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ បំពេញនូវបញ្ជីសំណួរ ដើម្បីស្ទាបស្ទង់នូវចំណេះដឹង ឥរិយាបទ ការអនុវត្តន៍ និងជំនឿរបស់ពួកគេ ស្តីអំពីអភិបាលកិច្ចនៅក្នុងប្រទេសកម្ពុជា ។

ថ្មីៗនេះការធ្វើអង្កេត បានព្យាយាមធ្វើអោយពត៌មានដែលលេចចេញពី ការបំពេញបញ្ជីសំណួរមានសុពលភាព គួបផ្សំជាមួយនឹងពត៌មាន នៃការធ្វើអង្កេត (Qualitative) ដែលប្រមូលបានពីសមាជិកសហគមន៍ចំនួន ៥៥២នាក់ ក្នុងនោះមានស្ត្រីចំនួន ២៥៧នាក់ ដែលរស់នៅក្នុងតំបន់ជាមួយនឹងមន្ត្រីដែលផ្តល់ពត៌មាន តាមរយៈការបំពេញបញ្ជី

សំណួរផងដែរ (Quantitative) ។ ទស្សនៈរបស់សហគមន៍ ត្រូវបានបញ្ចេញតាមរយៈ ការធ្វើប្រជុំក្រុមពិភាក្សា (PLA) និងការធ្វើសំភាសន៍ផ្ទាល់ (Simistructured) ទិន្នន័យទាំងនេះ គឺមានលក្ខណៈត្រីកោណ ដោយធ្វើការសំភាសន៍ជាមួយនឹងមន្ត្រីជាន់ខ្ពស់ ដែលត្រូវបានគេជឿជាក់ថា មានទស្សនៈច្បាស់លាស់ស្តីអំពីស្ថានភាពនៃអភិបាលកិច្ច ដូចជា : រដ្ឋលេខាធិការ អភិបាលក្រុង អភិបាលខេត្ត អភិបាលខេត្តរង និងសមាជិកគណៈកម្មាធិការដឹកនាំកម្មវិធី សិលា ។

លទ្ធផលនៃការបែងចែកជាត្រីកោណនេះ បានបង្កើតនូវមូលដ្ឋាន នៃការធ្វើអង្កេត (KAPB) បន្ត ស្តីអំពីអភិបាលកិច្ចនៅក្នុងប្រទេសកម្ពុជា និងធ្វើការប្រៀបធៀបការធ្វើអង្កេតនៅឆ្នាំ ២០០១ ដែលបានធ្វើតាមរបៀបដូច គ្នា ។ ការធ្វើអង្កេតក៏ត្រូវបានប្រៀបធៀបផងដែរជាមួយនឹងបទដ្ឋាន ដែលដកស្រង់ចេញពីគំរូអភិបាលកិច្ចអន្តរជាតិ ។ អនុសាសន៍ត្រូវបានធ្វើឡើងចេញពីការធ្វើអង្កេតនេះ និងចេញពីការប្រៀបធៀបជាមួយនឹងបទដ្ឋាន និងការធ្វើសង្កេតទូទៅ ។

**ប្រការ១ : និយមន័យ**

ក្នុងការបង្កើតនិយមន័យ នៃអភិបាលកិច្ច ក្រុមអង្កេត (ដូចនៅឆ្នាំ ២០០១) បានប្រើប្រាស់នូវនិយមន័យដែលកំណត់ដោយធនាគារពិភពលោក និង DFID ដែលកំណត់ថា អភិបាលកិច្ច គឺជាវិធីយាបថ ដែលអំណាចត្រូវបានគេប្រើប្រាស់ក្នុងការគ្រប់គ្រងធនធានសេដ្ឋកិច្ច និងសង្គមរបស់ប្រទេស សំរាប់ធ្វើការអភិវឌ្ឍន៍ ។ ក្នុងន័យទូទៅអភិបាលកិច្ចនិយាយអំពី បរិស្ថាននៃស្ថាប័ន ដែលប្រជាពលរដ្ឋមានទំនាក់ទំនងក្នុងចំណោមពួកគេដោយផ្ទាល់ និងមានទំនាក់ទំនងជាមួយភ្នាក់ងារ ឬមន្ត្រីរដ្ឋាភិបាល ។ និយមន័យនេះ គឺដូចគ្នាទៅនឹងនិយមន័យដែលបានប្រើប្រាស់នៅក្នុងឆ្នាំ ២០០១ និងត្រូវបានប្រើប្រាស់សំរាប់ហេតុផលតែមួយ ។ ការធ្វើអង្កេតបានបែងចែក ដាច់ដោយឡែកនូវខ្លឹមសារ នៃអភិបាលកិច្ចសំខាន់ៗ ៤ ដើម្បីធ្វើការសាកល្បង ដូចជា : គណនេយ្យភាព ការចូលរួម ការព្យាករណ៍ និងតម្លាភាព ។

**ប្រការ២ : បទដ្ឋាន**

ប្រការ ២ ការធ្វើអង្កេត ដើម្បីពង្រឹងនូវបទដ្ឋានអភិបាលកិច្ចល្អ សំរាប់មន្ត្រីរដ្ឋាភិបាលកម្ពុជា ទាំងមន្ត្រីតែងតាំង និងមន្ត្រីឃុំ-សង្កាត់ ដែលត្រូវបានជ្រើសរើសតាមការបោះឆ្នោត ។ អត្ថន័យជាក់ច្បាស់នៃបទដ្ឋាននៅក្នុងអត្ថបទ (ទំព័រ២៤) ជាពិសេសនៅត្រង់កន្លែងដែលលទ្ធផល នៃការអង្កេត KAPB នៅឆ្នាំ ២០០៤ ត្រូវបានធ្វើការ

ប្រៀបធៀបនៅក្នុងបទដ្ឋាននោះ ។ និយាយដោយសង្ខេប ទោះបីបទដ្ឋាននោះសំរាប់ (ក) បង្កើតយន្តការសំរាប់ការចូលរួមរបស់ប្រជាពលរដ្ឋ ដើម្បីរៀបចំអនាគតផ្ទាល់ខ្លួនរបស់ពួកគេ (ខ) ពង្រឹងសេដ្ឋកិច្ច (គ) បំបាត់ភាពក្រីក្រ (ឃ) ជំរុញការអភិវឌ្ឍន៍ (ង) ការពារសន្តិសុខ និង (ច) បំបាត់អំពើពុករលួយក៏ដោយ ។ ដោយមានការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ នៅឆ្នាំ ២០០២ ការបង្កើតនូវបរិយាកាស នៃអភិបាលកិច្ចល្អ អាចធ្វើទៅបាន និងការជំរុញអោយមានការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍន៍ ថ្មីៗនេះមន្ត្រីត្រូវបានគេមើលឃើញថា កំពុងចាប់ផ្តើមឈានឆ្ពោះទៅរកបទដ្ឋាន (ក) ប៉ុន្តែមិនអាចឈានទៅរកបទដ្ឋានផ្សេងៗទៀតទេ ។

## ប្រការ៣ : ការធ្វើអង្កេត KAPB ឆ្នាំ ២០០៤ និងការប្រៀបធៀបជាមួយ KAPB ឆ្នាំ ២០០១

ប្រការ៣ ធ្វើការអធិប្បាយ និងវិភាគអំពីការធ្វើអង្កេត KAPB ឆ្នាំ ២០០៤ (ទំព័រ ៣១) ។ ធ្វើការប្រៀបធៀប KAPB ឆ្នាំ ២០០៤ ជាមួយនឹង KAPB ឆ្នាំ ២០០១ ផងដែរ (ទំព័រ ៥១) ។

### ក-រាជការកម្ពុជា

ការអង្កេត បង្ហាញនូវចំណេះដឹង ឥរិយាបថ ការអនុវត្តន៍ និងជំនឿ របស់មន្ត្រីរាជការកម្ពុជា ដែលកំពុងបំរើការងារនៅឆ្នាំ ២០០៤ (ទំព័រ ៣១) និងក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលត្រូវបានជ្រើសរើសដោយការបោះឆ្នោតក្នុងឆ្នាំ ២០០២ (ទំព័រ១១៣ ក្នុងភាសាអង់គ្លេស) ។ ការធ្វើអង្កេតនេះ បានប្រៀបធៀបនូវទស្សនៈទាំងនេះ ជាមួយនឹងទស្សនៈដែលបានបញ្ចេញនូវការធ្វើអង្កេតនៅឆ្នាំ ២០០១ (ទំព័រ៥១) ។ ទស្សនៈទាំងនេះរួមមាន ភាពពិតនៃបរិយាកាសដែលការអភិវឌ្ឍន៍គាំទ្រដោយរដ្ឋាភិបាល ឬគាំទ្រដោយដៃគូរអភិវឌ្ឍន៍កំពុងតែកើតមានឡើង ។

### ខ-លក្ខណៈពិសេសមួយចំនួន របស់មន្ត្រីរាជការកម្ពុជា និងក្រុមប្រឹក្សាឃុំ-សង្កាត់

ការធ្វើអង្កេតទៅលើមន្ត្រីរាជការកម្ពុជាឆ្នាំ ២០០៤ បង្ហាញថា ១៩% មានអាយុក្រោម ៣៤ឆ្នាំ ហើយ ៨៤% មានអាយុ ៣៥ឆ្នាំ និងលើសពី ៣៥ឆ្នាំ ។ ពួកគេមិនមានកំរិតវប្បធម៌ខ្ពស់ទេ ដោយ ៣៨% មានកំរិតវប្បធម៌ត្រឹមបឋមសិក្សា ២៦%មានកំរិតវប្បធម៌ត្រឹមអនុវិទ្យាល័យ និង ២៧%មានកំរិតវប្បធម៌ត្រឹមវិទ្យាល័យ ។ ៥%ប៉ុណ្ណោះ បានសិក្សាដល់សកលវិទ្យាល័យ ។ ៣៧% បានធ្វើការបំរើរដ្ឋាភិបាលចំនួនពី ២ឆ្នាំ ដល់ ៥ឆ្នាំ ហើយពួកគេភាគច្រើនចាប់បំរើការងារតាំងពីបោះឆ្នោតឆ្នាំ ២០០២ មកម្លេះ ។ មន្ត្រីរាជការផ្សេងៗទៀតបានបំរើការងារចំនួនពី ៦ ទៅ ៣៧ឆ្នាំ ។ ពួកគេហាក់ដូចជាមិនមានទ្រព្យសម្បត្តិច្រើនទេ : ៨% មិនមានផ្ទះផ្ទាល់ខ្លួន ហើយ ៨៨% មានផ្ទះតែមួយគត់ ។ ១៥% គ្មានដីផ្ទាល់ខ្លួន ហើយមន្ត្រីផ្សេងទៀត មានដីផ្ទាល់ខ្លួនប្រហែលជា ១ហិចតា និង ៣% ផ្សេងទៀតមានដីផ្ទាល់ខ្លួនប្រហែល ៥ហិចតា ។ មន្ត្រីក្រុមប្រឹក្សាឃុំ-សង្កាត់ សរុបចំនួន ៥៥% ដែលត្រូវបានធ្វើអង្កេត (ទំព័រ

១១៣ ក្នុងភាសាអង់គ្លេស) ។ មន្ត្រី ៤% ប៉ុណ្ណោះ ដែលមានអាយុក្រោម ៣៤ឆ្នាំ ហើយមន្ត្រីផ្សេងៗទៀត មានអាយុលើសពី ៣៤ឆ្នាំ ។ មន្ត្រី ៧% មានអាយុលើសពី ៦៥ឆ្នាំ ។ ប្រហែល ៥៧% មានកំរិតវប្បធម៌ត្រឹមបឋមសិក្សា ២៨% មានកំរិតវប្បធម៌ត្រឹមអនុវិទ្យាល័យ ១២% មានកំរិតវប្បធម៌ត្រឹមវិទ្យាល័យ ។ មានតែ ០.៨% ដែលបានសិក្សាដល់សកលវិទ្យាល័យ ។ មន្ត្រី ២% មិនមានផ្ទះផ្ទាល់ខ្លួន ហើយមន្ត្រី ៩៥% បានអះអាងថា ពួកគេមានផ្ទះផ្ទាល់ខ្លួនតែមួយគត់ ។ មន្ត្រី ៧% មិនមានដីផ្ទាល់ខ្លួន ហើយមន្ត្រីផ្សេងៗទៀត មានដីផ្ទាល់ខ្លួនប្រហែលជា ១ហិចតា លើកលែងតែមន្ត្រី ២% ដែលមានដីជាង ៥ហិចតា ។ ទស្សនៈរបស់ពួកគេ ស្ទើរតែមិនមានលក្ខណៈខុសគ្នាពីទស្សនៈរបស់មន្ត្រីតែងតាំង ។ មន្ត្រី ៦៤% អះអាងថា ពួកគេមិនបានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់ ដើម្បីបំពេញការងាររបស់ពួកគេបានល្អទេ ។

### គ-មន្ត្រីជាន់ខ្ពស់ជាន់ក្រោយ

មានមន្ត្រី ៣៤% ផ្សេងទៀត ដែលមានអាយុក្រោម ៣៤ឆ្នាំ ។ មន្ត្រីទាំងនេះ រួមទាំងស្មៀនឃុំ-សង្កាត់ ដែលត្រូវបានតែងតាំងបន្ទាប់ពីបានប្រលងសមត្ថភាព ។ ពួកគេមានកំរិតវប្បធម៌គ្រាន់បើដែរ ប្រហែល ៤% សិក្សាដល់សកលវិទ្យាល័យ ហើយអ្នកផ្សេងៗទៀត បានទទួលនូវការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ។ មន្ត្រីទាំងនេះ បានទទួលនូវការបណ្តុះបណ្តាល និងមានទស្សនៈទាន់សម័យ ប៉ុន្តែពួកគេបន្តធ្វើការងារនៅក្នុងមជ្ឈដ្ឋានអភិរក្សទៅវិញ ។

### ឃ-ការយល់ដឹងស្តីពីអភិបាលកិច្ច និងគណនេយ្យភាព

មន្ត្រីជាង ៨៥% បានបណ្តុះបណ្តាលស្តីអំពីអភិបាលកិច្ចក្នុងរយៈពេល ២ឆ្នាំ កន្លងទៅ ដែលរៀបចំដោយភ្នាក់ងាររដ្ឋាភិបាល ។ អ្នកផ្តល់ពត៌មាន បានយល់ដឹងអំពីពាក្យថាអភិបាលកិច្ច និង វិមជ្ឈការ (ដែលពាណិជ្ជករបាននិយាយថា គាត់គ្រាន់តែបានលឺពាក្យថា អភិបាលកិច្ច ក្នុងរយៈពេល ២ឆ្នាំកន្លងទៅនេះទេ ) ប៉ុន្តែពួកគេបានយល់ដឹងអំពីខ្លឹមសារ នៃពាក្យទាំងនេះច្រើនជាងកាលពីឆ្នាំ ២០០១ ។ មន្ត្រីបានទទួលស្គាល់ថា ឧទាហរណ៍ គណនេយ្យ ភាពគឺជាផ្នែកមួយដ៏សំខាន់របស់អភិបាលកិច្ច ហើយមន្ត្រី ៧៨% បាននិយាយថា វាគឺការស្ទាបស្ទង់នូវសកម្មភាពរបស់រដ្ឋាភិបាលតាមរយៈប្រជាពលរដ្ឋ ហើយ ៦៧% បានគិតថា វាគឺជាកំរិតមួយដែលមន្ត្រីរាជការ ទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ប៉ុន្តែ ៦៦% បានគិតថា វាគឺជាការមកបំពេញភារកិច្ចដ៏ទៀងទាត់របស់មន្ត្រីរាជការ ។

### ង-ការយល់ដឹងអំពីការចូលរួម

នៅក្នុងន័យតែមួយនេះ អ្នកផ្តល់ពត៌មានបានយល់ឃើញថា ការចូលរួមគឺជាផ្នែកមួយដ៏សំខាន់របស់អភិបាលកិច្ចដែរ ដោយ ៨៣% បានគិតថា លក្ខណៈដ៏សំខាន់នៃការចូលរួមគឺថា មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល គួរធ្វើ

ការសំរេចទៅលើគោលនយោបាយ ដើម្បីជាផលប្រយោជន៍របស់ប្រជាពលរដ្ឋ ហើយ ៦៩% បានគិតថា រដ្ឋាភិបាល គួរតែប្រាប់អោយប្រជាពលរដ្ឋគ្រប់រូប បានដឹងនូវច្បាប់របស់ពួកគេដែលត្រូវគោរព ។ មន្ត្រី ៨១% ជឿជាក់ថា មធ្យោបាយចូលរួមការអភិវឌ្ឍន៍ មានន័យថា បង្កើនការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាល នៅក្នុងការដំណើរការអភិវឌ្ឍន៍ ។ ប៉ុន្តែទស្សនះរបស់ពួកគេ មានលក្ខណៈប្រសើរជាងឆ្នាំ ២០០១ ស្តីពីតួនាទីរបស់ចាស់ជរា និងស្ត្រីក្នុងការអភិវឌ្ឍន៍ ។ មន្ត្រី ៧៦% បានគាំទ្រការចូលរួមរបស់ចាស់ជរា នៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ ហើយមន្ត្រី ៨០% បានគាំទ្រការ ចូលរួមរបស់ស្ត្រី ។ មានតំរូវការសំរាប់ការបណ្តុះបណ្តាលនៅក្នុងការចូលរួម ។

## ច-ការយល់ដឹងអំពីការព្យាករណ៍ទុកជាមុន

នៅពេលដែលអ្នកផ្តល់ពត៌មាន មិនបានចាត់ទុកការព្យាករណ៍ទុកជាមុន ជាផ្នែកទាំងមូលនៃអភិបាលកិច្ច ពួកគេបានយល់ច្បាស់នូវតួនាទី នៃការព្យាករណ៍ទុកជាមុនជាវិធាននៃច្បាប់ ។ ពួកគេបានយល់នូវសារៈសំខាន់នៃការផ្សព្វផ្សាយច្បាប់ និង បទបញ្ញត្តិផ្សេងៗ និងសារៈសំខាន់នៃការអនុវត្តច្បាប់ និង បទបញ្ញត្តិផ្សេងៗ អោយបានខ្ជាប់ខ្ជួន។

## ឆ-ការយល់ដឹងអំពីតម្លាភាព

អ្នកផ្តល់ពត៌មានទាំងអស់បានយល់ច្បាស់អំពីអត្ថន័យនៃពាក្យ តម្លាភាព ទោះបីជាតាមរយៈការធ្វើអង្កេត (Qualitative) ដែលក្រុមប្រឹក្សាឃុំជាច្រើនបានអនុវត្ត។ គួរអោយចាប់អារម្មណ៍នោះគឺថា ចំពោះបញ្ហានេះ មន្ត្រីប្រហែលពីភាគបីបានគិតថា មានពេលច្រើនដែលការសំរេចគួរតែធ្វើឡើងដោយរដ្ឋាភិបាល ជាជាងការធ្វើឡើងដោយសាធារណៈជន ហើយ ៦៥% បានមានជំនឿថា ការអនុវត្តច្បាប់ធ្វើអោយយឺតដល់ដំណើរការអភិវឌ្ឍន៍។ នៅត្រង់ចំនុចនេះ មន្ត្រីមានការប្រុងប្រយ័ត្នយ៉ាងខ្លាំង។ ពួកគេបានគាំទ្រយ៉ាងពេញទំហឹងចំពោះស្ថានភាពដដែល ។

## ជ-ឥរិយាបថស្តីពីការបង់ថវិកាក្រោមតុ

អ្នកផ្តល់ពត៌មានប្រហែល៥៨% មានជំនឿថា ការបង់ថវិកាក្រោមតុជាមធ្យោបាយសាមញ្ញដើម្បីអោយគេធ្វើអ្វីមួយនៅក្នុងប្រទេសកម្ពុជា ហើយប្រហែល៥៣% ជឿជាក់ថា វាជាការមួយដែលអាចទទួលយកបាន ដែលមន្ត្រីរដ្ឋាភិបាលមានប្រាក់ខែតិច ទទួលនូវកំរៃជើងសារ។ ចំពោះសំណួរសួរថាតើអ្នកម៉ៅការត្រូវតែសូកលុយដើម្បីទទួលបានកុងត្រាមកធ្វើ ? មន្ត្រីប្រហែល ៥០% មានជំនឿថា ពួកគេច្បាស់ជាធ្វើដូច្នោះមែន ។ ចំនួន៨១% មិនឯកភាពចំពោះ បក្សពួកនិយម ។

***ឈ-គណនេយ្យភាព សេដ្ឋកិច្ច និង សន្តិសុខ***

មន្ត្រីចំនួន ៩១% ជឿជាក់ថា មានគណនេយ្យភាពច្រើនជាងមុនតាំងតែពីមានការបោះឆ្នោតឃុំ-សង្កាត់នៅឆ្នាំ២០០២ ។ ទាក់ទងទៅនឹងបញ្ហាសេដ្ឋកិច្ចវិញ អ្នកផ្តល់ពត៌មានចំនួន ៦៦% បានគិតថា រដ្ឋាភិបាល កំពុងធ្វើការងារគ្រប់គ្រាន់ដើម្បីបង្កើតអោយមានខឿនសេដ្ឋកិច្ចរឹងមាំ។ ចំនួន៥៦% បានគិតថា មន្ត្រីរាជការកំពុងធ្វើការងារគ្រប់គ្រាន់ដើម្បីជួយសំរួលដល់អាជីវកម្មខ្នាតតូច។ ចំពោះសន្តិសុខវិញ មន្ត្រីចំនួន៨៥%បាននិយាយថា ប្រជាពលរដ្ឋត្រូវបានអនុញ្ញាតិអោយបញ្ចេញមតិយោបល់ជាសាធារណៈ ហើយ ១៥% បាននិយាយថា ពួកគេមិនត្រូវបានអនុញ្ញាតិអោយបញ្ចេញមតិយោបល់ជាសាធារណៈទេ ។ ៨៨%ដែលគួរអោយចាប់អារម្មណ៍នោះបាននិយាយថា រដ្ឋាភិបាលគួរតែធ្វើកិច្ចការអោយបានច្រើនជាងនេះទៀត ដើម្បីធ្វើអោយប្រជាពលរដ្ឋទាំងអស់មានសុវត្ថិភាព ។

***ខលក្ខណៈ (Qualitative) ត្រូវបានគេមើលឃើញថា ផ្ទុយគ្នាទៅនឹង (Quantitative)***

អ្នកចូលរួមក្នុងក្រុមពិភាក្សាភាគច្រើនមានអាយុពី ២០-៦៥ឆ្នាំ មានគំលាតធំ ។ ពួកគេភាគច្រើនមានកំរិតវប្បធម៌ត្រឹមបឋមសិក្សា។ ពួកគេច្រើនតែជាកសិករ អ្នកនេសាទ និង ស្ត្រីមេផ្ទះ។ អ្នកផ្តល់សំភាសន៍ផ្ទាល់ (Simistructured) ច្រើនតែមានកំរិតវប្បធម៌ខ្ពស់ ពួកគេស្ទើរតែទាំងអស់បានបញ្ចប់ថ្នាក់អនុវិទ្យាល័យ និង វិទ្យាល័យ ។ អ្នកផ្តល់សំភាសន៍ផ្ទាល់ទាំងនេះ (Simistructured) ភាគច្រើនធ្វើការនៅអង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និងផ្នែកឯកជន ហើយអ្នកម៉ៅការក៏មានច្រើនដែរ ។

បញ្ហាអភិបាលកិច្ចល្អ ជាទូទៅត្រូវបានបកស្រាយយ៉ាងល្អ ដោយអ្នកផ្តល់ពត៌មានភាគច្រើននៅក្នុងសហគមន៍ សង្គមស៊ីវិល និងផ្នែកឯកជន ។ អភិបាលកិច្ចល្អ ត្រូវបានគេមើលឃើញថា ជះឥទ្ធិពលដល់ការរស់នៅល្អរបស់ពួកគេ ទោះបីតិចក្តី ច្រើនក្តី ។ ចំណែកឯអ្នកផ្តល់ពត៌មានជាសង្គមស៊ីវិលវិញ មានគំនិតច្រើនហើយធ្វើការឆ្លើយតបនូវសំណួរជាច្រើនផងដែរ ។ ចំណែកឯក្រុមពិភាក្សានៅតាមសហគមន៍បានយល់ឃើញថា អភិបាលកិច្ចច្រើនតែទាក់ទងទៅនឹងការអភិវឌ្ឍន៍ភាពក្រីក្រ និងសន្តិសុខ ។ អ្នកផ្តល់ពត៌មានភាគច្រើន បានកំណត់នូវអភិបាលកិច្ចដែលទាក់ទងទៅនឹងថ្នាក់ដឹកនាំ ហើយមន្ត្រីរដ្ឋាភិបាលបានកំណត់ថា អភិបាលកិច្ច គឺជាប្រព័ន្ធមួយ ។ ការព្រួយបារម្ភខ្លាំងបំផុតរបស់ពួកគេ គឺការចូលរួមនឹងគណនេយ្យភាព ពួកគេងាយនឹងយកគំរាប់តាមនូវគំរូ នៃអភិបាលកិច្ចមិនល្អ ។ ចំពោះបញ្ហាការព្យាករណ៍ទុកជាមុនវិញ អ្នកផ្តល់ពត៌មានភាគច្រើន បានយល់ដឹងអំពីច្បាប់ និងបទបញ្ញត្តិផ្សេងៗ ប៉ុន្តែពួកគេក៏បានសារភាពថា ចំណេះដឹងរបស់ពួកគេនៅមានកំណត់ និងមិនទាន់ច្បាស់នៅឡើយ ។ អ្នកចូលរួមក្រុមពិភាក្សាកាន់តែមានការយល់ដឹងតិច ចំពោះច្បាប់ និងបទបញ្ញត្តិផ្សេងៗ ពីព្រោះពួកគេមានកំរិតវប្បធម៌ទាប និងខ្វះ

ខាតនូវមធ្យោបាយទំនាក់ទំនង ។ ការឯកភាពជាទូទៅនោះគឺថា ច្បាប់នឹងបទបញ្ញត្តិផ្សេងៗ មិនត្រូវគេបានអនុវត្តន៍ខ្ជាប់ខ្ជួន និងត្រឹមត្រូវឡើយ ។ ពួកគេមិនសប្បាយចិត្តចំពោះវប្បធម៌រួចទោស ដែលអនុវត្តន៍ដោយកងកំលាំងសន្តិសុខ និងអំពើពុករលួយរបស់តុលាការ ពួកគេក៏បានកោតសរសើរចំពោះយន្តការដោះស្រាយជំលោះ របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ផងដែរ ។ អ្នកផ្តល់ពត៌មានទាំងអស់ យល់ឃើញថា ការចូលរួមជាផ្នែកសំខាន់មួយនៅក្នុងដំណើរការអភិវឌ្ឍន៍ ។ មានទស្សនៈជាទូទៅមួយថា តាំងពីមានការបោះឆ្នោតឆ្នាំ ២០០២ ក្រុមប្រឹក្សាឃុំ-សង្កាត់ជាច្រើន កំពុងប្រឹងប្រែងរៀបចំនូវកិច្ចប្រជុំជាសាធារណៈ ដើម្បីអោយប្រជាពលរដ្ឋបញ្ចេញនូវយោបល់ ។ គំរោងភាគច្រើនទាក់ទៅនឹងកិច្ចប្រជុំមុនធ្វើគំរោង និងក្រោយធ្វើគំរោង ។ ចំពោះបញ្ហាតម្លាភាពវិញនោះ អ្នកផ្តល់ពត៌មានបាននិយាយថា ក្រុមប្រឹក្សាឃុំ-សង្កាត់ជាច្រើនកំពុងប្រឹងប្រែងប្រកបដោយតម្លាភាពដោយបិទប្រកាសការចំណាយ របស់ក្រុមប្រឹក្សាឃុំ-សង្កាត់នៅលើក្តារប្រកាស។ នៅក្នុងទីក្រុងភ្នំពេញមានការបារម្ភមួយថា ក្រុមប្រឹក្សាសង្កាត់មិនបានយកចិត្តទុកដាក់លើពត៌មានត្រលប់ របស់ប្រជាពលរដ្ឋដែលបានបោះឆ្នោតអោយនោះទេ ។ ចំណែកឯបញ្ហាគណនេយ្យភាពវិញ នៅពេលដែលមានការរិះគន់ចំពោះប្រព័ន្ធដេញថ្លៃកិច្ចសន្យាទាំងនៅថ្នាក់ឃុំនិងថ្នាក់ខេត្ត នៅពេលនោះក្រុមប្រឹក្សាឃុំ-សង្កាត់ ហាក់ដូច ជាទទួលខុសត្រូវចំពោះមូលនិធិដែលខ្វះខាត ។ ទោះបីយ៉ាងណាក៏ដោយ ក៏មន្ត្រីត្រូវគេមើលឃើញថាបានប្រព្រឹត្តអំពើពុករលួយ ហើយការបង់ថវិកាក្រោមតុ គឺជាទំលាប់ ។

***ការបែងចែក Gender***

ការធ្វើអង្កេតក៏បានធ្វើការបែងចែកនូវទស្សនៈរបស់ស្ត្រី និងបុរស ដែលជាមន្ត្រីរបស់រដ្ឋាភិបាល (ទំព័រ៨៥ ក្នុងភាសាអង់គ្លេស) ។ ស្ត្រីនៅក្នុងការធ្វើអង្កេតមានសរុប ១៦% ពួកគេមានកំរិតវប្បធម៌ ប្រហាក់ប្រហែលគ្នា ប៉ុន្តែពួកគេក៏មានវ័យក្មេងណាស់ដែរ ហើយក៏មិនបានបំរើការងារនៅក្នុងជួររដ្ឋាភិបាលបានយូរណាស់ណាដែរ ។ ទាក់ទងទៅនឹង ចំណេះដឹង ការអនុវត្តន៍ និងជំនឿ លទ្ធផលនៃការអង្កេតទាំងបុរស និងទាំងស្ត្រី គឺស្ទើរតែដូច គ្នា ។ លក្ខណៈខុសគ្នានោះ គឺឋិតនៅក្នុងចំណុចភាគរយតូចបំផុតអំពីបញ្ហាភាគច្រើន ប៉ុន្តែលក្ខណៈខុសគ្នាទាំងនោះគឺតិចបំផុត ។

***លក្ខណៈខុសគ្នានៃខេត្តដែលបានធ្វើអង្កេត***

តារាងដែលបានប្រៀបធៀបខេត្តគោលដៅ ដែលបានបំបែកដាក់ដោយឡែកៗ (ទំព័រ ៦៤ ក្នុងភាសាអង់គ្លេស) មិនបានបង្ហាញនូវលក្ខណៈខុសគ្នា រវាងមន្ត្រីជាប់ឆ្នោត និងមន្ត្រីតែងតាំងទាំង៧ខេត្ត ដែលបានធ្វើអង្កេត

នោះឡើយ ។ លក្ខណៈខុសប្លែកគ្នាបន្តិចនោះគឺថា មន្ត្រីនៅទីក្រុងភ្នំពេញមានវ័យក្មេងជាង មានកំរិតវប្បធម៌ខ្ពស់ជាង ហើយមានជីវភាពអន់ខ្សោយ ជាងមន្ត្រីនៅតាមខេត្តទាំង៦នោះបន្តិច ។ ពួកគេបានទទួលនូវចំនួន នៃការបណ្តុះបណ្តាលស្តីអំពីអភិបាលកិច្ចប្រហែលគ្នា ។ ចំណេះដឹង អំពីអភិបាលកិច្ចរបស់មន្ត្រីភ្នំពេញខ្ពស់ជាងបន្តិច ឥរិយាបទដូចគ្នា ប៉ុន្តែខ្លាំងជាងបន្តិចសំរាប់ការអនុវត្តវិញ មន្ត្រីនៅទីក្រុងភ្នំពេញមួយចំនួនតូច បានគិតថាច្បាប់ត្រូវបានគោរពយ៉ាងខ្ជាប់ខ្ជួន ហើយពួកគេបានទទួលព័តមានគ្រប់គ្រាន់ស្តីអំពីការចំណាយរបស់រដ្ឋាភិបាល។ មន្ត្រីនៅទីក្រុងភ្នំពេញចង់អោយស្ត្រី និង មនុស្សវ័យចាស់ចូលរួមក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ច្រើនជាង ហើយពួកគេមិនសូវជឿជាក់ថាមន្ត្រីរដ្ឋាភិបាលកំពុងធ្វើកិច្ចការគ្រប់គ្រាន់ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច និង អាជីវកម្មខ្នាតតូច។

***<u>ការប្រៀបធៀបការអង្កេតនៅឆ្នាំ ២០០៤ ជាមួយនឹងការអង្កេតជាលើកដំបូងនៅឆ្នាំ ២០០១</u>***

មានមន្ត្រីរាជការភាគច្រើន ដែលមានអាយុក្រោម ៣៤ឆ្នាំ នៅក្នុងឆ្នាំ ២០០៤ នេះ ហើយក៏មានកំរិតវប្បធម៌ខ្ពស់ជាងមុនបន្តិចដែរ ។ ជាការពិតណាស់ ចំនួននៃមន្ត្រីរាជការ ដែលបំរើការងារនៅក្នុងថ្នាក់ឃុំមានការកើនឡើង ពួកគេក្រជាងមុនបន្តិច ពួកគេបានទទួលនូវការបណ្តុះបណ្តាល ស្តីពីអភិបាលកិច្ចបានច្រើនជាងមុន (៨៥%) ប្រៀបធៀបទៅនឹង ៦១% ប៉ុន្តែមិនសូវមានទំនុកចិត្តថា ពួកគេបានទទួលនូវការបណ្តុះបណ្តាលគ្រប់គ្រាន់ដើម្បីធ្វើការងាររបស់ពួកគេបានល្អឡើយ ។ ចំណេះដឹងរបស់ពួកគេបានកើនឡើង ៤-៦% ឬលើសពីនេះ ។ មន្ត្រីភាគច្រើនមិនមានជំនឿតទៅទៀតថា គណនេយ្យភាពនៅក្នុងអភិបាលកិច្ច មានន័យថា ការមកធ្វើការងារទៀងទាត់របស់មន្ត្រីរដ្ឋាភិបាល ។ ពួកគេនៅតែមានជំនឿថា ទោះបីជាមិនសូវជាខ្លាំងក្លាក៏ដោយ ក៏ការចូលរួមនៅក្នុងអភិបាលកិច្ចមានន័យថា មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល គួរតែធ្វើការសំរេចនូវគោលនយោបាយ ដើម្បីជាប្រយោជន៍របស់ប្រជាពលរដ្ឋ ។នៅឆ្នាំ ២០០៤ មន្ត្រីតិចជាង ១០% ជាស្ត្រីដែលរៀបការហើយ ដែលមានសំលេងនៅក្នុងជួររដ្ឋាភិបាល ប៉ុន្តែមានសំលេងខ្លាំងក្លាទៅក្នុងប្រព័ន្ធវិមជ្ឈការជាងនៅក្នុងឆ្នាំ ២០០១ ។ នៅក្នុងឆ្នាំ ២០០៤ មន្ត្រីមានជំនឿតិចតួច (ត្រឹម ១០%) ថា ការបង់ថវិកាក្រោមតុ គឺជាទំលាប់ ឬអាចទទួលយកបាន ។ នៅឆ្នាំ ២០០៤ មន្ត្រីភាគច្រើនបានមានជំនឿថា គួរតែមានចំនួនស្ត្រីឋិតនៅក្នុងតំណែងធ្វើគោលនយោបាយនៅក្នុងប្រទេសកម្ពុជា ច្រើនជាងនៅឆ្នាំ ២០០១ ។ ពួកគេក៏ឯកភាពផងដែរចំពោះគោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ប៉ុន្តែក៏នៅមានជំនឿយ៉ាងមុតមាំ (៨៨% នៅ ឆ្នាំ ២០០៤ ប្រៀបធៀបទៅនឹង ៣៣% នៅឆ្នាំ ២០០១) ថា រដ្ឋាភិបាលអាចធ្វើកិច្ចការបន្ថែមទៀត ដើម្បីធ្វើអោយប្រជាពលរដ្ឋទាំងអស់មានសុវត្ថិភាព និងសន្តិសុខ ។

## ការធ្វើអង្កេតដំបូងទៅលើក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលបានជាប់ឆ្នោត ប្រៀបធៀបការធ្វើអង្កេតជាមួយនិងមន្ត្រីតែងតាំង

មន្ត្រីជាប់ឆ្នោតមានវ័យចំណាស់ជាងមន្ត្រីតែងតាំងបន្តិច ។ ៣% មានអាយុក្រោម ៣៤ឆ្នាំ (បើប្រៀបធៀបជាមួយនឹងមន្ត្រីតែងតាំង ៣៤%) ៩០% មានអាយុចន្លោះ ៣៤-៦៤ឆ្នាំ (បើប្រៀបធៀបទៅនឹងមន្ត្រីតែង ៦៣%) ហើយ ៧% មានអាយុជាង ៦៥ឆ្នាំ (បើប្រៀបធៀបទៅនឹងមន្ត្រីតែងតាំង ២%) ។ ជាទូទៅមន្ត្រីតែងតាំងមានកំរិតវប្បធម៌ខ្ពស់ជាងមន្ត្រី ដែលជ្រើសរើសដោយការបោះឆ្នោត ។ ចំពោះមន្ត្រីដែលជ្រើសរើសដោយការបោះឆ្នោតចំនួន ៥៧% មានកំរិតវប្បធម៌ត្រឹមបឋមសិក្សា (បើប្រៀបធៀបទៅនឹងមន្ត្រីតែងតាំង ១០%) ២៨% មានកំរិតវប្បធម៌ត្រឹមអនុវិទ្យាល័យ (បើប្រៀបធៀបទៅនឹងមន្ត្រីតែងតាំង ២៤%) ១២% មានកំរិតវប្បធម៌ត្រឹមវិទ្យាល័យ (បើប្រៀបធៀបទៅនឹងមន្ត្រីតែងតាំង ៤៩%) ហើយមន្ត្រីជាប់ឆ្នោត ៩នាក់មានកំរិតវប្បធម៌ត្រឹមសកលវិទ្យាល័យ (បើប្រៀបធៀបទៅនឹងមន្ត្រីតែងតាំង ៨៧នាក់) ។ ចំពោះមន្ត្រីដែលបានជ្រើសរើសដោយការបោះឆ្នោត ៣៩% បាននិយាយថា ពួកគេទើបតែបំរើការងារនៅក្នុងជួររដ្ឋាភិបាលរយៈពេលពី ២-៥ឆ្នាំ ប៉ុណ្ណោះ (តាមការប៉ាន់ស្មានភាគច្រើនស្មៀនឃុំ-សង្កាត់) ហើយចំណែកឯអ្នកមន្ត្រី ៥៨% បំរើការងារនៅក្នុងជួររដ្ឋាភិបាលចាប់ពី ៦-៤៥ឆ្នាំ ។ មន្ត្រីដែលជ្រើសរើសដោយការបោះឆ្នោត ហាក់ដូចជាមានទ្រព្យសម្បត្តិច្រើនជាងមន្ត្រីតែងតាំងបន្តិច ។ ក្នុងចំណោមមន្ត្រីដែលជ្រើសរើសដោយការបោះឆ្នោតទាំងអស់ មានតែ ២%ប៉ុណ្ណោះដែលគ្មានផ្ទះផ្ទាល់ខ្លួន ហើយ ៩៥% មានផ្ទះផ្ទាល់ខ្លួនតែមួយគត់ (បើប្រៀបធៀបទៅនឹងមន្ត្រីតែងតាំង ១៧% មិនមានផ្ទះផ្ទាល់ខ្លួន ហើយ ៧៩% មានផ្ទះផ្ទាល់ខ្លួនតែមួយគត់) ក្នុងចំណោមមន្ត្រីជាប់ឆ្នោតទាំងអស់ ៧%មិនមានដីផ្ទាល់ខ្លួន ហើយភាគច្រើនមានដីប្រហែលជា ១ហិចតា។ មានតែ ៤% ប៉ុណ្ណោះ ដែលមានដីប្រហែលជា ៥ហិចតា ។ ក្នុងចំណោមមន្ត្រីតែងតាំងទាំងអស់ ២៦% មិនមានដីផ្ទាល់ខ្លួន (ភាគច្រើនជាស្មៀនឃុំ) ពួកគេភាគច្រើនមានដីប្រហែលជា ១ហិចតា ហើយ ២% ប៉ុណ្ណោះ ដែលមានដីច្រើនជាង ៥ហិចតា ។

ទាក់ទងទៅនឹងការបណ្តុះបណ្តាលស្តីអំពីអភិបាលកិច្ច ទាំងមន្ត្រីជាប់ឆ្នោត និងមន្ត្រីតែងតាំង បានធ្វើការអះអាងប្រហាក់ប្រហែលគ្នា តែទោះបីជាយ៉ាងណាក៏ដោយ ក៏ប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់ បានទទួលនូវការបណ្តុះបណ្តាលច្រើនជាងគេបន្តិចដែរ ។ មន្ត្រីជាប់ឆ្នោតចំនួន ៨៨% បានចូលរួមវគ្គបណ្តុះបណ្តាលស្តីអំពីអភិបាលកិច្ច ភាគច្រើនបានទទួលនូវការបណ្តុះបណ្តាលនេះ រយៈពេល ២ឆ្នាំ កន្លងទៅហើយ ហើយបានរៀបចំដោយភ្នាក់ងារអភិបាលកិច្ច ហើយសំរាប់មន្ត្រីតែងតាំងវិញ ៨០% បានទទួលនូវការបណ្តុះបណ្តាលស្តីពីអភិបាលកិច្ច ។ មន្ត្រីជាប់ឆ្នោតចំនួន ៥០% មានជំនឿថាពួកគេបានទទួលនូវការបណ្តុះបណ្តាលគ្រប់គ្រាន់ ដើម្បីធ្វើការងាររបស់ពួកគេ ហើយមន្ត្រី

តែងតាំង ៣២% មានជំនឿថា ពួកគេបានទទួលនូវការបណ្តុះបណ្តាលគ្រប់គ្រាន់ដែរ ។ ចំណេះដឹងស្តីអំពីអភិបាលកិច្ច របស់មន្ត្រីជាប់ឆ្នោត និងមន្ត្រីតែងតាំងវាស្ទើតែដូចគ្នា ។ ពួកគេមានការយល់ច្រលំអំពីពាក្យថា ការចូលរួមនៅក្នុង អភិបាលកិច្ច ទោះបីជាការពិតដែលថា ការងាររបស់ពួកគេត្រូវមានការចូលរួមច្រើនជាងមុនក៏ដោយ ។ ចំពោះការ អនុវត្តទិញ មានទស្សនៈខុសគ្នាបន្តិចរវាងមន្ត្រីតែងតាំង និងមន្ត្រីជាប់ឆ្នោត ប៉ុន្តែមន្ត្រីជាប់ឆ្នោតមានទស្សនៈច្បាស់ លាស់ ស្តីអំពីការបង់ថវិកាក្រៅផ្លូវការ ឬបង់ថវិកាក្រោមតុ ជាងមន្ត្រីតែងតាំងបន្តិច ។ នៅក្នុងឥរិយាបថ និងជំនឿ ទស្សនៈមន្ត្រីជាប់ឆ្នោត និងមន្ត្រីតែងតាំង គឺស្ទើតែដូចគ្នា ។ វាមិនមែនជាការគួរអោយភ្ញាក់ផ្អើលនោះទេ ពីព្រោះពួក គេភាគច្រើន មានបទពិសោធន៍ និងប្រវត្តិដូចគ្នា ។

## ***ការធ្វើការអង្កេតលើកដំបូង ទៅលើស្មៀនឃុំ-សង្កាត់***

ស្មៀនឃុំ-សង្កាត់ ភាគច្រើនមានវ័យក្មេងជាងប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់ ឬមន្ត្រីតែងតាំង ឆ្ងាយ ណាស់ ហើយពួកគេក៏បំរើនៅក្នុងជួររដ្ឋាភិបាលរយៈពេលខ្លីជាងប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់ដែរ ។ ពួកគេទំនងជា មានជីវភាពក្រីក្រជាងសហការីរបស់ពួកគេ ប៉ុន្តែបានទទួលនូវចំនួននៃការបណ្តុះបណ្តាលស្តីអំពីអភិបាលកិច្ចដូចគ្នា ។ ទស្សនៈរបស់ពួកគេស្ទើតែដូចគ្នា ទៅនឹងទស្សនៈរបស់សហការីដែលបានជ្រើសរើសដោយការបោះឆ្នោត និងសហការី តែងតាំង ប៉ុន្តែហាក់ដូចជាមានទំងន់ជាងទស្សនៈរបស់សហការីជាប់ឆ្នោត និងតែងតាំង ។

## ***អនុសាសន៍***

ការធ្វើអង្កេតផ្តល់នូវអនុសាសន៍មួយចំនួន ប៉ុន្តែព្យាយាមមិនអោយមានការផ្តល់នូវអនុសាសន៍ជា ច្រើនដដែលៗ ស្តីអំពីការកែទំរង់មន្ត្រីរាជការកម្ពុជា ។ អនុសាសន៍ នៃការធ្វើអង្កេតទាក់ទងទៅនឹងការបណ្តុះបណ្តាល បន្ថែមដល់មន្ត្រីរាជការ ជាពិសេសស្តីអំពីអភិបាលកិច្ច ពង្រឹងតម្លាភាព នៃប្រព័ន្ធដេញថ្លៃម៉ៅការ ធ្វើសនិទានកម្មនូវ ការចំណាយមូលនិធិឃុំដល់ធនាគារឯកជននៅទីរួមស្រុកជាជាងប្រើប្រាស់ប្រព័ន្ធរតនាគារនៅទីរួមខេត្ត ពង្រឹងយន្តការ ដោះស្រាយទំនាស់នៅថ្នាក់ឃុំ-សង្កាត់ ពង្រឹងនូវការអនុវត្តន៍នៃការចូលរួមរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ផ្តល់អណត្តិ ដល់មន្ត្រីដើម្បីជួយអាជីវកម្មខ្នាតតូចរបស់ប្រជាពលរដ្ឋ និងពង្រឹងសេដ្ឋកិច្ច បង្កើតសេវាដែលកំណត់តំលៃជាក់លាក់ជា ផ្លូវការ ដោយមានការអនុគ្រោះដល់អ្នកក្របំផុត ហើយពង្រឹងការងាររបស់ប៉ូលីសឃុំ-សង្កាត់ ។

## II. សេចក្តីផ្តើម

- **ជីវប្រវត្តិ**

រយៈពេលជិត ៤០ឆ្នាំ កន្លងទៅនេះ ប្រទេសកម្ពុជាគ្រប់គ្រងដោយរបប ៦ ផ្សេងៗគ្នា ដែលឋិតនៅក្នុងបរិយាកាសនៃសង្គ្រាមស៊ីវិលហែកហួរ ។ ដោយមានការដួលរលំនៃចលនាក្រុមឧទ្ទាម ឆ្នាំ ១៩៩៨ ប្រទេសកម្ពុជាមានរដ្ឋាភិបាលបោះឆ្នោតតាមបែបប្រជាធិបតេយ្យលើកទី ៣ ដែលឋិតនៅក្រោមរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ។ ការកាត់បន្ថយភាពក្រីក្រតាមរយៈការអភិវឌ្ឍន៍ ការកែទំរង់រដ្ឋបាល និងនយោបាយ និងការពង្រឹងសេដ្ឋកិច្ច គឺជាអាទិភាពចំបងសំរាប់រដ្ឋាភិបាល និងម្ចាស់ជំនួយ ។ ចាត់វិធានការដ៏ចំបង ដើម្បីអោយសំរេចបាននូវលទ្ធិប្រជាធិបតេយ្យ វិមជ្ឈការ និងសហវិមជ្ឈការ ដោយធ្វើការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ចំនួន ១៦២១ នៅថ្ងៃទី ០៣-០២-២០០២ ដែលបង្កើតនូវប្រព័ន្ធលទ្ធប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន ។

ជោគជ័យនៃការកែទំរង់ទាំងនេះ នៅក្នុងប្រទេសកម្ពុជា គឺពឹងផ្អែកទៅលើមជ្ឈដ្ឋានដែលធ្វើការកែទំរង់ទាំងនោះ ។ នេះរួមបញ្ចូលទាំងការកែទំរង់មន្ត្រីរាជការកម្ពុជា សង្គមស៊ីវិល សហគមន៍ និងម្ចាស់ជំនួយ ។ ការធ្វើអង្កេតបច្ចុប្បន្ន គឺសំដៅចំពោះមន្ត្រីរាជការទាំងមន្ត្រីតែងតាំង ទាំងមន្ត្រីដែលជ្រើសរើសដោយការបោះឆ្នោត ត្រួតពិនិត្យមើលថាតើរាជការប្រើប្រាស់អំណាចរបស់ពួកគេដោយរបៀបណា ហើយពិនិត្យមើលថា តើរាជការប្រៀបធៀបជាមួយបទដ្ឋានអន្តរជាតិបានដល់កំរិតណាទៅហើយ ។ ការធ្វើអង្កេត គឺដើម្បីកំណត់នូវលក្ខណៈ នៃអភិបាលកិច្ចបច្ចុប្បន្ន និងដើម្បីប្រៀបធៀបអភិបាលកិច្ចបច្ចុប្បន្ន ជាមួយនឹងស្ថានភាពនៅឆ្នាំ ២០០១ ពេលដែលធ្វើការអង្កេតលើកដំបូង ។ ជាការពិតណាស់ ការធ្វើអង្កេតនោះត្រូវបានធ្វើឡើងមុនពេលមានការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ។

រដ្ឋាភិបាលកម្ពុជាមានមូលដ្ឋានគ្រឹះរបស់ខ្លួន នៅដើមទស្សវត្ស ៨០ បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានបណ្តេញចេញពីប្រទេស ដោយកងកំលាំងប្រដាប់អាវុធវៀតណាម និងកងកំលាំងស្នេហាជាតិកម្ពុជា ។ ខ្មែរក្រហមបានបន្សល់ទុកនូវប្រទេសដ៏ខ្ទេចខ្ទាំ និងប្រជាពលរដ្ឋទទួលរងនូវការឈឺចាប់ ។ ប្រជាពលរដ្ឋកម្ពុជា ដែលមានសមត្ថភាពផ្នែករដ្ឋបាលបានវិលត្រលប់ចូលមកទីក្រុងភ្នំពេញវិញ ពួកគេបានជួយបំរើការងារ ដើម្បីស្តារប្រទេសកម្ពុជាឡើងវិញ ។ ស្ថាប័នទាំងឡាយ ត្រូវបានបង្កើតឡើង ភាគច្រើនត្រូវយកគំរូតាមប្រទេសវៀតណាម ដែលក្នុងនោះបក្ស កងកំលាំងការពារជាតិ និងរដ្ឋបាល គឺសុទ្ធតែជាផ្នែកនៃអង្គការចាត់តាំងតែមួយ ។ នៅសម័យនោះទ្រឹស្តី មានសារៈសំខាន់ស្មើទៅនឹងវិន័យចាត់តាំងដែរ ។ នោះគឺជាក្បាលម៉ាស៊ីនដឹកនាំរបស់កុំមុយនីស្តដ៏រឹងមាំ ដែលប្រឆាំងទៅនឹងការកែទំរង់ រហូតដល់ឆ្នាំ ១៩៨៩ នៅពេលនោះកងកំលាំងវៀតណាមបានដកចេញ ។ បន្ទាប់ពីឆ្នាំ ១៩៨៩ ទើបមានការផ្លាស់ប្តូរនយោបាយ ប៉ុន្តែការផ្លាស់ប្តូរនោះតិចតួចបំផុតទៅតាមមធ្យោបាយ ដែលរដ្ឋាភិបាលកម្ពុជាត្រូវបានគ្រប់គ្រង ។ ការផ្លាស់ប្តូរ

មួយក្នុងចំណោមការផ្លាស់ប្តូរទាំងនោះ គឺបុគ្គលិករដ្ឋមួយចំនួន បានចាប់ផ្តើមស្វែងរកកំរៃក្រៅផ្លូវការពីសេវារបស់ពួកគេ ដើម្បីបំពេញបន្ថែមលើប្រាក់បៀវត្ស ឬចំណាយប្រចាំថ្ងៃរបស់ពួកគេ ។ ការផ្លាស់ប្តូរមួយទៀតគឺថា សូមបីតែនៅពេលពហុបក្សបានចាប់ផ្តើម បុគ្គលិករដ្ឋទាំងអស់ ត្រូវបានគេចាត់ទុកជាសមាជិករបស់គណបក្សប្រជាជន (CPP) (ជាការសន្មតដែលនាំអោយមានការវាយតំលៃខុសនូវព្រឹត្តិការណ៍បោះឆ្នោតនាឆ្នាំ ១៩៩៣ ) ។ ក្រោយឆ្នាំ ១៩៨៩ គឺមានទ្រឹស្តីថ្មី ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋទាំងប្រុសទាំងស្រី ដែលបំរើការជាការិយាលេខានុការនៅកំឡុងពេលនោះគឺជាមនុស្សដដែល ដែលមានចំនួន ៩០% នៃមន្ត្រីរាជការកម្ពុជានាបច្ចុប្បន្ន ។ បច្ចុប្បន្ននេះ ពួកគេគឺជាអ្នកអភិរក្សវ័យកណ្តាល ដែលគោរពអ្នកដែលមានអំណាច និងដឹងថាតើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីរស់ ។

មានមន្ត្រីរាជការវ័យក្មេងមួយក្រុម មានចំនួនសរុប ១១% ដែលត្រូវបានជ្រើសរើសក្នុងទស្សវត្ស ៩០ រួមមានអ្នកដែលបានគាំទ្រដោយគណបក្សនយោបាយផ្សេងៗទៀត ក្រៅពីគណបក្សប្រជាជនកម្ពុជា ( CPP ) ដែលរស់នៅប្រទេសក្រៅ ហើយដែលបានជះឥទ្ធិពលដោយផ្នត់គំនិតថ្មី ក្នុងទស្សវត្ស ៩០ ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមមន្ត្រីរាជការវ័យក្មេងនេះ ធ្វើការងារនៅក្នុងបរិយាកាសអភិរក្ស និងទទួលនូវប្រាក់បៀវត្សទៀតដូចគ្នាដែរ ។ ពួកគេមួយចំនួនកំពុងធ្វើបានប្រសើរជាងមន្ត្រីរាជការចាស់ ។ ដើម្បីធ្វើជាអ្នកដឹកនាំរដ្ឋាភិបាលកម្ពុជា នាពេលអនាគត ពួកគេគឺជាគោលដៅដ៏ល្អ សំរាប់ការបង្កើនសមត្ថភាពផ្នែកអភិបាលកិច្ច ។ រដ្ឋាភិបាលក៏ដូចជាម្ចាស់ជំនួយ បានយល់ដឹងពីសារសំខាន់នៃអភិបាលកិច្ច ដើម្បីអភិវឌ្ឍន៍ជាតិ ។ នៅឯកិច្ចប្រជុំទីស្តីការគណៈរដ្ឋមន្ត្រីលើកដំបូង នានីតិកាទី៣ ដែលបានរៀបចំនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ នាយករដ្ឋមន្ត្រីបានប្រកាសថា អភិបាលកិច្ចល្អ គឺជាបុរេលក្ខខណ្ឌដ៏សំខាន់បំផុត ចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ច ហើយសម្តេចនាយករដ្ឋមន្ត្រី ក៏បានមានប្រសាសន៍ដែរថា អភិបាលកិច្ចល្អ គឺជាចំណុចដ៏សំខាន់បំផុតនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ។ ម្ចាស់ជំនួយបានឯកភាព ។ នៅឯកិច្ចប្រជុំក្រុមផ្តល់យោបល់ធនាគារពិភពលោក ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ១០-០៩-២០០៤ ធនាគារពិភពលោកបាននិយាយថា មានឧបសគ្គជាច្រើន ដែលរាំងស្ទះដល់ការធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែឧបសគ្គចំបងគឺការរាំងស្ទះដល់ដំណើរការអភិបាលកិច្ច អំពើពុករលួយ អស្ថេរភាពនយោបាយ និងបញ្ហាបរិស្ថាន ប្រព័ន្ធច្បាប់ និងដំណោះស្រាយវិវាទការនិយតកម្មពន្ធគយ និងពាណិជ្ជកម្ម និងការគ្រប់គ្រងពន្ធ ។

ឥទ្ធិពលដែលបានកំណត់ ចំពោះការធ្វើអោយសំរេចបាននូវអភិបាលកិច្ចល្អ ជាពិសេសនូវថ្នាក់ខេត្ត និងថ្នាក់ឃុំ គឺជាកម្មវិធីសិលារបស់រដ្ឋាភិបាល ។ សីលា គឺជាកម្មវិធីរបស់រដ្ឋាភិបាលកម្ពុជា និងជាការទទួលខុសត្រូវរួមគ្រប់ក្រសួងរបស់ជាតិ ដែលមានទំនាក់ទំនងផ្ទាល់ជាងគេបំផុតជាមួយការអភិវឌ្ឍន៍ជនបទនិងអភិវឌ្ឍន៍នូវដំណើរការនយោបាយវិមជ្ឈការនិងសហវិមជ្ឈការ ។ កម្មវិធីសិលា គឺជាការខិតខំប្រឹងប្រែងរបស់ជាតិ ដើម្បីធ្វើការកាត់

បន្ថយភាពក្រីក្រអោយបានសំរេចតាមរយៈអភិបាលកិច្ចមូលដ្ឋាន អោយមានភាពល្អប្រសើរ ។ បច្ចុប្បន្ននេះ កម្មវិធីសិលាកំពុងគាំទ្រដល់ឃុំ-សង្កាត់ទាំងអស់នៅក្នុង ២៤ខេត្ត-ក្រុង ។ សិលា ជាកម្មវិធីសំរាប់រដ្ឋាភិបាល និងបណ្តាញដៃគូរម្ចាស់ជំនួយផ្តល់ហិរញ្ញវត្ថុជាពហុភាគី ដែលតាមរយៈនោះថវិកាជាង ៧៥លានដុល្លាសហរដ្ឋអាមេរិក ដែលមានតំលៃជាជំនួយបច្ចេកទេស និងជំនួយគាំទ្រផ្នែកកម្មវិធី ត្រូវបានផ្តល់អោយសំរាប់ការអភិវឌ្ឍន៍ជនបទ ។

ការកសាងសមត្ថភាពបុគ្គលិករដ្ឋាភិបាល គឺជាផ្នែកមួយដ៏សំខាន់របស់កម្មវិធីសិលា ។ កម្មវិធីសិលាផ្តល់ឱកាសពីរ ដល់មន្ត្រីមូលដ្ឋាន ។ ពួកគេបានទទួលនូវទស្សនៈថ្មី ដែលអាចជួយអោយពួកគេរៀបចំដំណើរការ ដែលជាការផ្តួចផ្តើមគំនិតដល់សមាជិកសហគមន៍ ក្នុងការអភិវឌ្ឍន៍ និងនាំមកនូវផលប្រយោជន៍របស់ពួកគេ ។ វិធីសាស្ត្រទាំងនេះមានសក្តានុពលនាំមកនូវការផ្លាស់ប្តូរដល់មន្ត្រីប្រហែល ៥០០០នាក់ ដែលពាក់ព័ន្ធដល់កម្មវិធីសិលា ។ មូលដ្ឋាននៃកម្មវិធីសិលា គឺសមត្ថភាពរបស់រដ្ឋាភិបាល ដែលអនុវត្តនូវគោលការណ៍អភិបលកិច្ចល្អ តាមរយៈការប្រើប្រាស់ប្រព័ន្ធ និងបែបបទកម្មវិធីសិលា ។ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ថា អភិបាលកិច្ច ជាកត្តាសំខាន់មួយក្នុងចំណោមកត្តាសំខាន់ទាំងឡាយក្នុងការពង្រឹងសន្តិភាពសន្តិសុខ និងស្ថេរភាពសង្គម ដើម្បីអោយសំរេចបាននូវគោលដៅអភិវឌ្ឍន៍ដល់សំខាន់ និងកាត់បន្ថយភាពក្រីក្រ ។ គោលបំណងអភិវឌ្ឍន៍ទី ៤ ដែលបានរៀបរាប់នៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចលើកទី ២ ២០០១ ដល់ ២០០៥ គឺ : " ពង្រឹងបរិយាកាសអភិបាលកិច្ច " ។ អភិបាលកិច្ច ក៏បានរៀបរាប់ផងដែរនៅក្នុងទស្សនៈនៃយុទ្ធសាស្ត្រ និងនៅក្នុងផ្នែកបរិបទ និងផែនការអនុវត្តការងារ : " អភិបាលកិច្ចល្អ គឺជាអ្វីដែលត្រូវការជាចាំបាច់ ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តភាព និងយុត្តិធម៌សង្គម "។

រដ្ឋាភិបាលកម្ពុជា បានចូលរួមជាមួយនឹងម្ចាស់ជំនួយដោយមានជំនឿថា អភិបាលកិច្ចល្អ និងទាក់ទាញនៅការវិនិយោគទុនច្រើនថែមទៀត និងធ្វើអោយមានកំណើនសេដ្ឋកិច្ច កាលណារដ្ឋាភិបាលពង្រឹងនូវការងាររបស់ខ្លួន ។ វាគឺជាទ្រឹស្តី ដែលត្រូវបានរៀបចំដ៏ល្អប្រសើរ និងមិនអាចកែប្រែបានក្នុងចំណោមម្ចាស់ជំនួយ ដែលរដ្ឋាភិបាលត្រូវតែគោរពច្បាប់ និងអនុវត្តតាមគោលនយោបាយរបស់ខ្លួន ដែលអាចព្យាករណ៍ទុកជាមុនបាន និងត្រឹមត្រូវបំផុត ធានាអោយមានសណ្តាប់ធ្នាប់សង្គម និងមាននិតិរដ្ឋ ។ លើកទឹកចិត្តដល់ការប្រកបអាជីវកម្មផ្សេងៗ និងការពារដល់ទ្រព្យសម្បត្តិ ដែលធ្វើអោយមានទំនុកទុកចិត្ត និងទាក់ទាញវិនិយោគទុនក្នុងស្រុក និងក្រៅស្រុក ។ ដើម្បីអោយសំរេចបាននូវគោលបំណងដែលបានរៀបរាប់ខាងលើនេះ រដ្ឋាភិបាលចាំបាច់ត្រូវយល់ដឹង គិតពិចារណា និងប្រកាន់ខ្ជាប់នូវអត្ថន័យ បទដ្ឋាន និងវិធីសាស្ត្រដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ក្នុងការពិនិត្យតាមដានអភិបាលកិច្ច ។

- **<u>គោលបំណងនៃបេសកកម្ម</u>**

នៅខែមេសា ឆ្នាំ ២០០៣ កម្មវិធីសិលាបានគ្របដណ្តប់គ្រប់ខេត្ត-ក្រុងទាំងអស់ នៅក្នុងប្រទេសកម្ពុជា ។ សិលា កំពុងអនុវត្តបន្តនូវកម្មវិធី ៥ឆ្នាំ របស់ខ្លួន (២០០១-២០០៥) ។ ធនាគារពិភពលោកកំពុងអនុវត្តគំរោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន (RILGP) តាមរយៈកម្មវិធីសិលា ហើយធនាគារពិភពលោកមានជំនឿថា វាជាការសំខាន់ណាស់ក្នុងការធ្វើអង្កេត ស្តីអំពីចំណេះដឹង ឥរិយាបថ ការអនុវត្តន៍ និងជំនឿ របស់មន្ត្រីរដ្ឋាភិ-បាល និងក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលជ្រើសរើសដោយការបោះឆ្នោត បានអនុវត្តន៍នូវអភិបាលកិច្ចល្អ និងដើម្បីធ្វើការប្រៀបធៀបជាមួយនឹងការអង្កេតដែលបានធ្វើ កាលពីឆ្នាំ ២០០១ ។

សរុបសេចក្តីមកគោលបំណង នៃការធ្វើអង្កេតនៅឆ្នាំ ២០០៤នេះ គឺដើម្បីកំណត់នូវការអភិវឌ្ឍន៍បទដ្ឋាននៃអភិបាលកិច្ចល្អនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ឃុំ និងធ្វើការវាយតំលៃចំពោះបទដ្ឋានទាំងនេះ ។ បទដ្ឋានទាំងនេះនឹងត្រូវបានកំណត់ដែលឋិតនៅក្រោមនិទ្ទេសបទ នៃចំណេះដឹង ឥរិយាបទ ការអនុវត្តន៍ និងជំនឿ ។ លទ្ធផល និងធ្វើការប្រៀបធៀបជាមួយការធ្វើអង្កេតលើកដំបូងនៅឆ្នាំ ២០០១ ។

***<u>ក-តួនាទី និងភារកិច្ច</u>***

អត្ថបទទាំងស្រុងស្តីអំពីតួនាទី និងភារកិច្ចផ្លូវការ បានភ្ជាប់ជាឧបសម្ព័ន្ធមួយ ។ អត្ថបទនេះបានណែនាំដល់ក្រុមអ្នកអង្កេត អោយប្រើប្រាស់វិធីសាស្ត្រជ្រើសរើសគំរូដោយឥតព្រៀងទុក ។ តាមគំរោងជ្រើសរើសគំរូ គំរូត្រូវបានកំនត់តាមខេត្ត ដែលបានធ្វើអង្កេតនៅឆ្នាំ ២០០១ ដែលក្នុងនោះ លំអៀងពីស្តង់ដារមិនច្រើនជាង ១០%ទេ (យើងទទួលបានតិចជាង ៨% នៅឆ្នាំ ២០០១) ។ បញ្ជីសំណួរបានរៀបចំ ទៅតាមបញ្ជីសំណួរដែលបានប្រើប្រាស់នៅឆ្នាំ ២០០១ ដោយផ្អែកទៅតាមនិយមន័យនៃអភិបាលកិច្ច ដែលអាចទទួលយកបាន និងដោយផ្អែកទៅលើបទដ្ឋាន នៃអភិបាលកិច្ច ដែលបានឯកភាពដោយបុគ្គលិកលេខាធិការដ្ឋាន របស់គណៈកម្មាធិការដឹកនាំការងារកម្មវិធីសិលា ។ ហើយបន្ទាប់មកក៏បានបញ្ចូលសំណួរទាំងអស់ ទៅក្នុងមូលដ្ឋានទិន្នន័យ SPSS ។ បន្ទាប់មកទៀតការធ្វើសំភាសន៍តាមរបៀប (Quantitative) និង (Qualitative) ត្រូវបានអនុវត្តន៍នៅក្នុងខេត្តចំនួន ៧ ដែលបានឯកភាពគ្នា ។ បញ្ជីសំណួរ (Quantitative) ត្រូវបានបំពេញដោយមន្ត្រីតែងតាំង និងមន្ត្រីដែលជ្រើសរើសដោយការបោះឆ្នោតនៅគ្រប់ថ្នាក់ទាំងអស់ (សង្កត់ធ្ងន់ទៅលើមន្ត្រីថ្នាក់ឃុំ) ចំណែកឯការធ្វើសំភាសន៍តាមរបៀប (Qualitative) បានធ្វើជាមួយសហគមន៍ សង្គមស៊ីវិល និងប្រជាពលរដ្ឋផ្សេងទៀតដែលមិនមែនជាមន្ត្រី ។ ពត៌មានដែលប្រមូលបាន ត្រូវយកមកធ្វើវិភាគ ធ្វើការបែងចែកដាច់ដោយឡែកពីគ្នា និងដាក់បញ្ចូលនៅក្នុងរបាយការណ៍ និងនៅក្នុងឧបសម្ព័ន្ធ ។

- **វិធីសាស្ត្រនៃបេសកកម្ម**

## *ក-គំរូជ្រើសរើស សំរាប់ធ្វើអង្កេត Quantitative*

ក្នុងចំណោម ២៤ ខេត្ត-ក្រុង របស់ប្រទេសកម្ពុជា ភ្នំពេញត្រូវបានជ្រើសរើសតាមការកំណត់ទុកជាមុន បន្ទាប់មកជ្រើសរើសខេត្តចំនួន ៦ ដែលបានធ្វើការអង្កេតនៅឆ្នាំ ២០០១ នៅក្នុងនោះ ខេត្ត ២ ដែលកាលពីឆ្នាំ ២០០១ មិនទាន់មានកម្មវិធីសិលានោះទេ ត្រូវបានប្រើប្រាស់ដើម្បីធ្វើការត្រួតពិនិត្យនៅពេលនោះ ។ ក្នុងនោះមានខេត្តតាកែវ បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង កំពង់ចាម កំពង់ស្ពឺ និងភ្នំពេញ ត្រូវបានជ្រើសរើស បន្ទាប់មកគិតគូរគំរូជ្រើសរើសដ៏ចៃដន្យ ដែលរៀបតាមលំដាប់ជាន់ថ្នាក់សំរាប់ធ្វើការអង្កេតនៅក្នុងខេត្ត-ក្រុង ចំនួន ៧ ទាំងនេះ ។ ចំនួនគំរូដែលជ្រើសរើសត្រូវរៀបដាក់ទៅតាមប្រភេទ នៃអ្នកផ្តល់ពត៌មាន អ្នកផ្តល់ពត៌មានទាំងអស់ សុទ្ធតែជាមន្ត្រីរាជការកម្ពុជា នៅថ្នាក់ផ្សេងៗគ្នា មានថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក ថ្នាក់ឃុំ-សង្កាត់ និងថ្នាក់ភូមិ ។ ចំពោះប្រភេទនៃអ្នកផ្តល់ពត៌មានផ្សេងៗគ្នា ទំហំនៃការជ្រើសរើសគំរូតាមការស្នើសុំចំនួន ៣ ត្រូវបានគិតគូរទុកជាមុន ។ ទំហំនៃការជ្រើសរើសគំរូ ត្រូវផ្អែកទៅតាមការជ្រើសរើសគំរូ ដោយមានការលំអៀងពីស្តង់ដារ គឺ ១០% , ៨% ឬក៏ ៥% ហើយទុកចិត្តបាន ៩៥% ។ តារាងដែលបានភ្ជាប់ជាមួយជាឧបសម្ព័ន្ធបី បានរៀបរាប់អំពីវិធីសាស្ត្រ នៃការជ្រើសរើសគំរូ ។ នៅពេលដែលក្រុមអង្កេតអាចទទួលបានគំរូ ដោយមានការលំអៀងពីស្តង់ដារក្រោម ៨% ។

ការធ្វើអង្កេតដោយផ្អែកលើបញ្ជីសំណួរ (Quantitative) (ដែលបានភ្ជាប់ជាឧបសម្ព័ន្ធ ៥ ) ដែលរួមមាននិទស្សន៏ចង្អុលបង្ហាញការវាយតំលៃ ហើយបកប្រែជាភាសាខ្មែរ បានឯកភាពដោយលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកម្មវិធីសិលា ត្រូវបានចែកជូនដល់មន្ត្រីរដ្ឋាភិបាលតែងតាំង និងមន្ត្រីក្រុមប្រឹក្សាឃុំ-សង្កាត់ចំនួន ២០០០នាក់ ដែលបានកំណត់នៅក្នុងគំរូនេះ ។ លទ្ធផលត្រូវបានបញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យ SPSS ដែលបានបង្កើតទៅតាមគោលបំណងចង់បាន ។ លទ្ធផលទាំងអស់ត្រូវបានវិភាគជាលទ្ធផលរួមមួយ សំរាប់ខេត្តចំនួន ៧ ព្រមទាំងបំបែកដោយឡែកៗទៅតាមខេត្ត ភេទ ទៅតាមមន្ត្រីតែងតាំង មន្ត្រីជ្រើសរើសដោយការបោះឆ្នោត និងស្មៀនឃុំ-សង្កាត់ ដែលជាសមាសភាពថ្មី និងសំខាន់ នៅក្នុងអភិបាលកិច្ចនៅតាមខេត្តនានា ។ លទ្ធផលដែលទទួលបានពីដំណាក់កាលទី១ នេះ ត្រូវបែងចែកជាត្រីកោណផងដែរ ដោយជាប់ជាមួយទិន្នន័យ (Qualitative) ដែលប្រមូលបាននៅក្នុងតំបន់តែមួយ ដែលនៅទីនោះបញ្ជីសំណួរត្រូវបានចែកចាយសំរាប់បំពេញផងដែរ ទិន្នន័យទាំងនេះដែលទទួលបានពីការធ្វើអង្កេតស្តីពីអភិបាលកិច្ច បានបញ្ចូលទៅក្នុងប្រការ៣ នៃ TORS និងធ្វើការប្រៀបធៀបជាមួយនឹង ការធ្វើអង្កេតនៅឆ្នាំ ២០០១ ដើម្បីធ្វើការចាប់អារម្មណ៍ថាតើ មន្ត្រីរាជការកម្ពុជា ទាំងមន្ត្រីតែងតាំង មន្ត្រីជាប់ឆ្នោតកំពុងបំពេញភារកិច្ចរបស់ពួកគេដល់កំរិតណា ។

### ខ-ការជ្រើសរើសគុំរូ *Qualitative*

ដំណាក់កាលសិក្សាស្របពេលជាមួយគ្នា បានត្រូវអនុវត្តដោយប្រើវិធីសាស្ត្រចូលរួម (Qualitative) ដែលជាក្រុមពិភាក្សា (PLA) និងការធ្វើសំភាសន៍ផ្ទាល់ជាលក្ខណៈបុគ្គល (SSI) ។ លទ្ធផលទទួលបានពីដំណាក់កាលនេះ ត្រូវប្រើប្រាស់ដើម្បីបែងចែកលទ្ធផល ដែលទទួលបានពីបញ្ជីសំណួរ (Quantitative) ជាត្រីកោណ ។ បញ្ជីសំណួរជាច្រើនដែលបានចែកជូនសំរាប់បំពេញ ទោះជានៅទីណាក៏ដោយ ឧទាហរណ៍ នៅសាលាស្រុក ឬសាលាឃុំ ក្រុមអ្នកអង្កេតក៏បានរៀបចំក្រុមពិភាក្សា (PLA) យ៉ាងហោចណាស់ក៏មួយក្រុមដែរ និងធ្វើសំភាសន៍ផ្ទាល់ជាលក្ខណៈបុគ្គល (SSI) ពី ១-៣នាក់ ។ ក្រុមពិភាក្សា ច្រើនតែរៀបចំនៅក្នុងភូមិជិតៗ ដោយមានអ្នកភូមិពី ១០-១២នាក់ចូលរួម ហើយដែលជាទីពេញចិត្តនោះ គឺចំនួនបុរស និងស្ត្រីស្មើគ្នា ហើយមន្ត្រីអង្គការក្រៅរដ្ឋាភិបាលដែលត្រូវបានអញ្ជើញអោយមកចូលរួមនៅក្នុងបទសំភាសន៍នោះ ដោយផ្អែកលើមូលដ្ឋាន ដែលពួកគេមានការចាប់អារម្មណ៍ជាខ្លាំងនៅក្នុងការអភិវឌ្ឍន៍ ។ នៅក្នុងក្រុមពិភាក្សា អ្នកចូលរួមបានសរសេរអំពីគំរូវការអភិវឌ្ឍន៍នូវមូលដ្ឋានរបស់ពួកគេសមិទ្ធិផលដែលទទួលបានកន្លងមក និងគំរោងដែលត្រូវបានគេបោះបង់ចោលនៅលើផ្ទាំងក្រដាស់ធំមួយ ហើយក៏បានពិភាក្សាអំពីទិដ្ឋភាពនៃអភិបាលកិច្ច ។ ក្រុមពិភាក្សាក៏បានធ្វើការសន្និដ្ឋាន ទៅលើទិដ្ឋភាពអភិបាលកិច្ច ដែលបានជះឥទ្ធិពលដល់ពួកគេ ។ ការប្រជុំពិភាក្សាត្រូវបានប្រើខ្សែអាត់ថតសំលេង ( ដោយមានការអនុញ្ញាតពីអ្នកចូលរួម ) ហើយសំលេងដែលថតបានពីការប្រជុំ នឹងត្រូវសរសេរឡើងវិញទាំងអស់ ជាភាសាអង់គ្លេស និងធ្វើវិភាគដើម្បីរកខ្លឹម-សាររបស់វា ។

នៅពេលដែលក្រុមពិភាក្សាកំពុងតែដំណើរការ សមាជិករបស់ក្រុមអង្កេតផ្សេងទៀត ចេញស្វែងរកអ្នកផ្តល់សំភាសន៍ផ្ទាល់ជាលក្ខណៈបុគ្គល (ឧទាហរណ៍ : បុគ្គលនោះមិនមែនជាមន្ត្រីរាជការ) នៅក្នុងភូមិដែលអាចបញ្ចេញនូវទស្សនៈអំពីព្រឹត្តការណ៍ថ្មីៗ ។ ពួកគេក៏បានជ្រើសរើសអ្នកម៉ៅការ មន្ត្រីអង្គការក្រៅរដ្ឋាភិបាល អ្នកប្រកបអាជីវកម្ម គ្រូបង្រៀន ។ល។ ប្រជាពលរដ្ឋទាំងនេះ ត្រូវបានសួរសំណួរជាលក្ខណៈបុគ្គល (SSI) ដែលផ្តោតទៅលើការយល់ដឹងអំពីអភិបាលកិច្ច ។ ការធ្វើសំភាសន៍ (SSI) ក៏ត្រូវប្រើខ្សែអាត់ថតសំលេងដែរ (ប៉ុន្តែដោយមានការអនុញ្ញាតពីអ្នកផ្តល់សំភាសន៍ផងដែរ មានអ្នកម៉ៅការតែ ២នាក់គត់ ដែលធ្វើការបដិសេធមិនអោយថតសំលេង ដោយពួកគេមានបំណងធ្វើការត្អូញត្អែរអំពីដំណើរការដេញថ្លៃ ) ហើយសំលេងដែលថតបានពីការសំភាសន៍នោះ ត្រូវបានសរសេរជាភាសាអង់គ្លេស និងធ្វើការវិភាគដើម្បីរកខ្លឹមសាររបស់វា ។ ដោយសារតែអ្នកចូលរួមទាំងអស់ ត្រូវបានធានានូវការសំងាត់ សំលេងដែលថតបាននេះ មិនត្រូវបានចែកចាយជាផ្នែកមួយនៃរបាយការណ៍នោះទេ ។

ផ្នែកសំខាន់ទី ៣ នៃពត៌មានដែលទទួលបានពីការធ្វើអង្កេត គឺរបាយការណ៍របស់អ្នកផ្តល់ពត៌មានសំខាន់ (Key Informant) ប្រធានក្រុមអង្កេតបានធ្វើសំភាសន៍ជាមួយមន្ត្រីជាន់ខ្ពស់មួយចំនួន ដែលមានទស្សនៈស្តីអំពីអភិបាលកិច្ច មានដូចជា អភិបាលខេត្ត-ក្រុង អភិបាលខេត្តរង ឬមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ផ្សេងៗទៀត ។ ខ្សែអាត់ថតសំលេងនៃកិច្ចសំភាសន៍ ត្រូវបានរៀបចំ និងផ្ទៀងផ្ទាត់ជាមួយសមាជិកក្រុមអង្កេតទាំងនោះ ដែលមានវត្តមាន រួមមានអ្នកបកប្រែដែលព្យាយាមផ្ទៀងផ្ទាត់អោយបានត្រឹមត្រូវ ។ ទស្សនៈដែលបញ្ចេញ នៅក្នុងរបាយការណ៍របស់អ្នកផ្តល់ពត៌មានសំខាន់ (Key Informant) ត្រូវបានប្រើប្រាស់ដើម្បីបែងចែកទាំងលទ្ធផល នៃបញ្ជីសំណួរ (Quantitative) និងទាំងលទ្ធផលនៃការធ្វើសំភាសន៍ (Qualitative) ជាត្រីកោណ ។ បញ្ជីសំណួរ(Quantitative) ចំនួន១៩៥៨ ត្រូវបានបំពេញដោយបុរស និង ស្ត្រី ក្នុងនោះមានសមាជិកសហគមន៍ចំនួន៥៥២នាក់ ដែលមានស្ត្រីចំនួន ២៥៧ បានចូលរួមក្នុងការប្រជុំជាក្រុមពិភាក្សា (PLA) ការសម្ភាសន៍ជាលក្ខណៈបុគ្គល (SSI) និង ការសម្ភាសន៍ជាមួយអ្នកផ្តល់ពត៌មានសំខាន់ (Key Informant) ។ លទ្ធផលនៃវិធីសាស្ត្រធ្វើអង្កេតទាំងអស់ ទាំង (Qualitative) និង (Quanitative) ត្រូវបានយកមកពិចារណារួមជាលទ្ធផលសរុប ដែលត្រូវបែងចែកជាត្រីកោណ សំរាប់ខេត្តគោលដៅនីមួយៗ និងជាលទ្ធផលដោយឡែកក្នុងកំរូថ្នាក់ជាតិ ។

**ត-ចំណុចខ្លាំង និង ផលវិបាក**

**ចំណុចខ្លាំង:**

បញ្ជីសំណួរ (Quantitative) បានធ្វើការស្ទាបស្ទង់នូវចំណេះដឹងរបស់មន្ត្រីចំនួន ១៩៩៨នាក់ នៅក្នុងខេត្តចំនួន៦ និងទីក្រុងភ្នំពេញ និងដាក់បញ្ចូលសំរាប់ធ្វើការវិភាគក្នុងមូលដ្ឋានទិន្នន័យ (SPSS) ដែលជាកម្មវិធីខ្លាំងផ្នែកបញ្ចូលស្ថិតិ ។ បន្ថែមពីលើនេះទៀត បញ្ជីសំណួរ (Quantitative) គឺវែង (៦០សំណួរដែលតែងតែមានអត្ថបទខ្លីអមជាមួយ ស្ថិតនៅក្រោមចំណងជើងនៃចំណេះដឹង ឥរិយាបថ ការអនុវត្តន៍ និង ជំនឿ) ហើយត្រូវការផ្តោតយកចិត្តទុកដាក់។ ក្រុមអង្កេតបានព្យាយាមធ្វើអោយប្រាកដថា បរិយាកាសជុំវិញទីកន្លែងដែលសំរាប់បំពេញបញ្ជីសំណួរ គឺត្រជាក់ហើយងាយស្រួល ហើយមិនអនុញ្ញាតិអោយមន្ត្រីចំលងតាមគ្នាឡើយ ។ ចំពោះអ្នកដែលមានការលំបាកក្នុងការសរសេរ រឺមើល រឺ សំរាប់មន្ត្រីដែលមិនយល់នូវសំណួរណាមួយ តែងតែមានបុគ្គលិកមានសមត្ថភាពជួយជានិច្ច (បុគ្គលិកដែលស្លៀកពាក់ឯកសណ្ឋានអាវយឺត និងមួកពណ៌ស មានផ្លាកសញ្ញា ព្រមទាំងពាក់ប័ណ្ណសំគាល់ខ្លួនទៀតផង) ។ មានចំលើយបាទ/ចាស/ទេ ព្រមទាំងមានចំលើយដែលអាចជ្រើសរើសបានច្រើនទៀតផង ដែលជួយផ្តោតការយកចិត្តទុកដាក់ ។ អ្នកផ្តល់ពត៌មានភាគច្រើនបាននិយាយថា ពួកគេយល់ឃើញថា បញ្ជីសំណួរដែលពួកគេបំពេញ គឺគួរអោយចាប់អារម្មណ៍ក្រៃលែង ។

ការពិភាក្សាជាក្រុម (PLA) បានផ្តោតទៅលើដ្យាក្រាមអភិវឌ្ឍន៍ ដោយមានការចូលរួមរបស់អ្នកភូមិក្នុងការបំពេញនូវដ្យាក្រាមអភិវឌ្ឍន៍នោះ និងអធិប្បាយអំពីស្ថានភាពបច្ចុប្បន្ន ជោគជ័យ និងបរាជ័យនៃគំរោងអភិវឌ្ឍន៍និមួយៗ រីក៏ការខិតខំប្រឹងប្រែង បានផ្តល់នូវការផ្តោតយកចិត្តទុកដាក់ ដែលនាំទៅរកការពិភាក្សាអំពីប្រធានបទនៃអភិបាលកិច្ច ។ ការពិពណ៌នាជាក់ស្តែង ស្តីពីប្រធានបទដែលធ្លាប់បានដឹងបានលឺរួចមកហើយ ធ្វើអោយកាន់តែងាយយល់ឡើង ហើយពិភាក្សាអំពីបញ្ហាស្មុគ្រស្មាញ ហើយបានជួយអោយអ្នកចូលរួមដាក់ភ្ជាប់ រវាងទស្សនៈខុសគ្នានៃការអភិវឌ្ឍន៍ជាមួយអភិបាលកិច្ច ។ បែបបទរៀបចំក្រុមពិភាក្សា (PLA) បានទទួលនូវការឯកភាពពីអ្នកចូលរួមដែលធ្វើអោយពួកគេមានការពេញចិត្តជាងការចោទសួរ ឬការបំពេញបញ្ជីសំណួរ ។ ដ្យាក្រាមអភិវឌ្ឍន៍ រឹតតែធ្វើឱ្យពួកគេមានការចាប់អារម្មណ៍ និងធ្វើអោយពួកគេមានអារម្មណ៍ថា ទស្សនៈរបស់ពួកគេមានតំលៃដែលបានបង្កើននូវការលើកកំពស់ និងទំនុកចិត្តខ្លួនឯង បញ្ជីសំណួរអាចធ្វើអោយពួកគេមានអារម្មណ៍ថា ខ្លួនគេផ្ទាល់ល្ងិតល្ងង់ បើពួកគេមិនយល់អំពីចំលើយ ។

ការធ្វើសំភាសន៍ផ្ទាល់ជាលក្ខណៈបុគ្គល (SSI) គឺប្រើជាមួយប្រជាពលរដ្ឋដែលមានពេលវេលាច្រើន មានចំណេះដឹង និងពេញចិត្តនៅក្នុងការធ្វើសំភាសន៍តែប៉ុណ្ណោះ ។ បើអ្នកផ្តល់ពត៌មាន មានការរារែកក្នុងការឆ្លើយ ក្រុមអង្កេតបានស្នើសុំដោយសមគួរអោយបញ្ឈប់ការសន្ទនានោះភ្លាម ។ អ្នកផ្តល់ពត៌មានភាគច្រើនពេញចិត្តនឹងការពិភាក្សាអំពីប្រធានបទនៃអភិបាលកិច្ច ពីព្រោះវាបានជះឥទ្ធិពលដល់ជីវភាពរបស់ពួកគេ ។ មានតែអ្នកផ្តល់ពត៌មាន តែ ២នាក់គត់ ដែលមិនយល់ព្រមអោយថតសំលេងរបស់ពួកគេ ។ ចំណែកឯអ្នកផ្តល់ពត៌មានផ្សេងៗទៀត បានយល់ព្រមអោយថតសំលេង ដោយហេតុថា ទស្សនៈដែលគេបញ្ចេញនឹងត្រូវចាត់ទុកជាការសំងាត់ ។ អ្នកខ្លះឆ្លើយត្រង់ ហើយច្បាស់លាស់ទៀត ។ ចំណែកឯការធ្វើសំភាសន៍ជាមួយអ្នកផ្តល់ពត៌មានសំខាន់ (Key Informant) ដូចជា អភិបាលខេត្ត-ក្រុង និងសមាជិកគណៈកម្មាធិការដឹកនាំការងារកម្មវិធីសិលា គឺមានសារៈសំខាន់ណាស់នៅក្នុងដំណើរការធ្វើវិភាគដោយបញ្ចូលបញ្ហាទាំងអស់ ទៅក្នុងបរិបទ ។

ក្រុមអង្កេតក៏បានទទួលនូវអត្ថប្រយោជន៍ដ៏ធំធេងផងដែរ ក្នុងការបំពេញការងារតាមរយៈលេខាធិការដ្ឋាន នៃគណៈកម្មាធិការដឹកនាំការងារកម្មវិធីសិលា ដែលមានសមត្ថភាព និងក្រុម (PLG) នៅភ្នំពេញ និងនៅតាមបណ្តាខេត្ត ដែលបានធ្វើអង្កេត ។ ក្រុមទាំងនេះអាចរៀបចំប្រមូលផ្តុំមន្ត្រីនៅតាមឃុំឆ្ងាយៗ ដែលឋិតនៅក្នុងខេត្តគោលដៅ ។ ចំណែកឯការិយាល័យរបស់អភិបាលខេត្ត-ក្រុង ក៏បានរៀបចំតាមវិធីសាស្ត្រ ដែលផ្តល់នូវផលល្អដូចគ្នានេះដែរ ។

***ផលវិបាក:***

ផលវិបាកដែលក្រុមអង្កេតបានប្រឈមមុខ គឺថា ការអង្កេតបានធ្វើនៅរដូវភ្លៀង ។ ដើម្បីដោះស្រាយនូវមធ្យោបាយធ្វើដំណើរ ជូនកាលក្រុមអង្កេតបានធ្វើដំណើរយ៉ាងជ្រៅចូលទៅក្នុងខេត្ត តាមដែលអាចធ្វើទៅបានដោយប្រើរថយន្ត កាណូត ឬម៉ូតូ ។ ទាំងមន្ត្រីតែងតាំង និងមន្ត្រីដែលជាប់ឆ្នោត ឆ្លៀតពេលដើម្បីបំពេញបញ្ជីសំនួរតាមដែលគេអាចធ្វើទៅបាន ។ មានតែតំបន់មួយទេ ដែលក្រុមអង្កេតមានបញ្ហា ទាក់ទងទៅនឹងការបំពេញបញ្ជីសំនួរនោះគឺ ទីក្រុងភ្នំពេញ មន្ត្រីថ្នាក់ជាតិខ្លះ បានបដិសេធមិនបំពេញសំនួរមួយចំនួន ។ ដោយអះអាងថា បញ្ជីសំណួរសួរទាក់ទងទៅនឹងគោលនយោបាយក្រសួងរបស់ពួកគេ ។ ដូច្នេះក្រុមអង្កេត មិនអាចដោះស្រាយនៅបញ្ហានេះបាន ឡើយ ។ បញ្ជីសំណួរសំខាន់ ត្រូវបានធ្វើការកែសំរួលជាច្រើនដង ។ សំនួរដែលបានរៀបចំនៅពេលបោះឆ្នោតក្រុម ប្រឹក្សាឃុំ-សង្កាត់ ត្រូវបានលប់ចោល ។ សំនួរដែលទាក់ទងទៅនឹងអង្គការមូលដ្ឋានដូចជា ក្រុមប្រឹក្សាអភិវឌ្ឍន៍ភូមិ និងក្រុមប្រឹក្សាអភិវឌ្ឍន៍ឃុំ ក៏ត្រូវបានលុបចោលដែរ ។ ប៉ុន្តែសំនួរភាគច្រើន នៅតែយកមកប្រើប្រាស់ ជាពិសេសសំរាប់ធ្វើការប្រៀបធៀបជាមួយលទ្ធផលធ្វើអង្កេតនៅឆ្នាំ ២០០១ ។ ដូចនៅក្នុងការអង្កេតអំពីបញ្ហាសង្គម (Quantitaive) និង (Qualitative) លទ្ធផលនៃការធ្វើអង្កេត គឺមានសុពលភាព ដូចពត៌មានដែលបុគ្គលសំរេចផ្តល់អោយដល់អ្នកស្រាវជ្រាវពត៌មានដែរ ។

***ឃ-ក្រុមចុះអង្កេត***

អង្គការ គ្រួសរ៉ូដស៍ ក្រុមផ្តល់យោបល់ បានឆ្លើយតបជាវិជ្ជមាន ទៅតាមការអញ្ជើញអោយដេញថ្លៃដើម្បីធ្វើការអង្កេតពីគណៈកម្មាធិការដឹកនាំការងារកម្មវិធីសិលា នៅក្នុងខែមេសា ឆ្នាំ ២០០៤ បន្ទាប់ពីដំណើរការនៃការពន្យាពេល និងដំណើរការយឺតយ៉ាវនៃការចចារ ទីបំផុតរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចុះហត្ថលេខាលើកិច្ចសន្យានៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ ។ ក្រុមអង្កេតជ្រើសរើសដោយ អ្នកចុះកិច្ចសន្យា គឺអង្គការគ្រួសរ៉ូដស៍ ដែលជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលមានអ្នកវិភាគពត៌មាន ជាជនជាតិបរទេស មានបទពិសោធន៍ មានអ្នកចាត់ចែងកម្មវិធីសំរាប់ធ្វើអង្កេតជាជនជាតិកម្ពុជា ដែលមានបទពិសោធន៍ និងមានទីប្រឹក្សាបញ្ចូលពត៌មាន ជនជាតិកម្ពុជា ដែលធ្លាប់បានធ្វើការងារទាក់ទងទៅនឹងការអង្កេតនេះច្រើនឆ្នាំកន្លងមកហើយ ។ សមាជិកផ្សេងៗទៀត ជាបុគ្គលិកចុះអង្កេត ដែលមានបទពិសោធន៍ បានធ្វើការអង្កេតជាមួយអង្គការគ្រួសរ៉ូដស៍ច្រើនលើកមកហើយ ។ ក្រុមអង្កេតនេះមានបទពិសោធន៍ធ្វើការងារនៅទីវាល និងមានបទពិសោធន៍ធ្វើការងារជាមួយគ្នាបានល្អ ។

ការបណ្តុះបណ្តាលដំបូងជាភាសាខ្មែរ ដោយគ្រូបណ្តុះបណ្តាលមានបទពិសោធន៍ ។ ការបណ្តុះបណ្តាលរួមមានការសាកល្បងនៅបញ្ជីសំណួរ រៀបចំក្រុមពិភាក្សា និងធ្វើការសំភាសន៍ផ្ទាល់ជាលក្ខណៈបុគ្គល (SSI)

ធ្វើការកត់ត្រាបញ្ចូលពត៌មាន និងសិក្សាអំពីវត្ថុស័ក្តិពិសេសជាភាសាខ្មែរ និងភាសាអង់គ្លេស ដែលទាក់ទងនឹងអភិបាលកិច្ច ។ ធ្វើការចុះអង្កេតសាកល្បងនៅខេត្តកណ្តាល ផលវិបាករួមបញ្ចូលផងដែរ គឺពេលវេលាសំរាប់បណ្តុះបណ្តាលកំណត់ត្រឹម ១សប្តាហ៍ ។ ដោយសារតែបុគ្គលទាំងអស់មានបទពិសោធន៍យ៉ាងហោចណាស់ ៤ ឬ ៥ឆ្នាំដែរ ហើយការបណ្តុះបណ្តាល គឺគ្រាន់តែជាការរំលឹកឡើងវិញតែប៉ុណ្ណោះ ។

ការិយាល័យគណៈកម្មាធិការដឹកនាំការងារកម្មវិធីសិលា និងការិយាល័យ PLG នៅក្នុងខេត្តនិមួយៗបានចាត់ចែងការងារទុកជាមុន ។ នៅក្នុងខេត្តនិមួយៗ ក្រុមអង្កេត ២ក្រុម ដែលក្នុង១ក្រុម មានសមាជិក ៧នាក់ បានធ្វើដំណើរតាមម៉ោងកំណត់ទៅសាលាស្រុកផ្សេងៗគ្នា ជាទីកន្លែងដែលមន្ត្រីថ្នាក់ស្រុក ក្រុមប្រឹក្សាឃុំ និងស្មៀនឃុំមកពីឃុំផ្សេងៗ (រួមទាំងស្ត្រី ដែលបំរើការជាមន្ត្រី បានអញ្ជើញមកតាមការស្នើសុំជាពិសេសផងដែរ) បានជួបជុំនៅទីកន្លែងដ៏សមគួរ ។ ពេលនោះ ទស្សនៈទាំងឡាយទាក់ទងទៅនឹងការធ្វើអង្កេត និងប្រភេទនៃបញ្ជីសំណួរត្រូវបានពន្យល់យ៉ាងក្បោះក្បាយដល់អ្នកចូលរួម ។ នៅពេលនោះដែរ អ្នកចូលរួម ត្រូវបានត្រួតពិនិត្យក្នុងការបំពេញបញ្ជីសំណួរ ។ ពេលដែលការប្រជុំកំពុងតែដំណើរការ សមាជិកនៃក្រុមអង្កេតដ៏ទៃទៀត បានធ្វើដំណើរទៅភូមិជិតខាងដើម្បីរៀបចំនូវក្រុមពិភាក្សា (PLA) ។ ចំណែកឯសមាជិកផ្សេងទៀត បានស្វែងរកប្រជាពលរដ្ឋនៅក្នុងឃុំ ដែលមិនមែនជាមន្ត្រីរដ្ឋាភិបាល ហើយដែលមានទស្សនៈច្រើនអំពីអភិបាលកិច្ច សំរាប់ធ្វើការសំភាសន៍ផ្ទាល់ជាលក្ខណៈបុគ្គល (SSI) ។ ពេលដែលបញ្ជីសំណួរត្រូវបានបំពេញចប់សព្វគ្រប់ ហើយការសំភាសន៍ផ្ទាល់ជាលក្ខណៈបុគ្គល និងក្រុមពិភាក្សាបានបញ្ចប់ហើយនោះ ក្រុមអង្កេតបានវិលត្រលប់មកទីរួមខេត្តវិញ គឺវិលត្រលប់មកការិយាល័យដែលអង្គការគ្រួសរ៉ូដស៍បានជួលនៅទីនោះ ។ បន្ទាប់មកបញ្ជីសំណួរ ត្រូវបញ្ចូលទៅក្នុងកម្មវិធីសំរង់ស្ថិតិកុំព្យូទ័រ ហើយចំណែកឯការធ្វើសំភាសន៍វិញ ត្រូវបានសរសេរជាភាសាអង់គ្លេស ពិនិត្យផ្ទៀងផ្ទាត់ឡើងវិញជាមួយនឹងអ្នកវិភាគ ។

នៅក្នុងសហគមន៍សមាជិកក្រុមអង្កេត បានពាក់អាវ និងពាក់មួកស បោះពុម្ពសំរាប់ធ្វើការអង្កេត។ អាវមានផ្លាកសញ្ញាសិលានៅខាងខ្នង សមាជិកក្រុមអង្កេតក៏បានពាក់ប័ណ្ណសំគាល់ខ្លួន កម្មវិធីសិលា PLG & Crossroads សំរាប់សុវត្ថិភាពផ្ទាល់ខ្លួន និងភាពដែលអាចទុកចិត្តបាន ហើយកាន់លិខិតអនុញ្ញាតសំរាប់ការធ្វើអង្កេតដែលចុះហត្ថលេខាដោយអភិបាលខេត្តនិមួយៗ ។

### ***ង-សកម្មភាពបេសកកម្ម***

មានសេចក្តីថ្លែងដ៏ពេញលេញ ដែលបានលើកឡើងនៅក្នុងសកម្មភាពបេសកកម្ម បានអធិប្បាយនៅក្នុងឧបសម្ព័ន្ធ ៤ ។ សេចក្តីថ្លែងនេះ បានអធិប្បាយអំពីសកម្មភាពទាំងអស់ ដែលបានអនុវត្ត និងរៀបរាប់អំពីប្រជា-

ពលរដ្ឋដែលបានទាក់ទងក្នុងកំឡុងធ្វើការអង្កេត ។ ដោយសារតែវាជាកំណត់ហេតុប្រចាំថ្ងៃ វាច្រើនសំបើមណាស់ ហើយក៏មិនរាប់បញ្ចូលនូវគំនិតផ្សេងៗទៀត ប្រសិនបើមានការកំណត់ទីតាំងនៅត្រង់នោះ ។

***ច-ការពិនិត្យឡើងវិញនូវប្រភពបន្ទាប់បន្សំ***

វត្ថុស័ព្ទដែលពាក់ព័ន្ធជុំវិញអភិបាលកិច្ចនៅក្នុងប្រទេសកម្ពុជា ត្រូវបានពិនិត្យឡើងវិញ មុនពេលធ្វើការអង្កេត ហើយត្រូវបានកត់ត្រាទុកជាឧបសម្ព័ន្ធ ៨ ។ ឧបសម្ព័ន្ធនេះ បានរួមបញ្ចូលទាំងវត្ថុស័ព្ទ ដែលបានត្រួតពិនិត្យឡើងវិញសំរាប់ការអង្កេតលើកដំបូង ដែលនៅក្នុងនោះ វាក្លាយជាប្រភពសំរាប់ធ្វើជានិយមន័យ និងបទដ្ឋានដែលត្រូវបានប្រើប្រាស់ ដើម្បីផ្តល់ពត៌មានស្តីអំពីរចនាសម្ព័ន្ធមូលដ្ឋាននៃការធ្វើអង្កេតមានដូចជាបញ្ជីសំណួរជាដើម ។ ការសន្និដ្ឋានបានធ្វើឡើងបន្ទាប់ពីត្រួតពិនិត្យឡើងវិញនូវវត្ថុស័ព្ទចាស់ និងវត្ថុស័ព្ទថ្មី ដែលនិយមន័យប្រើប្រាស់នៅឆ្នាំ ២០០១ នៅតែមានសុពលភាពនៅឡើយ ។ សូមបញ្ជាក់ផងដែរថា ទិដ្ឋភាពសំខាន់ ៤ នៃអភិបាលកិច្ច នៅតែជាពាក្យ : គណនេយ្យភាព ការចូលរួម ការព្យាករណ៍ទុកជាមុន និងតម្លាភាព ដដែល ។ និយមន័យបទដ្ឋាន នៃអភិបាលកិច្ច គឺនៅដដែល ។

- **ការធ្វើគារវកិច្ចតប**

អង្គការ គ្រួសរ៉ូដស៍ ក្រុមផ្តល់យោបល់ Crossroads Consultancies Group សូមធ្វើគារវកិច្ចតបចំពោះការជួយជ្រោមជ្រែងប្រកបដោយសុទ្ធចិត្ត របស់ឯកឧត្តម **ង៉ៀង យ៉ាន់ណារ៉ា** អគ្គលេខាធិការ នៃគណៈកម្មាធិការដឹកនាំការងារកម្មវិធីសិលា ដែលបានចំណាយពេលវេលា និងការផ្តល់នូវសេចក្តីណែនាំដល់ឯកឧត្តមអភិបាលខេត្តតាកែវ ពោធិសាត់ កំពង់ស្ពឺ កំពង់ឆ្នាំង បាត់ដំបង និងកំពង់ចាម ដែលបានចំណាយពេល និងផ្តល់នូវការគាំទ្រដោយលោក **ស្កត់ ឡេបរតឺរ** អ្នកស្រី **ចុអាន ម៉ូរីសុន** លោក **ម៉ុហាមេដ អេលមិនស៊ី** និងមន្ត្រីជាន់ខ្ពស់ **PLG** ប្រចាំខេត្ត និងបុគ្គលិកទាំងអស់ ដែលបានជួយរៀបចំកាលវិភាគ និងឆ្លើយសំណួរ ។ យើងក៏សូមថ្លែង អំណរគុណផងដែរដល់មន្ត្រីគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត និងគណៈកម្មាធិការប្រតិបត្តិខេត្ត (PRDC/Excom) ដែលបានអនុញ្ញាតិអោយយើងធ្វើសម្ភាសន៍ និងសូមថ្លែងអំណរគុណដល់មន្ត្រី ថ្នាក់ឃុំ-សង្កាត់ ថ្នាក់ស្រុក និងខេត្ត ដែលគួរអោយពេញចិត្ត ដែលបានស្ម័គ្រចិត្តបំពេញបញ្ជីសំណួរដ៏វែងរបស់យើង ហើយជួនកាលទោះជាមិនមានភាពងាយស្រួល និងមានការលំបាកក្នុងការមើលក៏ដោយ។ នៅទីបញ្ចប់ យើងសូមថ្លែងអំណរគុណដល់សហគមន៍ ដែលយើងបានធ្វើការសម្ភាសន៍ ជាក្រុមពិភាក្សា និងជាលក្ខណៈបុគ្គល ចំពោះការអត់ធ្មត់ កិត្តិយស និងសេចក្តីឈ្លាសវៃរបស់ពួកគេ និងបានចំណាយពេលវេលាដ៏មានតំលៃ ដែលបានចូលរួមក្នុងក្រុមពិភាក្សារបស់យើង ។

III-**លទ្ធផលសំខាន់**

***ក-និយមន័យ នៃអភិបាលកិច្ចនៅក្នុងបរិបទ របស់មន្ត្រីកម្ពុជា (ប្រការ១)***

ការពិនិត្យឡើងវិញ នូវប្រភពបន្ទាប់បន្សំ នឹងបកស្រាយអំពីភាពស្មុគស្មាញ របស់និយមន័យសំដៅចំពោះអភិបាលកិច្ច ក្នុងប្រព័ន្ធនយោបាយ និងសេដ្ឋកិច្ចផ្សេងៗគ្នា ។ ចំពោះប្រទេសកម្ពុជា ការធ្វើអង្កេតត្រូវបានសំរេចដើម្បីប្រើប្រាស់និយមន័យ ដែលធនាគារពិភពលោកពេញចិត្តនោះមានន័យថា "អភិបាលកិច្ចជាលក្ខណៈដែលអំណាចត្រូវបានប្រើប្រាស់ ក្នុងការគ្រប់គ្រងធនធានសេដ្ឋកិច្ច និងសង្គមរបស់ប្រទេសសំរាប់ការអភិវឌ្ឍន៍" ។ នៅក្នុងអត្ថន័យដ៏ទូលំទូលាយ អភិបាលកិច្ច គឺនិយាយអំពីបរិយាកាសស្ថាប័នដែលប្រជាពលរដ្ឋ មានទំនាក់ទំនងក្នុងចំណោមពួកគេ និងជាមួយភ្នាក់ងារ និងមន្ត្រីរដ្ឋាភិបាល (ADB ២០០១) ។ អភិបាលកិច្ចក៏រាប់បញ្ចូលផងដែរ នូវរបៀបដែលរដ្ឋាភិបាលបំពេញនូវការទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋ សង្គមស៊ីវិល និងផ្នែកឯកជនដោយផ្ទាល់ ។ អត្ថន័យផ្ទុយរបស់អភិបាលកិច្ចក៏សំខាន់ផងដែរ គឺជារបៀបដែលរដ្ឋាភិបាលតម្រូវអោយ ប្រជាពលរដ្ឋ និងផ្នែកឯកជន បំពេញនូវការទទួលខុសត្រូវចំពោះមុខសាធារណៈជន និងរបៀបដែលរដ្ឋាភិបាល ទទួលខុសត្រូវចំពោះនយោបាយ និងការងាររបស់ខ្លួន (DFID ២០០០) ។

***ធនាគារពិភពលោក ពោលនូវកត្តាមូលដ្ឋានសំខាន់ ៤ នៃអភិបាលកិច្ច គឺ :***

***១. គណនេយ្យភាព (បង្កើតអោយមានការទទួលខុសត្រូវ ចំពោះសកម្មភាពការងារ)***

-ការគ្រប់គ្រងសេវាសាធារណៈ

-ការគ្រប់គ្រង និងការកែទំរង់សហគ្រាសសាធារណៈ

-ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

-កែទំរង់រដ្ឋបាលស៊ីវិល

***២. ការចូលរួម (ដំណើរការអភិវឌ្ឍន៍ដោយមានការចូលរួម)***

-ការចូលរួមរបស់អ្នកទទួលផល និងក្រុមដែលទទួលរងនូវឥទ្ធិពល

-ការប្រឈមមុខគ្នារវាង សេវាសាធារណៈ និងសេវាឯកជន

-ធ្វើវិមជ្ឈការនៃដំណើរការសាធារណៈ និងដំណើរការផ្តល់សេវា (ការផ្តល់អំណាចដល់រដ្ឋាភិបាលមូលដ្ឋាន)

-សហប្រតិបត្តិការ ជាមួយសង្គមស៊ីវិល

***៣. ការព្យាករណ៍ទុកជាមុន (ក្របខ័ណ្ឌស្របច្បាប់)***

-ច្បាប់និងការអភិវឌ្ឍន៍

-ក្របខ័ណ្ឌស្របច្បាប់សំរាប់ការអភិវឌ្ឍន៍សេវាសាធារណៈ និងឯកជន

*៤. តម្លាភាព (ភាពចំហរ នៃពត៌មាន)*

-ការដឹងអំពីពត៌មាន

***ខ-និយមន័យ នៃបទដ្ឋានពាក់ព័ន្ធ សំរាប់ការអនុវត្តន៍អភិបាលកិច្ចល្អ (ប្រការ ២)***

ម្តងទៀត ការពិនិត្យឡើងវិញ នូវប្រភពបន្ទាប់បន្សំ បង្ហាញអំពីវិសាលគមនៃទស្សនៈ ស្តីពីបទដ្ឋាននៃអភិបាលកិច្ចរបស់រាជរដ្ឋាភិបាល ការអង្កេត នៅ ឆ្នាំ ២០០១ និង ឆ្នាំ ២០០៤ បានជ្រើសរើស ពីនិយមន័យនៃបទដ្ឋាន DFID :

(១) ដំណើរការយន្តការនយោបាយ និងផ្លូវការ ដែលផ្តល់ឱកាសដល់ប្រជាពលរដ្ឋទាំងអស់ រួមទាំង ស្ត្រី ចាស់ជរា ជនពិការ អ្នកក្រ និងជនងាយទទួលរងគ្រោះ ដើម្បីរៀបចំ និងមានឥទ្ធិពលលើនយោបាយ និងការអនុវត្តន៍ជាផ្លូវការ ។

(២) ធ្វើអោយមានស្ថិរភាពសេដ្ឋកិច្ច និងសំរួលការធ្វើវិនិយោគផ្នែកឯកជន និងពាណិជ្ជកម្ម ក្នុងគោលបំណង ជំរុញអោយមានការរីកចំរើន ដែលចាំបាច់ សំរាប់កាត់បន្ថយភាពក្រីក្រ ។

(៣) អភិវឌ្ឍន៍ក្របខ័ណ្ឌ នយោបាយ ដែលអាចពង្រឹងគោលដៅលុបបំបាត់ភាពក្រីក្រ និងបង្កើនលៃលកទុក និងចុះបញ្ជី ធនធាន អោយស្របគ្នាទៅនឹងគោលនយោបាយជួយជ្រោមជ្រែង ជនក្រីក្រ ។

(៤) ធានារ៉ាប់រងចំពោះការផ្តល់ប្រកបដោយសមធម៌ និងជាសកល នូវសេវាជាមូលដ្ឋាន និងមានប្រសិទ្ធិភាព ។

(៥) ធានាសុវត្ថិភាព និងសន្តិសុខដោយផ្ទាល់ ប្រកបដោយយុត្តិធម៌ សំរាប់ពលរដ្ឋទាំងអស់ ។

(៦) ចាត់ចែងសន្តិសុខជាតិប្រកបដោយការទទួលខុសត្រូវ និងដោះស្រាយនូវភាពខ្វែងគំនិតគ្នា រវាងសហគមន៍ មុនពេលភាពខ្វែងគំនិត ក្លាយជាជំលោះដ៏ឃោរឃៅ ។

(៧) បង្កើតរដ្ឋាភិបាលដែលស្មោះត្រង់ និងទទួលខុសត្រូវ ដែលអាច ប្រយុទ្ធនឹងអំពើពុករលួយ ។

***<u>បទដ្ឋាន១</u>***: ដំណើរការយន្តការនយោបាយ និងផ្លូវការ ដែលផ្តល់ឱកាសដល់ប្រជាពលរដ្ឋទាំងអស់ រួមទាំងស្ត្រី ចាស់ជរា ជនពិការ អ្នកក្រ និងជនងាយទទួលរងគ្រោះ ដើម្បីរៀបចំ និងមានឥទ្ធិពល លើនយោបាយ និងការអនុវត្តន៍ជាផ្លូវការ ។

ប្រៀបធៀបឥរិយាបថ និងការអនុវត្តន៍ ដែលមាននៅក្នុងការធ្វើអង្កេតឆ្នាំ ២០០១ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់នៅខែកុម្ភៈ ឆ្នាំ ២០០២ ហាក់ដូចជាបានបង្កើតនូវបរិយាកាសថ្មីមួយ សំរាប់អភិបាលកិច្ច និង

ការចាប់ផ្តើមចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការអភិវឌ្ឍន៍ លក្ខណៈពិសេសថ្មីមួយ នៃប្រវត្តិសាស្ត្រកម្ពុជា ។ ស្មារតីទទួលខុសត្រូវដោយខ្លួនឯង បានលេចឡើងនៅក្នុងចំណោមក្រុមប្រឹក្សាឃុំ-សង្កាត់ និងក្នុងចំណោមប្រជាពលរដ្ឋជាច្រើន ។ មានការជំរុញអោយមានការចូលរួម ដូចដែលបានឃើញនៅក្នុងការអនុម័តដ៏មានប្រជាប្រិយភាព នូវផែនការអភិវឌ្ឍន៍ឃុំ ។ ផែនការ និងថវិកាទាំងនេះ ត្រូវបានពិភាក្សាដ៏យូរអង្វែង និងដោយចំហរនៅក្នុងក្រុមប្រឹក្សា ។ ថវិកាអភិវឌ្ឍន៍មិនអាចយកទៅប្រើប្រាស់ ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនឡើយ ។ ទោះជាធ្វើយ៉ាងដូច្នេះក៏ដោយ ក៏វាមិនអាចកាត់បន្ថយនូវភាពក្រីក្រទាំងស្រុងបានដែរ ។ ការអនុវត្តន៍ការចូលរួម គឺធ្វើឡើង ជាការសាកល្បង ហើយមិនទាន់បានចាក់គ្រឹះនៅឡើយទេ ។ មន្ត្រីនៅតែមានជំនឿថា (៨៣%) និយមន័យ នៃការចូលរួមនៅក្នុងអភិបាលកិច្ចគឺថា មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល គួរធ្វើការសំរេចនូវគោលនយោបាយដើម្បីជាប្រយោជន៍ របស់ប្រជាពលរដ្ឋ ។ មន្ត្រី ៩១% មានជំនឿថា បុរសមានអាយុលើសពី ១៨ឆ្នាំ ហើយនិង ៨២% ស្ត្រីមិនទាន់រៀបការមានអាយុលើស ១៨ឆ្នាំ គួរតែមានសំលេងនៅក្នុងការងាររបស់រដ្ឋាភិបាល ។ មន្ត្រី ៦៨% មានជំនឿថា ស្ត្រីរៀបការហើយ ហើយនិង ៥៩% មនុស្សវ័យចំណាស់ និង ៤៦% ជនពិការ គួរតែមានសំលេងក្នុងរដ្ឋាភិបាលដែរ ។ ដូច្នោះហើយ ឱកាសសំរាប់ជនក្រីក្រ និងជនងាយរងគ្រោះ ដើម្បីរៀបចំ និងមានឥទ្ធិពលទៅលើនយោបាយ និងការអនុវត្តន៍ជាផ្លូវការ គឺនៅមានកំរិតនៅឡើយ ។

ការនិយាយបែបនេះ ព្រឹត្តិការណ៍ពិតដែលបានកើតឡើងនៅក្នុងឃុំ-សង្កាត់ ក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ២០០៤ គឺថា ពួកគេភាគច្រើន បានចូលរួមនៅក្នុងការប្រជុំជាសាធារណៈ ដោយមានកំរិតខ្សោយទាត់ និងកំរិតនៃការចូលរួមផ្សេងៗគ្នា ដែលការផ្លាស់ប្តូរទស្សនៈពីរបៀប ត្រូវបានលើកទឹកចិត្ត ។ ប៉ុន្តែការប្រជុំរបៀបនេះ មិនត្រូវបានរៀបចំធ្វើមុនពេលការបោះឆ្នោតឆ្នាំ ២០០២ នោះទេ ។

ការធ្វើអង្កេត នឹងត្រូវធ្វើការសន្និដ្ឋានថា មន្ត្រីបានបំពេញតាមបទដ្ឋានទាំងឡាយ ដែលមាននៅក្នុងបទដ្ឋាន១១។

***<u>បទដ្ឋាន១២.</u>*** ធ្វើអោយមានស្ថេរភាពសេដ្ឋកិច្ច និង សំរួលដល់ការធ្វើវិនិយោគ និង អាជីវកម្មផ្នែកឯកជន ដើម្បីជំរុញកំណើនសេដ្ឋកិច្ចដែលចាំបាច់សំរាប់កាត់បន្ថយភាពក្រីក្រ ។ អ្នកផ្តល់ពត៌មានសំខាន់ យល់ច្បាស់ថា មន្ត្រីក្រៅក្រសួងពាណិជ្ជកម្មនៅទីក្រុងភ្នំពេញ មិនមានអំណាច ដើម្បីលើកកំពស់នូវសេដ្ឋកិច្ច ឬពាណិជ្ជកម្មទេ ។ មន្ត្រីថ្នាក់ខេត្ត ស្រុក និងឃុំ មិនត្រូវបានគេផ្តល់ភារកិច្ចអោយធ្វើកិច្ចការនេះទេ ។ មន្ត្រី ៦៦% មានជំនឿថា រដ្ឋាភិបាលកំពុងធ្វើកិច្ចការគ្រប់គ្រាន់ ដើម្បីពង្រឹងសេដ្ឋកិច្ច ហើយមន្ត្រី ៤១% ជឿជាក់ថា មន្ត្រីរដ្ឋាភិបាលកំពុងធ្វើកិច្ចការគ្រប់គ្រាន់

ដើម្បីជួយសំរួលដល់ការប្រកបអាជីវកម្មខ្នាតតូច ។ អ្នកផ្តល់ពត៌មាន (Qualitative) ដែលជាអាជីវករនោះ មិនបានពឹងផ្អែកលើជំនួយណាមួយរបស់មន្ត្រីឡើយ ហើយពួកគេពឹងថា អំពើពុករលួយផ្លូវការមានលក្ខណៈជាការដាក់ប៉ុស្តិ៍ត្រួតពិនិត្យខុសច្បាប់ ការទារពន្ធ និងភាស៊ីខុសច្បាប់ នឹងមិនអាចឈានដល់ចំណុចមួយ ដែលមិនមានតំលៃប្រកបអាជីវកម្ម ។ ចំណុចតូចបំផុតស្តីពីការប្រកបអាជីវកម្ម កសិករ នៅក្នុងឃុំមួយចំនួនអះអាងថា តើពួកគេចិញ្ចឹមសត្វពាហនៈបានប្រយោជន៍អ្វី បើក្រុមជនអន្ធពាល សេពគប់ជាមួយប៉ូលីស លួចសត្វពាហនៈរបស់ពួកគេ ហើយប៉ូលីសមិនបានព្យាយាមចាប់ចោរលួចនោះបានផង ។បើអ្នកភូមិចាប់ចោរប្លន់បាន ដោយខ្លួនគេ ប៉ូលីស ឬក៏ចៅក្រមដោះលែងចោរប្លន់អោយរួចខ្លួន ។ ជាការពិតណាស់មានសេចក្តីត្រូវការជាខ្លាំង អោយរដ្ឋាភិបាល ប្រគល់ភារកិច្ចដល់មន្ត្រី ដើម្បីជួយពង្រឹងសេដ្ឋកិច្ច និងប្រឹងប្រែងស្របពេលជាមួយគ្នា ដើម្បីទប់ស្កាត់អំពើពុករលួយផ្លូវការ ។

មន្ត្រីមិនអាចបំពេញនូវបទដ្ឋាន២ នេះបានទេ ។

***បទដ្ឋាន៣*** : បង្កើតក្របខណ្ឌគោលនយោបាយ ដែលអាចជំរុញនូវទិសដៅកាត់បន្ថយភាពក្រីក្រ ប្រមែប្រមូល និងចាត់ចែងធនធាន អោយស្របទៅតាមគោលនយោបាយ ជួយជ្រោមជ្រែងជនក្រីក្រទាំងនោះ ។

នេះជាការងារដែលកំពុងធ្វើ ។ ចំណែកឯនៅថ្នាក់នយោបាយវិញ មន្ត្រីនៅទីក្រុងភ្នំពេញកំពុងតែធ្វើច្បាប់រៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ដែលនឹងបង្កើតអោយមាននូវប្រព័ន្ធសហវិមជ្ឈការ និងកំណត់ដែនទទួលខុសត្រូវក្នុងការផ្តល់សេវានានា ប្រមែប្រមូលធនធាននៅថ្នាក់មូលដ្ឋាន និងបង្កើតក្របខណ្ឌគោលនយោបាយមួយ ដែលអាចលើកកំពស់គោលនយោបាយទាំងឡាយ ដើម្បីជួយដល់ជនក្រីក្រ ។ ប៉ុន្តែសេចក្តីព្រាងនៃច្បាប់នេះ តំរូវអោយមានការផ្តួចផ្តើមគំនិត និងឯកភាពស្មើតែគ្រប់ក្រសួងជាតិទាំងអស់ ហើយវានឹងពិបាកនឹងសំរេចបាន បើគ្មានសេចក្តីណែនាំពីថ្នាក់នយោបាយជាន់ខ្ពស់នោះទេ ។ អ្នកផ្តល់ពត៌មានសំខាន់ បានប្រាប់ក្រុមអង្កេតថា សេចក្តីព្រាងច្បាប់នេះ នឹងត្រូវចំណាយពេល ១ ឬ ២ឆ្នាំ មុនពេលវាទៅដល់សភា ។

ក្នុងខណៈនេះ ថ្នាក់មូលដ្ឋានដូចជាក្រុមប្រឹក្សាឃុំ-សង្កាត់ កំពុងជួបប្រទះនូវការលំបាក ក្នុងការស្វែងរកធនធានសំរាប់ការចំណាយរបស់ពួកគេ ដូច្នេះ តើពួកគេមានធនធានឯណា ដើម្បីប្រើប្រាស់ក្នុងការផ្តល់សេវានានាដល់សហគមន៍របស់ពួកគេ ។

តាមរយៈដៃគូរអភិវឌ្ឍន៍ ពួកគេប្រមែប្រមូលថវិកា ដែលពួកគេអាចប្រមែប្រមូលបានដោយស្របច្បាប់ មុនពេលពួកគេត្រូវបានប្រគល់អំណាចអោយប្រមែប្រមូលពន្ធដោយខ្លួនឯងនោះ ហើយពួកគេកំពុងតែប្រឹងប្រែងអនុវត្តន៍នូវគំរោងអភិវឌ្ឍន៍ ដែលបានឯកភាពនៅក្នុងសហគមន៍របស់ពួកគេ ។ គំរោងមួយចំនួន នៅក្នុងចំណោម

គំរោងទាំងនេះ មានដូចជា ការស្ថាបនាផ្លូវ និងប្រព័ន្ធធារាសាស្ត្រ អាចជួយកាត់បន្ថយភាពក្រីក្រ ហើយកសិករដែលក្រុមអង្កេតរបស់យើងមានទំនាក់ទំនងជាមួយនោះ មានការត្រេកអរចំពោះគំរោងទាំងអស់នេះណាស់ ។ ប៉ុន្តែគ្មានការចំរើនជឿនលឿនទៅមុខខ្លាំងទេ នៅពេលដែលក្រសួងទាំងឡាយប្រយុទ្ធប្រឆាំងទៅនឹងសង្គ្រាមដីធ្លី មិនចេះចប់មិនចេះហើយនៅទីក្រុងភ្នំពេញ ហើយនៅពេលដែលអ្នកនយោបាយភ្ជាប់ខ្លួនរបស់ពួកគេជាមួយនឹងបញ្ហាផ្សេងទៀត ។ អភិបាលខេត្តទាំងឡាយ មិនអាចជួយបាន ពីព្រោះពួកគេមិនអាចគ្រប់គ្រងទាំងស្រុង ទៅលើមន្ទីរទាំងឡាយ ទៅតាមរដ្ឋធម្មនុញ្ញពហុបក្ស ឆ្នាំ ១៩៩៣ នេះទេ ។

មន្ត្រីមិនអាចបំពេញនូវស្តង់ដារ៣ នេះទេ ទោះបីពួកគេភាគច្រើន ដឹងអំពីគំរូការ ដែលពួកគេត្រូវធ្វើបែបនេះក៏ដោយ ។

__បទដ្ឋាន៤__: ធានានូវការផ្តល់ប្រកបដោយសមភាព និងសកល នូវសេវាមូលដ្ឋានដ៏មានប្រសិទ្ធិភាពទាំងឡាយ ។ នេះ គឺអាស្រ័យទៅលើការសំរេចបានជោគជ័យ នៃក្របខណ្ឌគោលនយោបាយដែលបានពោលនៅក្នុងបទដ្ឋាន ៣ ។ និយាយបែបនេះ គឺមានការខិតខំប្រឹងប្រែងដែលគួរអោយស្ញប់ស្ញែងខ្លះ ក្នុងការផ្តល់សេវាអប់រំ និងសុខភាពមូលដ្ឋាន ការស្ថាបនាផ្លូវ ប៉ុន្តែការខិតខំប្រឹងប្រែងទាំងនេះ ប្រឈមមុខទៅនឹងឧបសគ្គជាច្រើន រួមមានអំពើពុករលួយផ្លូវការ ។

មន្ត្រីមិនបានបំពេញបទដ្ឋាន ៤ នោះទេ ។

__បទដ្ឋាន៥__: ធានាអោយមានសុវត្ថិភាព និងសន្តិសុខផ្ទាល់ ប្រកបដោយយុត្តិធម៌សំរាប់ប្រជាពលរដ្ឋគ្រប់រូប ។

មន្ត្រី ៨៥% មានជំនឿថា ប្រជាពលរដ្ឋត្រូវបានគេអនុញ្ញាតអោយបញ្ចេញទស្សនៈជាសាធារណៈ ទោះបីជាពួកគេរិះគន់ដល់រដ្ឋាភិបាលក៏ដោយ ហើយមន្ត្រី ៨៤% មានជំនឿថា ច្បាប់ទាំងអស់នៅក្នុងប្រទេសកម្ពុជាត្រូវបានគេគោរព និងអនុវត្តតាមយ៉ាងខ្ជាប់ខ្ជួន ហើយមន្ត្រី ៨៨% មានជំនឿថា រដ្ឋាភិបាលអាចធ្វើកិច្ចការបន្ថែមទៀត ដើម្បីធ្វើអោយប្រជាពលរដ្ឋមានសុវត្ថិភាព និងសន្តិសុខ ។

តាមទស្សនៈប្រជាពលរដ្ឋ ដែលមិនមែនជាមន្ត្រីរាជការ ដែលក្រុមអង្កេតបានសំភាសន៍ បាននិយាយថា នេះគឺជាការព្រួយបារម្ភខ្លាំងបំផុតទី២ របស់ពួកគេបន្ទាប់ពីភាពក្រីក្រ ។ ប្រជាពលរដ្ឋជាច្រើនមានជំនឿថា ការខ្វះនូវសន្តិសុខផ្ទាល់ខ្លួន គឺបណ្តាលអោយទទួលរងនូវភាពក្រីក្រ ។ ពួកគេបានលើកយកប្រព័ន្ធសន្តិសុខ និងយុត្តិធម៌សំរាប់ធ្វើជាចំណុចរិះគន់ដ៏ខ្លាំងបំផុតរបស់ពួកគេ ។ ពួកគេមិនមានទំនុកចិត្តចំពោះប៉ូលីស មិនមានទំនុកចិត្តចំពោះតុលាការដែលមិនបានផ្តល់យុត្តិធម៌ដល់អ្នកក្រ ឬនណាម្នាក់ដែលគ្មានលុយអោយពួកគេនោះទេ ។

គ្មានទំនុកចិត្តទាំងស្រុងចំពោះប្រព័ន្ធសន្តិសុខ និងយុត្តិធម៌ និងការបោះទីតាំងយោធានៅជិតទីកន្លែងរស់នៅរបស់ប្រជាពលរដ្ឋ ត្រូវចាត់ទុកជាឧបសគ្គដ៏ធ្ងន់ធ្ងរមួយចំពោះទីកន្លែងរបស់ពួកគេ ។ កងទ័ពត្រូវបានគេមើលឃើញថា ជាអ្នកទន្ទ្រានយកដី និងប្រើកំលាំងរំលោភបំពានទៅលើប្រជាពលរដ្ឋ ។ នៅក្នុងបញ្ហានេះ យើងបានលឺថា មានកំណត់សំគាល់វិជ្ជមានមួយ គឺប្រជាពលរដ្ឋមានការគោរព ចំពោះយន្តការដោះស្រាយបញ្ហា វិវាទរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។ ក្រុមអង្កេតមិនអាចធ្វើការអធិប្បាយក្បោះក្បាយអំពីយន្តការទាំងនេះឡើយ ពីព្រោះយន្តការទាំងនេះ ត្រូវបានគេមើលឃើញថា ជាជំរើសទាំងឡាយរបស់ប៉ូលីស ឬក៏តុលាការ ។

មន្ត្រីមិនបានបំពេញនូវបទដ្ឋាន ៥ នេះទេ ។

***បទដ្ឋាន៦*** : គ្រប់គ្រងសន្តិសុខជាតិ ប្រកបដោយស្មារតីទទួលខុសត្រូវ និងដោះស្រាយវិវាទនៅក្នុងសហគមន៍មុនពេលវិវាទទាំងនេះក្លាយទៅជាអំពើឃោរឃៅមួយ ។

បទដ្ឋាននេះ គឺហួសពីទំហំការងាររបស់ក្រុមអង្កេត ។

***បទដ្ឋាន៧*** : បង្កើតរដ្ឋាភិបាលដែលមានភក្តីភាព និងមានការទទួលខុសត្រូវ ដែលអាចប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។

មន្ត្រី ៥៨% ជឿជាក់ថា នៅក្នុងប្រទេសកម្ពុជា ការបង់ថវិកាក្រៅផ្លូវការ គឺជាមធ្យោបាយសាមញ្ញដើម្បីអោយគេធ្វើអ្វីមួយអោយបាន ។

ហើយមន្ត្រី ៥០% ជឿជាក់ថា អ្នកម៉ៅការ ត្រូវតែបង់ថវិកា ដើម្បីអោយគេផ្តល់កិច្ចសន្យាអោយ ហើយមន្ត្រី ៥៣% មានជំនឿថា វាជាការសមហេតុ សមផលណាស់ សំរាប់មន្ត្រីរដ្ឋាភិបាលដែលមានប្រាក់បៀវត្សតិចតួច ទទួលយកនូវកំរៃជើងសារ ។ ទោះជាយ៉ាងណាក៏ដោយ ក៏មន្ត្រី ៨១% មិនមានជំនឿថា ការជ្រើសរើសយកអ្នកម៉ៅការណាម្នាក់ ដោយសារតែពួកគេមានទំនាក់ទំនងជាមួយនឹងមន្ត្រីមានអំណាចនោះទេ ។

ចំណែកឯប្រជាពលរដ្ឋដែលមិនមែនជាមន្ត្រីរាជការវិញ បាននិយាយថា អំពើពុករលួយបានក្លាយទៅជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃទៅហើយ ។ ពួកគេមិនពេញចិត្តនឹងអំពើពុករលួយនោះទេ ប៉ុន្តែពួកគេបានយល់ឃើញថា វាជាការដែលមិនអាចជៀសវាងបាន ។ ពួកគេដឹងថា ពួកគេគ្មានអំណាចទាល់តែសោះ ក្នុងការដោះស្រាយនូវអំពើពុករលួយនេះ ។ ពួកគេក៏បានយល់ខ្លាំងណាស់ដែរ អំពីអំពើពុករលួយនេះ ។ ពួកគេយល់ថា មន្ត្រីទទួលបានប្រាក់បៀវត្សទាប ហើយត្រូវរកមធ្យោបាយដើម្បីរកប្រាក់បៀវត្សសំរាប់ចិញ្ចឹមជីវិត ។ ទោះបីជាក្លាយទៅជា បញ្ហាធម្មតាទៅហើយ

ក៏ពួកគេនៅតែគិតថា អំពើពុករលួយ គឺជារឿងខុសច្បាប់ ។ ចំពោះការចំណាយលុយក្រោមតុតិចតួច ជារៀងរាល់ថ្ងៃ ដល់មន្ត្រីដែលធ្វើការងារអ្វីមួយអោយប្រជាពលរដ្ឋដូចជា ចេញប័ណ្ណស្នាក់នៅ ឬសំបុត្រកំណើត ពួកគេមិនដឹងថា ហេតុអ្វីបានជារដ្ឋាភិបាលមិនអាចបិទប្រកាសនូវតំលៃជាក់លាក់ ហើយមិនអនុញ្ញាតអោយមន្ត្រីគិតថ្លៃបន្ថែម ។ ការអនុគ្រោះនឹងត្រូវផ្តល់ដល់អ្នកក្រីក្រ ។ អ្នកផ្តល់ពត៌មានជាច្រើនបាននិយាយថា ពួកគេនឹងមានសេចក្តីរីករាយ បើថ្លៃសេវាទាំងនេះ ត្រូវបានប្រមូល ហើយបែងចែកសំរាប់មន្ត្រីពាក់ព័ន្ធ ដើម្បីបន្ថែមទៅលើប្រាក់បៀវត្សរបស់ពួកគេ ដូចជាហិរញ្ញប្រទាន ត្រូវបានបែងចែកសំរាប់បុគ្គលិកសុខាភិបាល ។ ទាក់ទងទៅនឹងអំពើពុករលួយដ៏ធ្ងន់ធ្ងរ ដែលនាំអោយគ្មានអំពើយុត្តិធម៌ ឬក៏ប្រើប្រាស់ច្បាប់ ដើម្បីផលប្រយោជន៏របស់ពួកគេ អ្នកផ្តល់ពត៌មាន (Qaulitative) មិនបានផ្តល់ជាគំនិតនោះឡើយ ពួកគេនិយាយថា ពួកគេគ្មានអំណាចអ្វី ដែលត្រូវដោះស្រាយអំពើពុករលួយនេះទេ ។

មន្ត្រីមិនបានបំពេញនូវបទដ្ឋាន ៧ នេះទេ ។

## *គ-ការធ្វើអង្កេតបន្តឆ្នាំ ២០០៤ (ខេត្តទាំងអស់ ត្រូវបានធ្វើការពិចារណារួម) (ប្រការ៣)*

### *លក្ខណៈ នៃប្រជាពលរដ្ឋដែលបានធ្វើអង្កេត*

មន្ត្រីសរុបចំនួន ១៩៩៨នាក់ ត្រូវបានធ្វើអង្កេតនៅឆ្នាំ ២០០៤ ក្នុងនោះមានបុរស ១៦៧៥នាក់ ស្ត្រី ៣២៣នាក់ (តារាងទី១) ។ ក្នុងចំនួនទាំងនេះ ១៦% មានអាយុក្រោម ៣៤ឆ្នាំ ហើយ ៧៩% មានអាយុចន្លោះ ៣៤ ទៅ ៦៤ឆ្នាំ ។ ៥% មានអាយុលើសពី ៦៥ឆ្នាំ (តារាងទី២) ។ អ្នកផ្តល់ពត៌មានចំនួន ៣៨%បានបញ្ចប់បឋមសិក្សា ហើយ ២៦% បានបញ្ចប់អនុវិទ្យាល័យ និង ២៧%ទៀត បានបញ្ចប់វិទ្យាល័យ ។ ៥% ដែលបានសិក្សានៅសកលវិទ្យាល័យ គឺជាស្មៀនឃុំ-សង្កាត់ ឬមន្ត្រីថ្នាក់ជាតិនៅទីក្រុងភ្នំពេញ និងមន្ត្រី Seila Focal Points (តារាងទី៣) ។ មន្ត្រី ៣៩% មិនបានទទួលនូវការបណ្តុះបណ្តាលជំនាញបច្ចេកទេស វិជ្ជាជីវៈបន្ថែមទេ តែមន្ត្រី ៦០% បានទទួលនូវការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈផ្សេងៗគ្នា (តារាងទី៤) ។ អ្នកផ្តល់ពត៌មានភាគច្រើន ៥៩% ត្រូវបានបោះឆ្នោតជាក្រុមប្រឹក្សាឃុំ-សង្កាត់ ១៩% ជាស្មៀនឃុំ-សង្កាត់ ដែលបានតែងតាំង ២% ជាមន្ត្រីថ្នាក់ជាតិដែលបានតែងតាំង ៦% មន្ត្រីថ្នាក់ខេត្ត និង ១៣% មន្ត្រីថ្នាក់ស្រុក (តារាងទី៥) ។

៣៧% បំរើការងារនៅក្នុងជួររដ្ឋាភិបាល ចាប់ពី ២-៥ឆ្នាំ ៦២% បានបំរើការងារយូរជាងនេះ ។ ៣៦% បានបំរើការងារនៅក្នុងរដ្ឋាភិបាល ក្នុងសម័យនៃការិយាធិបតេយ្យ តាមរបៀបប្រទេសវៀតណាម (តារាងទី៦) ។ ពួកគេហាក់ដូចជាមិនមែនជាក្រុមដែលមានទ្រព្យសម្បត្តិច្រើនណាស់ណាទេ ។ ៨% មិនមានផ្ទះផ្ទាល់ខ្លួន ហើយ ៨៨% មានផ្ទះផ្ទាល់ខ្លួនមួយ (តារាងទី៨) ។ ១៥% គ្មានដីផ្ទាល់ខ្លួន ហើយ ២០%ទៀតមានដីផ្ទាល់ខ្លួនតិចតួច។ ៦៥% មានដីទំហំផ្សេងៗគ្នាពីតូចទៅធំ ប្រហែល ៤២% មានដីលើសពី ១ហិចតា (១០.០០០ម²) ។ មន្ត្រីជាង ៨៥% បានទទួលនូវការបណ្ដុះបណ្ដាលស្ដីពីអភិបាលកិច្ច (តារាងទី១០) ដែលក្នុងនោះ ៧៤% បានទទួលនូវការបណ្ដុះបណ្ដាល ២ឆ្នាំ កន្លងទៅហើយ (តារាងទី១១) ៩២% បានទទួលនូវការបណ្ដុះបណ្ដាលដែលផ្ដល់ដោយរដ្ឋាភិបាល (តារាងទី១២) ។ ទោះបីជាយ៉ាងណាក៏ដោយ ៥៦% បាននិយាយថា ពួកគេមិនទាន់បានទទួលនូវការបណ្ដុះបណ្ដាលគ្រប់គ្រាន់ ដើម្បីធ្វើការងារបច្ចុប្បន្នរបស់ពួកគេអោយបានល្អនោះទេ (តារាងទី១៣) ។

| **លេខសំនួរ** | ចំនួនអ្នកឆ្លើយ ១៩៩៨ |
|---|---|

**9-ភេទ**

| | ចំនួន | ភាគរយ |
|---|---|---|
| ប្រុស | 1675 | 83.8 |
| ស្រី | 323 | 16.2 |
| សរុប | 1998 | 100 |

**10-អាយុ**

| | ចំនួន | ភាគរយ |
|---|---|---|
| 18-24 | 118 | 5.9 |
| 25-34 | 197 | 9.9 |
| 35-44 | 350 | 17.5 |
| 45-54 | 747 | 37.4 |
| 55-64 | 480 | 24 |
| >65 | 100 | 5 |
| គ្មានចំលើយ | 6 | 0.3 |
| សរុប | 1998 | 100 |

**11- កំរិតវប្បធម៌**

| | ចំនួន | ភាគរយ |
|---|---|---|
| បឋមសិក្សា | 757 | 37.9 |
| អនុវិទ្យាល័យ | 526 | 26.3 |
| វិទ្យាល័យ | 543 | 27.2 |
| មធ្យមសិក្សាបច្ចេកទេស | 72 | 3.6 |
| ឧត្តមសិក្សា | 79 | 4 |

| លេខសំនួរ | ចំនួនអ្នកឆ្លើយ ១៩៩៨ |
|---|---|

| | | |
|---|---|---|
| អនុបណ្ឌិត / បណ្ឌិត | 17 | 0.9 |
| គ្មានចំលើយ | 4 | 0.2 |
| សរុប | 1998 | 100 |

**12- តើធ្លាប់ឆ្លងកាត់វគ្គបណ្តុះបណ្តាល មុខវិជ្ជាជីវៈជំនាញបច្ចេកទេសអស់រយៈពេលប៉ុន្មាន ?**

| | ចំនួន | ភាគរយ |
|---|---|---|
| 1-29 ថ្ងៃ | 245 | 12.3 |
| 1-4 ខែ | 562 | 28.1 |
| 5-11 ខែ | 106 | 5.3 |
| 1-3 ឆ្នាំ | 250 | 12.5 |
| 4-8 ឆ្នាំ | 54 | 2.7 |
| >9 ឆ្នាំ | 6 | 0.3 |
| មិនដែលរៀន | 775 | 38.8 |
| គ្មានចំលើយ | 1998 | 100 |

**13- តើ លោក លោកស្រី បំរើការងារនៅក្នុងជួររដ្ឋាភិបាលនេះថ្នាក់អ្វីដែរ ?**

| | ចំនួន | ភាគរយ |
|---|---|---|
| ថ្នាក់ជាតិ | 35 | 1.8 |
| ថ្នាក់ខេត្ត | 110 | 5.5 |
| ថ្នាក់ស្រុក | 268 | 13.4 |
| ថ្នាក់ឃុំ : ក្រុមប្រឹក្សាឃុំ/សង្កាត់ដែលទើបតែត្រូវបានបោះឆ្នោតជ្រើសរើស | 1186 | 59.4 |
| ថ្នាក់ឃុំ : ស្មៀនឃុំ/ស្មៀនសង្កាត់ | 382 | 19.1 |
| គ្មានចំលើយ | 17 | 0.9 |
| សរុប | 1998 | 100 |

**14- តើលោក លោកស្រី បំរើការងារ ក្នុងជួររដ្ឋាភិបាលប៉ុន្មានឆ្នាំហើយ ?**

| | ចំនួន | ភាគរយ |
|---|---|---|
| 1-12 ខែ | 20 | 1 |
| 2-5 ឆ្នាំ | 730 | 36.5 |
| 6-10 ឆ្នាំ | 152 | 7.6 |
| 11-19 ឆ្នាំ | 306 | 15.3 |
| 20-30 ឆ្នាំ | 728 | 36.4 |
| 31-45 ឆ្នាំ | 43 | 2.2 |
| គ្មានចំលើយ | 19 | 1 |
| សរុប | 1998 | 100 |

| លេខសំនួរ | ចំនួនអ្នកឆ្លើយ ១៩៩៨ |
|---|---|

**15- តើលោក លោកស្រី ចាប់ផ្តើមបំរើការងារ ក្នុងជួររដ្ឋាភិបាលនៅឆ្នាំណា ?**

| | ចំនួន | ភាគរយ |
|---|---|---|
| 1960-1969 | 31 | 1.6 |
| 1970-1979 | 412 | 20.6 |
| 1980-1989 | 610 | 30.5 |
| 1990-1995 | 112 | 5.6 |
| 1996-2001 | 268 | 13.4 |
| >2001 | 544 | 27.2 |
| គ្មានចំលើយ | 21 | 1.1 |
| សរុប | 1998 | 100 |

**16- តើលោក លោកស្រី មានផ្ទះផ្ទាល់ខ្លួនចំនួនប៉ុន្មាន ?**

| | ចំនួន | ភាគរយ |
|---|---|---|
| គ្មានផ្ទះ | 165 | 8.3 |
| 1 ផ្ទះ | 1765 | 88.3 |
| 2 ផ្ទះ | 51 | 2.6 |
| 3 ផ្ទះ | 6 | 0.3 |
| 4 ផ្ទះ | 4 | 0.2 |
| 9 ផ្ទះ | 1 | 0.1 |
| គ្មានចំលើយ | 6 | 0.3 |
| សរុប | 1998 | 100 |

**17- តើលោក លោកស្រី មានដីប៉ុន្មានហិចតា រឺ ម៉ែត្រការ៉េ ?**

| | ចំនួន | ភាគរយ |
|---|---|---|
| <1000 | 178 | 8.9 |
| 1001-5000 | 236 | 11.8 |
| 5001-8000 | 106 | 5.3 |
| 8001-9500 | 25 | 1.3 |
| 9501-10000 | 301 | 15.1 |
| 10001-12500 | 39 | 2 |
| 12501-15000 | 170 | 8.5 |
| 15001-20000 | 251 | 12.6 |
| 20001-30000 | 188 | 9.4 |
| 30001-50000 | 142 | 7.1 |
| >50000 | 63 | 3.2 |
| គ្មានដី | 299 | 15 |
| សរុប | 1998 | 100 |

| លេខសំនួរ | ចំនួនអ្នកឆ្លើយ ១៩៩៨ |
|---|---|

**18-តើលោក លោកស្រី ធ្លាប់បានរៀនវគ្គបណ្តុះបណ្តាលជាមួយកម្មវិធីសិលា ឬអង្គការក្រៅរដ្ឋាភិបាល NGO ស្តីអំពីអភិបាលកិច្ចល្អ ដែរឬទេ ?**

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1705 | 85.3 |
| ទេ | 278 | 13.9 |
| គ្មានចំលើយ | 15 | 0.8 |
| សរុប | 1998 | 100 |

**19- ប្រសិនបើធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាល តើទើបតែរយៈពេល ២ឆ្នាំកន្លងទៅនេះឬ ?**

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1471 | 73.6 |
| ទេ | 489 | 24.5 |
| គ្មានចំលើយ | 38 | 1.9 |
| សរុប | 1998 | 100 |

**20- តើអ្នកណាបណ្តុះបណ្តាល លោក លោកស្រី អោយចេះធ្វើការងារបច្ចុប្បន្ននេះ ?**

| | ចំនួន | ភាគរយ |
|---|---|---|
| រដ្ឋាភិបាល | 425 | 21.3 |
| កម្មវិធីសិលា | 800 | 40 |
| ក្រសួងមហាផ្ទៃ | 275 | 13.8 |
| ថ្នាក់ជាតិ | 41 | 2.1 |
| ថ្នាក់ខេត្ត | 106 | 5.3 |
| ថ្នាក់ស្រុក | 176 | 8.8 |
| អង្គការក្រៅរដ្ឋាភិបាល | 74 | 3.7 |
| មេឃុំ / ចៅសង្កាត់ | 21 | 1.1 |
| គណបក្សសមរង្ស៊ី | 1 | 0.1 |
| ឪពុកម្តាយ | 1 | 0.1 |
| គណបក្សហ៊្វុនស៊ិនប៉ិច | 2 | 0.1 |
| គ្មានចំលើយ | 76 | 3.8 |
| សរុប | 1998 | 100 |

**21- តើលោក លោកស្រី បានទទួលការបណ្តុះ បណ្តាលគ្រប់គ្រាន់ ដើម្បីធ្វើការងារបច្ចុប្បន្នរបស់ លោក លោកស្រី បានល្អដែរឬទេ ?**

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 873 | 43.7 |
| ទេ | 1116 | 55.9 |
| គ្មានចំលើយ | 9 | 0.5 |
| សរុប | 1998 | 100 |

| លេខសំនួរ | ចំនួនអ្នកឆ្លើយ ១៩៩៨ |
|---|---|

**ចំណេះដឹង**

អ្នកផ្តល់ពត៌មានជាច្រើន បានដឹងថា អភិបាលកិច្ចជាអ្វី ។ ៩១% ផ្តល់និយមន័យដល់អភិបាលកិច្ច បានត្រឹមត្រូវថា វាជាគំរិតដែលអំណាច ត្រូវបានប្រើប្រាស់ ក្នុងការគ្រប់គ្រងធនធានរបស់ប្រទេស (តារាងទី១៤)។ អ្នកផ្តល់ពត៌មានបានយល់ច្បាស់ថា អភិបាលកិច្ចល្អជាអ្វី ដោយ ៩១% អោយនិយមន័យចំពោះអភិបាលកិច្ចថា ការប្រើប្រាស់អំណាចតាមរយៈស្ថាប័នរដ្ឋ ប្រកបដោយគណនេយ្យភាព និងតម្លាភាពដល់សាធារណៈជន (តារាងទី១៥) ។ អ្នកផ្តល់ពត៌មានជាច្រើន បានដឹងនូវគោលការណ៍សំខាន់បំផុត នៃអភិបាលកិច្ចល្អ ដែលក្នុងនោះ ៨៦% បានជ្រើសរើសយកតម្លាភាព៨០% បានជ្រើសរើសយកការពិភាក្សា និង ៦៨% បានជ្រើសរើសយកគណនេយ្យភាព (តារាងទី១៦)។ ក្រុមអង្កេតមានការភ្ញាក់ផ្អើលបន្តិច ដោយឃើញថា ចំនួនដែលសំរេចធ្វើតាមបទបញ្ជា មានចំនួន ៤៣% ។ ចំពោះនិយមន័យ នៃគណនេយ្យភាពនៅក្នុងអភិបាលកិច្ច អ្នកផ្តល់ពត៌មានហាក់ដូចជាមិនសូវដឹងច្បាស់ ។ អ្នកផ្តល់ពត៌មាន ៧៨% អោយនិយមន័យទៅលើគណនេយ្យភាព ថា វាជាការវាយតំលៃសកម្មភាពរបស់រដ្ឋាភិបាល ធ្វើឡើងដោយប្រជាពលរដ្ឋ ចំណែកឯ ៦៧% បានអោយនិយមន័យថា វាជាគំរិតដែលមន្ត្រីរដ្ឋាភិបាល ទទួលខុសត្រូវចំពោះឥរិយាបទរបស់ខ្លួន ។ ក្រុមអង្កេតក៏ភ្ញាក់ផ្អើលផងដែរថា អ្នកផ្តល់ពត៌មាន ៦៦% បានផ្តោតយកចិត្តទុកដាក់វត្តមានជាទៀងទាត់នៅឯកន្លែងធ្វើការរបស់ពួកគេ ទោះបីជាការអោយនិយមន័យបែបនេះ ត្រូវបានគេយល់ឃើញថា វាជាគណនេយ្យភាពក៏ដោយ (តារាងទី១៧)។ អ្នកផ្តល់ពត៌មាន មិនបានសង្កត់ធ្ងន់ទៅលើនិយមន័យ នៃការព្យាករណ៍ទុកជាមុននៅក្នុងអភិបាលកិច្ចនេះទេ ៧៦% បានកំណត់ថា ការទស្សទាយទុកជាមុន គឺជាដំណើរការនិតិរដ្ឋ និង ៧៥%បានកំណត់ថា វាជាគំរិតដែលច្បាប់ត្រូវបានគេកំណត់យ៉ាងខ្ជាប់ខ្ជួន (តារាងទី១៨) ។ ៦៤% ដែលបានកំណត់ថា វាជាការបន្តអនុវត្តនូវប្រព័ន្ធបច្ចុប្បន្ន គឺជាអ្នកគាំទ្រនៅស្ថានភាពដដែលនេះ ដែលមិនបានធ្វើអោយមានការភ្ញាក់ផ្អើលដល់មន្ត្រីដែលមានទស្សនៈអភិរក្ស ។ អ្វីដែលគួរអោយព្រួយបារម្ភ គឺមានជំរើសច្រើនដែលទាក់ទងទៅនិយមន័យ នៃការចូលរួមនៅក្នុងអភិបាលកិច្ច មន្ត្រីដែលជ្រើសរើសដោយការបោះឆ្នោតចំនួន ៨៣% បាននិយាយថា មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ គួរធ្វើការសំរេចលើគោលនយោបាយ ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋ ហើយ ៦៨% និយាយថា អោយរដ្ឋាភិបាលប្រកាសប្រាប់ប្រជាពលរដ្ឋគ្រប់ៗគ្នា អំពីច្បាប់ដែលពួកគេត្រូវអនុវត្តតាម (តារាងទី១៩)។ មានការងារដែលត្រូវធ្វើចំពោះការអភិវឌ្ឍន៍ នៃការចូលរួម ។ យ៉ាងហោចណាស់ ក៏មានសេចក្តីបញ្ជាក់យ៉ាងច្បាស់ អំពីនិយមន័យ នៃតម្លាភាពនៅក្នុងអភិបាលកិច្ច ដែលក្នុងនោះអ្នកផ្តល់ពត៌មាន ៨១% បានគូសបញ្ជាក់ថា សាធារណៈជន គួរបានទទួលនូវពត៌មានរបស់រដ្ឋាភិបាលដោយស្រួល ហើយ ៧៤% ត្រូវការអោយមានច្បាប់ បទបញ្ញត្តិ និងសេចក្តីសំរេចជាក់លាក់របស់រដ្ឋា-ភិបាល (តារាងទី២០)។

ការដែលទទួលអោយចាប់អារម្មណ៍នោះ គឺអ្នកផ្តល់ពត៌មាននៅគ្រប់ខេត្តទាំងអស់ បានជ្រើសរើសចំលើយដូចគ្នា ចំពោះសំណួរអំពីគោលបំណងចំបង នៃអភិបាលកិច្ចវិមជ្ឈការ នៅក្នុងប្រទេសកម្ពុជា (តារាងទី២២)។ អ្នកផ្តល់ពត៌មានជិត ៨៩% ចង់បានហេដ្ឋារចនាសម្ព័ន្ធជនបទ មានលក្ខណៈល្អប្រសើរ នេះជាទិសដៅច្បាស់លាស់នាពេលអនាគតដ៏ខ្លីរបស់ពួកគេ ហើយ ៧៤% ត្រូវការពង្រឹងសមត្ថភាពអ្នកភូមិ ដើម្បីអោយពួកគេធ្វើការអភិវឌ្ឍន៍ដោយខ្លួនឯង នេះជាគោលបំណងទស្សនៈវិជ្ជា ។ ៦៩% បានជ្រើសរើសចំលើយ "ការធ្វើផែនការវិមជ្ឈការដោយមានការគាំទ្រហិរញ្ញវត្ថុ ពីម្ចាស់ជំនួយខាងក្រៅ" ។ អ្នកចូលរួមកាន់តែយល់ច្បាស់ អំពីសមិទ្ធិផលអំពីក្រុមប្រឹក្សាឃុំ-សង្កាត់

| លេខសំនួរ | ចំនួនអ្នកឆ្លើយ ១៩៩៨ |
|---|---|

(តារាងទី២២) ដែលក្នុងនោះ ៨៧% បានជ្រើសរើសយកចំលើយ " កាត់បន្ថយភាពក្រីក្រ តាមរយៈការអភិវឌ្ឍន៍ ដែលមានការចូលរួម " ៨៦% បានជ្រើសរើសយកចំលើយ " ផ្តល់លទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន " ហើយ ៨៥% បានជ្រើសរើសយកចំលើយ " ផ្តល់អំណាចដល់អ្នកភូមិ ដើម្បីអោយពួកគេធ្វើការសំរេចចិត្តអំពីគំរូការអភិវឌ្ឍន៍របស់ពួកគេ " ។

មន្ត្រីបានប្រមូលផ្តុំនូវទ្រឹស្តី នៃវិមជ្ឈការ

សូមបញ្ជាក់ឡើងវិញថា នៅក្រោមតារាង ២៣ មន្ត្រី ៩៥% ជឿជាក់ថា ក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋរបស់ពួកគេ បានដឹងនូវចំនួនថវិកា និងចំនួនដងនៃការផ្តល់ថវិកាដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។ ទោះយ៉ាងណាក៏ដោយ ពួកគេមានទស្សនៈតិចតួចទាក់ទងទៅនឹងអ្នកដែលត្រួតពិនិត្យតាមដានលើកិច្ចសន្យា ក្នុងនាមម្ចាស់ជំនួយ (តារាងទី២៤) ។ ៦១% បានជ្រើសរើសចំលើយ " អភិបាលខេត្ត " ៥១% បានជ្រើសរើសយកចំលើយ " PRDC Excom " អ្នកផ្តល់ពត៌មានមិនបានដឹងអំពីរូបមន្ត ដែលមូលនិធិវិនិយោគឃុំ-សង្កាត់ ត្រូវបានធ្វើវិភាជន៍ដល់ឃុំឡើយ (តារាងទី២៥) ។ ៨៦% បានឆ្លើយថា វាអាស្រ័យទៅលើចំនួនប្រជាពលរដ្ឋនៅក្នុងឃុំ ។

**22- តើអភិបាលកិច្ចមានន័យយ៉ាងដូចម្តេចចំពោះលោក លោកស្រី ?**

| | ចំនួន | ភាគរយ |
|---|---|---|
| ប្រើប្រាស់អំណាច ដោយផ្អែកទៅតាមការចង្អុលបង្ហាញរបស់គណបក្សគ្រប់គ្រង ។ | 231 | 11.6 |
| ប្រើប្រាស់អំណាចដោយផ្អែកទៅលើទស្សនៈផ្ទាល់របស់អ្នកណាម្នាក់ ។ | 83 | 4.2 |
| អំណាចដែលត្រូវបានប្រើប្រាស់ ដើម្បីគ្រប់គ្រងធនធានរបស់ប្រទេស ។ | 1817 | 90.9 |
| ការដឹកនាំរបស់មនុស្សជាច្រើន តាមរយៈមនុស្សតែពីរបីនាក់ ។ | 397 | 19.9 |
| អំណាចដែលត្រូវបានប្រើប្រាស់ ដើម្បីផ្តល់ផលប្រយោជន៍ដល់សមាជិកគណបក្សនយោបាយ ។ | 134 | 6.7 |
| គ្មានចំលើយ | 20 | 1 |

**23- តើលោក លោកស្រី យល់ថា អភិបាលកិច្ចល្អ គឺអ្វី ?**

| | ចំនួន | ភាគរយ |
|---|---|---|
| ការប្រើប្រាស់អំណាចតាមរយៈកងកំលាំងសន្តិសុខ និងប៉ូលីស ។ | 97 | 4.9 |
| អនុវត្តនូវប្រព័ន្ធនយោបាយដែលផ្តល់ឱកាសដល់មនុស្សគ្រប់ៗគ្នា ។ | 1137 | 56.9 |
| ការប្រើប្រាស់អំណាចតាមរយៈស្ថាប័នរដ្ឋ ដែលមានការទទួលខុសត្រូវ និងមានតម្លាភាពដល់សាធារណៈជនទូទៅ ។ | 1831 | 91.6 |
| ការប្រើប្រាស់អំណាចតាមរយៈស្ថាប័នគណបក្សនយោបាយ ។ | 68 | 3.4 |
| ការប្រើប្រាស់អំណាចតាមរយៈមន្ត្រីជាន់ខ្ពស់ដែលត្រូវបានតែងតាំង ។ | 120 | 6 |
| ការប្រើប្រាស់អំណាចតាមរយៈច្បាប់ ដែលអាចទទួលយកបាន និងត្រូវបានបន្តប្រតិបត្តិ ។ | 1324 | 66.3 |
| គ្មានចំលើយ | 4 | 0.2 |

| លេខសំនួរ | ចំនួនអ្នកឆ្លើយ ១៩៩៨ |
|---|---|

24-- តើលោក លោកស្រី យល់ថា គោលការណ៍សំខាន់បំផុតនៅក្នុងអភិបាលកិច្ចល្អ គឺអ្វី ?

| | ចំនួន | ភាគរយ |
|---|---|---|
| ការពិភាក្សា | 1594 | 79.8 |
| គោរពសេចក្ដី | 867 | 43.4 |
| តម្លាភាព | 1725 | 86.3 |
| គ្មានអំពើពុករលួយ | 1293 | 64.7 |
| កិច្ចព្រមព្រៀង | 1107 | 55.4 |
| ការគោរពគ្នា | 1246 | 62.4 |
| ការអភិវឌ្ឍន៍ | 1362 | 68.2 |
| ផែនការចូលរួម និងការធ្វើវិភាគទានពីសហគមន៍នៅតាមមូលដ្ឋាន | 1283 | 64.2 |
| ការទទួលខុសត្រូវ | 1367 | 68.4 |
| ការទស្សទាយទុកជាមុន | 344 | 17.2 |

25- ការទទួលខុសត្រូវនៅក្នុងអភិបាលកិច្ច គឺ :

| | ចំនួន | ភាគរយ |
|---|---|---|
| គឺជាដែលមន្ត្រីរាជការ ត្រូវទទួលខុសត្រូវចំពោះឥរិយាបថរបស់ខ្លួន ។ | 1340 | 67.1 |
| ការគ្រប់គ្រងកិច្ចការរដ្ឋាភិបាល ដោយមន្ត្រីតែងតាំង ។ | 354 | 17.7 |
| ការវាយតំលៃសកម្មភាពរបស់រដ្ឋាភិបាល ដោយប្រជាពលរដ្ឋ ។ | 1564 | 78.3 |
| ការចូលមកធ្វើការយ៉ាងទៀងទាត់របស់មន្ត្រី នៅក្នុងការិយាល័យរបស់រដ្ឋាភិបាល ។ | 1311 | 65.6 |
| គឺជាដែលចៅហ្វាយនាយសប្បាយចិត្ត ទៅនឹងការអនុវត្តន៍ការងាររបស់មន្ត្រីនានា ។ | 185 | 9.3 |
| គ្មានចំលើយ | 2 | 0.1 |

26- ការទស្សទាយទុកជាមុននៅក្នុងអភិបាលកិច្ច គឺ :

| | ចំនួន | ភាគរយ |
|---|---|---|
| ការបន្តអនុវត្តន៍នូវប្រព័ន្ធដែលមាននាពេលបច្ចុប្បន្ន ។ | 1279 | 64 |
| គឺជានៃការដឹកនាំ និងច្បាប់ឆ្លុះបញ្ចាំងនូវទស្សនៈរបស់គណៈបក្សគ្រប់គ្រងនយោបាយ ។ | 230 | 11.5 |
| គឺជានៃការដឹកនាំ និងច្បាប់ត្រូវបានបន្តប្រតិបត្តិ ។ | 1489 | 74.5 |
| ការត្រឡប់ទៅយកច្បាប់នាទស្សវត្ស ៥០ និង ៦០ មកប្រើវិញ ។ | 242 | 12.1 |
| ការអនុវត្តន៍ច្បាប់ ។ | 1522 | 76.2 |
| គ្មានចំលើយ | 4 | 0.2 |

27- ការចូលរួមនៅក្នុងអភិបាលកិច្ច គឺ :

| | ចំនួន | ភាគរយ |
|---|---|---|
| យុវជនទាំងអស់ អាចចូលរួមក្នុងការសំរេចចិត្តរបស់រដ្ឋាភិបាល ។ | 1008 | 50.5 |
| ចំនួនដែលប្រជាពលរដ្ឋចូលរួម ក្នុងការសំរេចចិត្តរបស់រដ្ឋាភិបាល ។ | 1128 | 56.5 |

| លេខសំនួរ | ចំនួនអ្នកឆ្លើយ ១៩៩៨ |
|---|---|

| | | |
|---|---|---|
| មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល គួរសំរេចនូវគោលនយោបាយដែលជាប្រយោជន៍ដ៏ប្រសើរបំផុតរបស់ប្រជាជន ។ | 1666 | 83.4 |
| ខស្សនៈដែលបានលើកឡើង មានឥទ្ធិពលក្នុងរដ្ឋាភិបាល ។ | 377 | 18.9 |
| ស្នើអោយរដ្ឋាភិបាលជូនដំណឹងដល់មនុស្សគ្រប់គ្នា នូវច្បាប់អ្វីដែលពួកគេត្រូវតែគោរព ។ | 1367 | 68.4 |
| គ្មានចំលើយ | 3 | 0.2 |

**28- តម្លាភាពនៅក្នុងអភិបាលកិច្ច គឺ :**

| | ចំនួន | ភាគរយ |
|---|---|---|
| ច្បាប់ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសំរេចច្បាស់លាស់របស់រដ្ឋាភិបាល ។ | 1475 | 73.8 |
| ជូនដំណឹងដល់សាធារណៈជន ស្តីពីបញ្ហាទាំងឡាយ លើកលែងតែអ្នកដែលបង្កអោយមានអស្ថេរភាព ។ | 914 | 45.7 |
| ត្រូវកំណត់តំលៃសំរាប់ការបំរើសេវាអោយបានច្បាស់លាស់ ។ | 1284 | 64.3 |
| ពត៌មានផ្សេងៗរបស់រដ្ឋាភិបាល ត្រូវដាក់អោយសាធារណៈជន បានដឹងដោយងាយ ។ | 1622 | 81.2 |
| ទុកលទ្ធភាពអោយមន្ត្រីជាន់ខ្ពស់ បង្កើតច្បាប់ និងបទបញ្ជាផ្ទៃក្នុង ។ | 402 | 20.1 |
| គ្មានចំលើយ | 4 | 0.2 |

**29- តើអ្វីជាវត្ថុបំណងចំបង នៃអភិបាលកិច្ចវិមជ្ឈការ នៅក្នុងប្រទេសកម្ពុជា ?**

| | ចំនួន | ភាគរយ |
|---|---|---|
| រៀបចំផែនការវិមជ្ឈការ ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីម្ចាស់ជំនួយខាងក្រៅ ។ | 1373 | 68.7 |
| កាត់បន្ថយភាពក្រីក្រ និងពង្រឹងលទ្ធិប្រជាធិបតេយ្យ | 1772 | 88.7 |
| ពង្រឹងអំណាចក្រុមប្រឹក្សាឃុំ/សង្កាត់ថ្មី ។ | 1303 | 65.2 |
| ពង្រឹងសមត្ថភាពរបស់អ្នកភូមិ ដើម្បីអភិវឌ្ឍន៍ខ្លួនគេ ។ | 1468 | 73.5 |
| បង្កើនអំណាចដល់អ្នកភូមិ ។ | 799 | 40 |
| បង្កើតគណៈកម្មាធិការប្រឹក្សាដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ ។ | 1139 | 57 |
| ធ្វើផែនការចូលរួម និងវិភាគទានទៅតាមមូលដ្ឋាន ។ | 1308 | 65.5 |
| គ្មានចំលើយ | 3 | 0.2 |

**30- ក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលទើបជាប់ឆ្នោត តាមរយៈការបោះឆ្នោតនឹង :**

| | ចំនួន | ភាគរយ |
|---|---|---|
| ធ្វើអោយមានប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន ។ | 1713 | 85.7 |
| ផ្តល់សិទ្ធិអំណាចដល់អ្នកភូមិ ដើម្បីសំរេចនូវគំរូវការអភិវឌ្ឍន៍ផ្ទាល់របស់ពួកគេ ។ | 1695 | 84.8 |
| ពង្រឹងសមាជិកភាពរបស់គណបក្សនយោបាយនៅថ្នាក់ទាប ។ | 243 | 12.2 |
| ត្រូវរកថវិកាបរទេស ។ | 536 | 26.8 |
| កាត់បន្ថយភាពក្រីក្រ តាមរយៈការអភិវឌ្ឍន៍ដែលមានការចូលរួមពីសហគមន៍ ។ | 1741 | 87.1 |
| គ្មានចំលើយ | 2 | 0.1 |

| **លេខសំនួរ** | ចំនួនអ្នកឆ្លើយ ១៩៩៨ |
|---|---|

**31- ចំនួនទឹកប្រាក់ និងចំនួនដងនៃការផ្តល់ថវិកា វិនិយោគនៃកម្មវិធីសិលា ឃុំ/សង្កាត់ ទទួលពីរដ្ឋាភិបាលកណ្តាល គឺត្រូវអោយដឹងដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ និងអ្នកបោះឆ្នោត**

| | ចំនួន | ភាគរយ |
|---|---|---|
| ពិត | 1899 | 95 |
| មិនពិត | 81 | 4.1 |
| គ្មានចំលើយ | 18 | 0.9 |
| សរុប | 1998 | 100 |

**32- តើនរណាត្រួតពិនិត្យកុងត្រារបស់ខេត្ត ពេលមានការវិនិយោគរបស់ម្ចាស់ជំនួយ ?**

| | ចំនួន | ភាគរយ |
|---|---|---|
| អភិបាលខេត្ត | 1218 | 61 |
| អ្នកត្រួតពិនិត្យបញ្ជីចំណាយចំណូល | 872 | 43.6 |
| មន្ទីរអភិវឌ្ឍន៍ជនបទ | 790 | 39.5 |
| ក្រសួងមហាផ្ទៃ | 933 | 46.7 |
| គ.អ.ជ.ខ (PRDC) / គណៈកម្មាធិការប្រតិបត្តិ ( Excom ) | 1024 | 51.3 |
| មិនដឹង | 187 | 9.4 |
| គ្មានចំលើយ | 7 | 0.4 |

**33- ថវិកាវិនិយោគឃុំ / សង្កាត់ ត្រូវបានបែងចែកសំខាន់ គឺផ្អែកទៅតាម :**

| | ចំនួន | ភាគរយ |
|---|---|---|
| ចំងាយផ្លូវពីឃុំទៅទីរួមខេត្ត ។ | 720 | 36 |
| ចំនួនប្រជាជននៅក្នុងឃុំ ។ | 1711 | 85.6 |
| ថាតើឃុំនោះក្រដល់កំរិតណា | 1143 | 57.2 |
| រូបមន្តកុំព្យូទ័រ | 139 | 7 |
| សេចក្តីសំរេចដោយអភិបាលខេត្ត | 620 | 31 |
| គ្មានចំលើយ | 15 | 0.8 |

## សេចក្តីសន្និដ្ឋាន

អ្នកផ្តល់ពត៌មាន ជឿជាក់ថា រដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ គួរទទួលខុសត្រូវចំពោះសកម្មភាពរបស់ពួកគេ (តារាងទី២៦) ដែលក្នុងនោះ ៨២% មានជំនឿថា ក្រុមប្រឹក្សាឃុំ-សង្កាត់ គួរតែទទួលខុសត្រូវ ចំណែកឯ ៨០% មានជំនឿថា ថ្នាក់ខេត្តគួរតែទទួលខុសត្រូវ ហើយ ៧៩% ទៀត មានជំនឿថា ថ្នាក់ជាតិគួរតែទទួលខុសត្រូវផងដែរ ។ (តារាងទី២៧) បង្ហាញអោយឃើញថា អ្នកផ្តល់ពត៌មាន ៩១% គិតថា បុរសមានអាយុលើសពី ១៨ឆ្នាំ គួរមានសំលេងនៅក្នុងជួររដ្ឋាភិបាល ហើយ ៨២% មានជំនឿថា ស្ត្រីមិនទាន់រៀបអាពាហ៍ពិពាហ៍ ដែលមានអាយុលើស ពី ១៨ គួរតែមានសំលេងនៅក្នុងជួររដ្ឋាភិបាល ។ មន្ត្រី ៦៨% មានជំនឿថា ស្ត្រីដែលរៀបអាពាហ៍ពិពាហ៍ហើយ គួរតែមានសំលេងនៅក្នុងជួររដ្ឋាភិបាលផងដែរ ។ មន្ត្រី ៣៧% មានជំនឿថា កងទ័ពគួរតែមានសំលេង ហើយមន្ត្រី

| លេខសំនួរ | ចំនួនអ្នកឆ្លើយ ១៩៩៨ |
| --- | --- |

៤៣% ក៏មានជំនឿផងដែរថា ព្រះសង្ឃគួរតែមានសំលេងនៅក្នុងជួររដ្ឋាភិបាល ។ អ្នកផ្តល់ពត៌មាន ហាក់ដូចជាមានទស្សនៈមិនច្បាស់លាស់អំពីបញ្ហាតម្លាភាពដែលបានលើកឡើង នៅក្នុងតារាងដាច់ដោយឡែកពីគ្នា ២៨ និង ២៩ ។ អ្នកផ្តល់ពត៌មាន ៦៦% មានជំនឿថា មានពេលខ្លះការអនុវត្តន៍ច្បាប់ ធ្វើអោយយឺតយ៉ាវដល់ដំណើរការអភិវឌ្ឍន៍ ហើយ ៦៦% ទៀត មានជំនឿថា មានពេលខ្លះ ជាការប្រសើរណាស់ដែលការសំរេចចិត្ត ធ្វើឡើងដោយរដ្ឋាភិបាល ជាជាងធ្វើឡើងដោយសាធារណៈជន ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេបានដឹងអំពី អត្ថប្រយោជន៍នៃប្រព័ន្ធវិមជ្ឈការ ដែលអំណាចមួយចំនួន បានផ្ទេរពីថ្នាក់ជាតិទៅអោយក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលក្នុងនោះអ្នកផ្តល់ពត៌មាន ៩៤% បានផ្តល់នូវការឯកភាពចំពោះចំលើយនេះ (តារាងទី៣០) ។ អ្នកផ្តល់ពត៌មាន ៧២% បានគិតថា ការអភិវឌ្ឍន៍យូរអង្វែងនៅក្នុងប្រទេសកម្ពុជា មិនអាចធ្វើទៅបានដោយគ្មានក្រុមប្រឹក្សាឃុំ-សង្កាត់បានឡើយ (តារាងទី៣១) ។ អ្នកផ្តល់ពត៌មានមិនបានគិតថា មនុស្សចាស់ និងស្ត្រី បានយល់ពីការអភិវឌ្ឍន៍ ហើយគួរតែចូលរួមនៅក្នុងការធ្វើផែនការ និងចូលរួមនៅក្នុងការចាត់ចែងថវិកា សំរាប់ការអភិវឌ្ឍន៍ (តារាងទី៣២-៣៣) ។ អ្នកផ្តល់ពត៌មាន ៧៦% បានគិតថា មនុស្សចាស់គួរតែចូលរួម ហើយ ៨០% ទៀត បានគិតថា ស្ត្រីក៏គួរតែចូលរួមដែរ ។ ការអភិវឌ្ឍន៍ដោយមានការចូលរួមដូចដែលបានចោទសួរ នៅក្នុងតារាង ៣៤ ។ អ្នកផ្តល់ពត៌មាន ៨២% បានគិតថា ការអភិវឌ្ឍន៍មានការចូលរួមមានន័យថា បង្កើនការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាលនៅក្នុងដំណើរការអភិវឌ្ឍន៍ ហើយ ៧៩% បានគិតថា ការអភិវឌ្ឍន៍ដោយមានការចូលរួមនេះ មានន័យថា ផ្តល់អំណាចដល់អ្នកភូមិ ដើម្បីឱ្យពួកគេធ្វើការសំរេចចិត្តអំពីការអភិវឌ្ឍន៍របស់ពួកគេ ។

អ្នកផ្តល់ពត៌មានហាក់ដូចជា មានការយល់ដឹងអំពីការធ្វើផែនការ និងការចាត់ចែងគ្រប់គ្រងការអភិវឌ្ឍន៍ ។ អ្នកផ្តល់ពត៌មាន ៧៧% មានជំនឿថា ការគ្រប់គ្រងល្អនៅក្នុងការអភិវឌ្ឍន៍ ជំរុញអោយមានការពិភាក្សាបន្ថែមទៀតរវាងអ្នកភូមិ និងមន្ត្រីក្រុមប្រឹក្សាឃុំ-សង្កាត់ នៅក្នុងការធ្វើសេចក្តីសំរេចអំពីការអភិវឌ្ឍន៍ (តារាង ៣៥ ) ។ អ្នកផ្តល់ពត៌មាន ៨៥% គិតថា ការរៀបចំផែនការល្អ នៅក្នុងការអភិវឌ្ឍន៍មានន័យថា ការរៀបចំផែនការដែលបញ្ចូលគំនិត សេចក្តីសំរេច និងការចូលរួមដោយស្ម័គ្រចិត្តរបស់សហគមន៍ ដែលទទួលរងឥទ្ធិពល ពីការធ្វើផែនការនោះ ហើយ ៨៤% ទៀត មានជំនឿថា ការធ្វើផែនការល្អ មានន័យថា ការធ្វើផែនការដែលច្បាស់លាស់ នឹងអាចអនុវត្តទៅបាន (តារាងទី៣៦) ។ ចំពោះលក្ខណៈសម្បត្តិចាំបាច់របស់អ្នកគ្រប់គ្រង និងអ្នកដឹកនាំល្អ អ្នកផ្តល់ពត៌មាន ៨៤% មានជំនឿថា វាជាបញ្ហាយោគយល់គ្នា ហើយជឿជាក់ថា បញ្ហាទាំងនេះ អាចត្រូវបានគេដោះស្រាយ ដែលក្នុងនោះអ្នកផ្តល់ពត៌មាន ៨០% មានជំនឿថា វាជាការត្រឹមត្រូវ និងយោគយល់រវាងគ្នា និងគ្នា (តារាងទី៣៧) ។ អ្នកផ្តល់ពត៌មាន ៨៧% មានជំនឿថា អត្ថប្រយោជន៍ដ៏ធំ នៃអភិបាលកិច្ចល្អ គឺថា ប្រទេស នឹងមានការអភិវឌ្ឍន៍ និងសន្តិ-សុខ ហើយ ៧៥% មានជំនឿថា ប្រជាពលរដ្ឋនឹងពេញចិត្តតំណាងរបស់ពួកគេនៅក្នុងរដ្ឋាភិបាល (តារាងទី៣៨) ។ អ្នកផ្តល់ពត៌មានទាំង ៧ខេត្ត បានឆ្លើយនូវចំលើយប្រហាក់ប្រហែលគ្នា ចំពោះសំនួរដែលសួរអំពី ថាតើស្ត្រីគួរតែចូលរួមក្នុងការអភិវឌ្ឍន៍ដែរឬទេ ។ ៨៣% ឆ្លើយថា ស្ត្រីគួរតែចូលរួមនៅក្នុងការអភិវឌ្ឍន៍ ពីព្រោះស្ត្រីគឺជាមាតាពិភពលោក (តារាងទី៣៩) ។

| លេខសំនួរ | ចំនួនអ្នកឆ្លើយ ១៩៩៨ |
|---|---|

34- តើមន្ត្រីរបស់រដ្ឋាភិបាលថ្នាក់ណាខ្លះ ដែលគួរទទួលខុសត្រូវ ចំពោះសកម្មភាពរបស់ខ្លួន ?

| | ចំនួន | ភាគរយ |
|---|---|---|
| ថ្នាក់ជាតិ | 1578 | 79 |
| ថ្នាក់ខេត្ត | 1589 | 79.5 |
| ថ្នាក់ឃុំ | 1631 | 81.6 |
| គ្មានចំលើយ | 13 | 0.7 |

35- តើលោក លោកស្រីយល់ថា នរណាគួរតែមានសំលេង ក្នុងការងាររបស់រដ្ឋាភិបាល ?

| | ចំនួន | ភាគរយ |
|---|---|---|
| បុរសដែលមានអាយុលើសពី ១៨ឆ្នាំ | 1816 | 90.9 |
| ស្ត្រីមានប្តី | 1351 | 67.6 |
| ស្ត្រីគ្មានប្តី ដែលមានអាយុលើសពី ១៨ឆ្នាំ | 1646 | 82.4 |
| ព្រឹទ្ធាចារ្យ | 1181 | 59.1 |
| ជនពិការ | 909 | 45.5 |
| ទាហាន | 734 | 36.7 |
| ព្រះសង្ឃ | 868 | 43.4 |
| គ្មានចំលើយ | 4 | 0.2 |

36- តើមានពេលខ្លះ ការប្រតិបត្តិច្បាប់ ធ្វើអោយយឺតដំណើរដល់ការអភិវឌ្ឍន៍ដែរឬទេ ?

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1353 | 67.7 |
| ទេ | 597 | 29.9 |
| គ្មានចំលើយ | 48 | 2.4 |
| សរុប | 1998 | 100 |

37- តើមានពេលខ្លះសេចក្តីសំរេចដែលធ្វើឡើងដោយរដ្ឋាភិបាលប្រសើរជាងធ្វើ ជាសាធារណៈដែរឬទេ ?

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1316 | 65.9 |
| ទេ | 664 | 33.2 |
| គ្មានចំលើយ | 18 | 0.9 |
| សរុប | 1998 | 100 |

38- តើលោក លោកស្រីឯកភាពអំពីវិមជ្ឈការ ដែលអំណាចមួយចំនួន ត្រូវបានផ្ទេរពីរដ្ឋាភិបាលថ្នាក់ជាតិ ដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ដែរឬទេ ?

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1897 | 94.9 |
| ទេ | 96 | 4.8 |

| លេខសំនួរ | ចំនួនអ្នកឆ្លើយ ១៩៩៨ |
|---|---|

| | | |
|---|---|---|
| គ្មានចំលើយ | 5 | 0.3 |
| សរុប | 1998 | 100 |

**39- តើការអភិវឌ្ឍន៍ដែលមានរយៈពេលយូរនៅក្នុងប្រទេសកម្ពុជា អាចដំណើរការបានដោយគ្មានក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលទើបនឹងជាប់ឆ្នោតថ្មីរទេ ?**

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 540 | 27 |
| ទេ | 1446 | 72.4 |
| គ្មានចំលើយ | 12 | 0.6 |
| សរុប | 1998 | 100 |

**40 - នៅក្នុងប្រទេសកម្ពុជា ចាស់ព្រឹទ្ធាចារ្យមិនយល់ពីការអភិវឌ្ឍន៍ ដូច្នេះពួកគាត់មិនគួរអោយចូលរួមនៅក្នុងការរៀបចំផែនការ និងថវិកាឃុំ/សង្កាត់ ទេ ។**

| | ចំនួន | ភាគរយ |
|---|---|---|
| ពិត | 464 | 23.2 |
| មិនពិត | 1521 | 76.1 |
| គ្មានចំលើយ | 13 | 0.7 |
| សរុប | 1998 | 100 |

**41- នៅក្នុងប្រទេសកម្ពុជា ស្ត្រីមិនយល់ពីការអភិវឌ្ឍន៍ គេមិនគួរអោយពួកគាត់ចូលរួមនៅក្នុងការរៀបចំផែនការ និងថវិកាឃុំ/សង្កាត់ ទេ ។**

| | ចំនួន | ភាគរយ |
|---|---|---|
| ពិត | 384 | 19.2 |
| មិនពិត | 1604 | 80.3 |
| គ្មានចំលើយ | 10 | 0.5 |
| សរុប | 1998 | 100 |

**42- នៅក្នុងប្រទេសកម្ពុជា វិធីសាស្ត្រចូលរួមក្នុងការអភិវឌ្ឍន៍ មានន័យថា :**

| | ចំនួន | ភាគរយ |
|---|---|---|
| បង្កើនការចូលរួមពីមន្ត្រីរដ្ឋាភិបាលនៅក្នុងការអភិវឌ្ឍន៍ ។ | 1313 | 65.7 |
| បង្កើនការចូលរួមពីអង្គការក្រៅរដ្ឋាភិបាល នៅក្នុងដំណើរការអភិវឌ្ឍន៍ ។ | 1633 | 81.7 |
| រៃអង្គាសលុយ និងសុំកំលាំងពលកម្មពីអ្នកភូមិ ។ | 862 | 43.1 |
| ផ្តល់អំណាចដល់អ្នកភូមិ ដើម្បីធ្វើការសំរេចចិត្ត ស្តីពីការអភិវឌ្ឍន៍ផ្ទាល់ខ្លួនរបស់ពួកគេ ។ | 1583 | 79.2 |
| បង្កើនការចូលរួមពីព្រះសង្ឃ និងអាចារ្យក្នុងការអភិវឌ្ឍន៍ ។ | 1365 | 68.3 |
| សូមយកការរៀបរាប់ខាងលើនេះ ជាចំលើយ ។ | 963 | 48.2 |
| ការរៀបរាប់ខាងលើទាំងអស់ មិនមែនជាចំលើយ ។ | 66 | 3.3 |
| គ្មានចំលើយ | 3 | 0.2 |

| លេខសំនួរ | ចំនួនអ្នកឆ្លើយ ១៩៩៨ |
|---|---|

**43- ការគ្រប់គ្រងល្អ នៅក្នុងការអភិវឌ្ឍន៍ មានន័យថា :**

| | ចំនួន | ភាគរយ |
|---|---|---|
| មានការពិគ្រោះពិភាក្សាថែមទៀត រវាងមន្ត្រីរដ្ឋាភិបាលថ្នាក់ខ្ពស់ និងមន្ត្រីឃុំ/សង្កាត់ ។ | 301 | 15.1 |
| មានការពិគ្រោះពិភាក្សាបន្ថែម រវាងអ្នកភូមិ និងមន្ត្រីឃុំ/សង្កាត់ ក្នុងការសំរេចចិត្តក្នុងកិច្ចអភិវឌ្ឍន៍ ។ | 1542 | 77.2 |
| គ្មានចំលើយ | 155 | 7.8 |
| សរុប | 1998 | 100 |

**44- តើការរៀបចំផែនការល្អ គឺជាអ្វី ?**

| | ចំនួន | ភាគរយ |
|---|---|---|
| ការរៀបចំផែនការ ដោយផ្អែកទៅលើការយល់ដឹង ពីគោលបំណងរបស់គណបក្សគ្រប់គ្រង ។ | 194 | 9.7 |
| ការរៀបចំផែនការ ដោយផ្អែកទៅលើទស្សនៈ និងសេចក្តីសំរេចផ្ទាល់ខ្លួនរបស់អភិបាលខេត្ត និងថ្នាក់ដឹកនាំឃុំ/សង្កាត់ - ស្រុក/ខណ្ឌ ។ | 765 | 38.3 |
| ការរៀបចំផែនការ ដែលរួមបញ្ចូលគ្នានូវគំនិត សេចក្តីសំរេច និងការចូលរួមដោយស្ម័គ្រចិត្តពីសហគមន៍ដែលទទួលឥទ្ធិពលពីផែនការ ។ | 1681 | 84.1 |
| ការរៀបចំផែនការដែលមានលក្ខណៈច្បាស់លាស់ហើយដែលអាចយកមកអនុវត្តន៍បាន ។ | 1669 | 83.5 |
| ការរៀបចំផែនការ និងការអនុវត្តន៏ដោយផ្អែកទៅលើគោលការណ៏របស់ព្រះពុទ្ធ ។ | 371 | 18.6 |
| គ្មានចំលើយ | 6 | 0.3 |

**45- តើគុណភាពចំបង នៃអ្នកគ្រប់គ្រងល្អ / ថ្នាក់ដឹកនាំល្អ គឺអ្វី ?**

| | ចំនួន | ភាគរយ |
|---|---|---|
| យល់ពីបញ្ហា និងជឿជាក់ថា អាចដោះស្រាយបញ្ហាទាំងនោះបាន ។ | 1689 | 84.5 |
| មិនជិតស្និទ្ធិជាមួយអ្នកដទៃ ។ | 140 | 7 |
| ប្រកាន់ភាពយុត្តិធម៌ និងយល់យោគដល់អ្នកដទៃ ។ | 1592 | 79.7 |
| ធ្វើជាមនុស្សសំខាន់ ដើម្បីជួយសហសេវិក ។ | 741 | 37.1 |
| ចេះតែដាក់បទបញ្ជា តែមិនបានធ្វើជាគំរូល្អដល់អ្នកដទៃ ។ | 64 | 3.2 |
| គោរពអ្នកដទៃ ។ | 1232 | 61.7 |
| ធានាថាមនុស្សធ្វើការក្រោមបង្គាប់ទទួលប្រាក់ខែខ្ពស់ ។ | 241 | 12.1 |
| ជ្រើសរើសមនុស្សក្រោមបង្គាប់ដែលស្មោះត្រង់ ។ | 880 | 44 |
| គ្មានចំលើយ | 5 | 0.3 |

**46- តើអត្ថប្រយោជន៍ចំបង នៃអភិបាលកិច្ចល្អ គឺអ្វី ?**

| | ចំនួន | ភាគរយ |
|---|---|---|
| ប្រជាពលរដ្ឋពេញចិត្តចំពោះតំណាងរបស់ពួកគាត់នៅក្នុងជួររដ្ឋាភិបាល ។ | 1507 | 75.4 |
| ប្រទេសមានការអភិវឌ្ឍន៍ និងសន្តិសុខ ។ | 1738 | 87 |
| ថ្នាក់ដឹកនាំ និងមនុស្សក្រោមបញ្ជាទទួលអត្ថប្រយោជន៍ច្រើន ។ | 390 | 19.5 |
| ប្រជាពលរដ្ឋនឹងមិនរិះគន់អ្នកដឹកនាំរបស់ពួកគេ ។ | 771 | 38.6 |

| **លេខសំនួរ** | ចំនួនអ្នកឆ្លើយ ១៩៩៨ | |
|---|---|---|
| អ្នកដឹកនាំនឹងត្រូវបោះឆ្នោតជ្រើសរើសសារជាថ្មី ។ | 1018 | 51 |
| គ្មានចំលើយ | 7 | 0.4 |

**47-ហេតុអ្វីបានជាស្ត្រី ត្រូវតែចូលរួម ក្នុងការអភិវឌ្ឍន៍ ?**

| | ចំនួន | ភាគរយ |
|---|---|---|
| ស្ត្រីមានចំនួនច្រើន ។ | 1139 | 57 |
| ស្ត្រីគឺជាផ្នែកនៃសង្គម ដែលក្រីក្រ និងទន់ខ្សោយជាងគេបំផុត ។ | 1313 | 65.7 |
| ស្ត្រីជាមាតានៃពិភពលោក ។ | 1651 | 82.6 |
| ប្រាក់ខែរបស់ស្ត្រីមិនគ្រប់គ្រាន់ ។ | 615 | 30.8 |
| ឧស្សាហ:របស់ស្ត្រីមិនត្រូវបានចាត់ទុកថា ជាអាទិភាព ហើយត្រូវគេមើលរំលង ប្រសិនបើមិនមានការយកចិត្តទុកដាក់យ៉ាងពិសេសដល់ពួកគេ ។ | 1004 | 50.3 |
| គ្មានចំលើយ | 5 | 0.3 |

**<u>ការអនុវត្តន៍</u>**

អ្នកផ្តល់ពត៌មាន ៨៣% មានជំនឿថា ការអនុវត្តន៏ ការគ្រប់គ្រងរដ្ឋាភិបាលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា គឺមានលក្ខណ:សមស្របសំរាប់រយ:ពេល ៥ឆ្នាំទៅមុខ (តារាងទី៤០) ។ ហើយ ៨៤% ទៀត មានជំនឿថា រដ្ឋាភិបាលកំពុងបង្កើនមធ្យោបាយ ដែលក្នុងនោះប្រជាពលរដ្ឋកម្ពុជាទាំងអស់ អាចចូលរួមធ្វើការសំរេចចិត្តលើគោលនយោបាយ (តារាងទី៤១) ។ ពួកគេបានសង្កត់ធ្ងន់យ៉ាងខ្លាំងដែរទៅលើការអនុវត្តន៏ច្បាប់ អ្នកផ្តល់ពត៌មានជិត ៨៥% បានមានជំនឿថា ច្បាប់ទាំងអស់ ត្រូវបានកំពុងអនុវត្តយ៉ាងខ្ជាប់ខ្ជួននៅក្នុងប្រទេសកម្ពុជា (តារាងទី៤២) ។ ពួកគេមិនដឹងថា ពួកគេបានទទួលពត៌មានគ្រប់គ្រាន់ ស្តីអំពីការចំណាយរបស់រដ្ឋាភិបាលនោះទេ ។ អ្នកផ្តល់ពត៌មាន ៧១% បាននិយាយថា ពួកគេមិនបានទទួលពត៌មានគ្រប់គ្រាន់ ស្តីពីការចំណាយរបស់រដ្ឋាភិបាលទេ (តារាងទី៤៣) ។

ចំពោះបញ្ហាអំពើពុករលួយវិញ អ្នកផ្តល់ពត៌មាន បានដឹងយ៉ាងច្បាស់ ហើយរារែកក្នុងចិត្តក្នុងការឆ្លើយ ។ ខាងក្រោមតារាង ៤៤ អ្នកផ្តល់ពត៌មាន ៥៨% បាននិយាយថា នៅក្នុងប្រទេសកម្ពុជា ការបង់ថវិកាក្រៅផ្លូវការ គឺជាមធ្យោបាយសាមញ្ញ ដើម្បីអោយគេធ្វើអ្វីមួយអោយ ហើយនៅក្រោមតារាង ៤៥ អ្នកផ្តល់ពត៌មាន ៥០% បាននិយាយថា អ្នកម៉ៅការត្រូវបង់កំរៃជើងសារ ដើម្បីទទួលបានកុងត្រា ។ អ្នកផ្តល់ពត៌មាន ៥៣% បាននិយាយថា វាជាការសមហេតុ សមផល ដែលមន្ត្រីរដ្ឋាភិបាលមានប្រាក់ខែតិច ទទួលយកកំរៃជើងសារ (តារាងទី៤៦) ។ អ្នកផ្តល់ពត៌មាន ៧១% និយាយថា ស្ថិតនៅក្រោមប្រព័ន្ធហិរញ្ញវត្ថុរបស់កម្មវិធីសិលាបច្ចុប្បន្ន អ្នកដែលចង់លួចថវិកាពីតំរោង នឹងត្រូវបានចាប់ខ្លួន (តារាងទី៤៧) ។ ពួកគេក៏បានសង្កត់ធ្ងន់អំពីការនិយមបក្សពួកផងដែរ ដែលក្នុងនោះ ៨១% បាននិយាយថា វាជាការមិនសមហេតុ សមផល ដែលជ្រើសរើសយកអ្នកម៉ៅការណាម្នាក់ ដោយសារដែលពួកគេមានទំនាក់ទំនងជាមួយមន្ត្រីដែលមានឥទ្ធិពល (តារាងទី៤៨) ។ អ្នកផ្តល់ពត៌មាន ហាក់ដូចជាមិនមានទំនុកចិត្តសោះ អំពីរបៀបកិច្ចសន្យាសំរាប់ធ្វើការងារ ដែលត្រូវបានគេផ្តល់អោយ ។ អ្នកផ្តល់ពត៌មាន ៦១% និយាយថា កិច្ចសន្យាគួរតែផ្តល់អោយនៅតំលៃទាបបំផុត ហើយទទួលបាននូវគុណភាពការងារល្អ (តារាងទី៤៩) ។

| លេខសំនួរ | ចំនួនអ្នកឆ្លើយ ១៩៩៨ |
|---|---|

48- តើការអនុវត្តន៍ទៅលើការគ្រប់គ្រង របស់រដ្ឋាភិបាលពេលបច្ចុប្បន្ន នៅក្នុងប្រទេស កម្ពុជា មានលក្ខណៈសមស្របសំរាប់រយៈពេល ០៥ ឆ្នាំ នៅមុខទៀតដែររឺទេ ?

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1664 | 83.3 |
| ទេ | 306 | 15.3 |
| គ្មានចំលើយ | 28 | 1.4 |
| សរុប | 1998 | 100 |

49- តើរដ្ឋាភិបាល កំពុងបង្កើនមធ្យោបាយដែលអាចអោយ ប្រជាជនកម្ពុជាចូល រួមចំណែកក្នុងការបង្កើតគោលនយោបាយដែររឺទេ ?

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1674 | 83.8 |
| ទេ | 300 | 15 |
| គ្មានចំលើយ | 24 | 1.2 |
| សរុប | 1998 | 100 |

50- តើច្បាប់ទាំងអស់ត្រូវបានបន្តប្រតិបត្តិនៅក្នុងប្រទេសកម្ពុជាដែររឺទេ ?

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1693 | 84.7 |
| ទេ | 281 | 14.1 |
| គ្មានចំលើយ | 24 | 1.2 |
| សរុប | 1998 | 100 |

51- តើលោក លោកស្រី បានទទួលពត៌មានគ្រប់គ្រាន់ អំពីការចំណាយ របស់រដ្ឋាភិបាលដែររឺទេ ?

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 566 | 28.3 |
| ទេ | 1408 | 70.5 |
| គ្មានចំលើយ | 24 | 1.2 |
| សរុប | 1998 | 100 |

52- ការសូកប៉ាន់គឺជាមធ្យោបាយដ៏សាមញ្ញទៅហើយ ដើម្បីអោយគេធ្វើអ្វីមួយនៅក្នុងប្រទេសកម្ពុជា ។

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1149 | 57.5 |
| ទេ | 812 | 40.6 |
| គ្មានចំលើយ | 37 | 1.9 |
| សរុប | 1998 | 100 |

| លេខសំនួរ | ចំនួនអ្នកឆ្លើយ ១៩៩៨ |
|---|---|

53- អ្នកម៉ៅការ ត្រូវចំណាយ កំរៃជើងសារ ( កុំមុយស្យុង) ដើម្បីបានកុងត្រាមកធ្វើ ។

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1006 | 50.4 |
| ទេ | 951 | 47.6 |
| គ្មានចំលើយ | 41 | 2.1 |
| សរុប | 1998 | 100 |

54- ជាការត្រឹមត្រូវហើយចំពោះមន្ត្រីរាជការដែលមានប្រាក់ខែតិច បានទទួលប្រាក់កំរៃជើងសារ ។

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1052 | 52.7 |
| ទេ | 916 | 45.8 |
| គ្មានចំលើយ | 30 | 1.5 |
| សរុប | 1998 | 100 |

55-ប្រព័ន្ធហិរញ្ញវត្ថុបច្ចុប្បន្នរបស់កម្មវិធីសិលាមានន័យថា មនុស្សដែលចង់លួចថវិកា ពីគំរោង នឹងត្រូវចាប់ខ្លួន ។

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1416 | 70.9 |
| ទេ | 553 | 27.7 |
| គ្មានចំលើយ | 29 | 1.5 |
| សរុប | 1998 | 100 |

56-តើការជ្រើសរើសយកនរណាម្នាក់ សំរាប់ម៉ៅការ ដោយសារពួកគេមានទំនាក់ទំនងជាមួយមន្ត្រីមានអំណាច តើអាចទទួលយកបានដែររឺទេ ?

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 365 | 18.3 |
| ទេ | 1614 | 80.8 |
| គ្មានចំលើយ | 19 | 1 |
| សរុប | 1998 | 100 |

57- កិច្ចសន្យាការងារដែលត្រូវទទួលរាប់រងនៅតាមឃុំ/សង្កាត់ គួរតែត្រូវបាន :

| | ចំនួន | ភាគរយ |
|---|---|---|
| ប្រគល់ទៅអោយអ្នកម៉ៅការដែលល្អបំផុតនៅក្នុងតំបន់ ។ | 1185 | 59.3 |
| ផ្សព្វផ្សាយតាមប្រព័ន្ធឃោសនា ។ | 1017 | 50.9 |
| ប្រគល់ទៅអោយអ្នកទុកចិត្ត ដែលអាចទទួលខុសត្រូវលើការងារនេះបាន ។ | 988 | 49.4 |
| ផ្សព្វផ្សាយលើក្តារប្រកាសពត៌មាន នៅតាមការិយាល័យរបស់រដ្ឋាភិបាល ។ | 972 | 48.6 |
| ប្រគល់ទៅអោយអ្នកម៉ៅការដែលត្រូវការការងារធ្វើ ។ | 333 | 16.7 |
| ប្រគល់ទៅអោយអ្នកម៉ៅការ ដែលត្រូវបានសំរេចជ្រើសរើសដោយមានការឯកភាព ។ | 1217 | 60.9 |
| ប្រគល់ជូនដោយការយកតំលៃទាប ប៉ុន្តែផ្តល់គុណភាពជាក់លាក់ ។ | 1395 | 69.8 |
| គ្មានចំលើយ | 9 | 0.5 |

| លេខសំនួរ | ចំនួនអ្នកឆ្លើយ ១៩៩៨ |
|---|---|

## ជំនឿ

អ្នកផ្តល់ពត៌មាន ហាក់ដូចជាមានជំនឿថា រដ្ឋាភិបាលកំពុងតែធ្វើការ ដើម្បីជាប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ ។ អ្នកផ្តល់ពត៌មាន ៨៧% បានផ្តល់នូវចំលើយស្រប ក្រោមតារាង ៥០ ។ ពួកគេជឿជាក់ថា រដ្ឋាភិបាលមូលដ្ឋាន ដែលបានជ្រើសរើសដោយការបោះឆ្នោត លក្ខណៈប្រជាធិបតេយ្យ និងជំរុញអោយមានការអភិវឌ្ឍន៍មូលដ្ឋាន ប្រសើរជាងមន្ត្រីតែងតាំង ។ អ្នកផ្តល់ពត៌មាន ៩៧% បានពត៌មានស្រប (តារាងទី ៥១) ។ អ្នកផ្តល់ ៨៨% បាននិយាយថា ពួកគេមានជំនឿថា គួតែមានការកំណត់តំលៃជាក់លាក់ សំរាប់សេវារដ្ឋាភិបាលទាំងអស់ (តារាងទី ៥២) ។ អ្នកផ្តល់ពត៌មាន ៩១% ក៏មានជំនឿដែរថា រឹតតែមានការទទួលខុសត្រូវខ្លាំងឡើងចំពោះមូលនិធិ តាំងពីមានការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់នៅឆ្នាំ ២០០២ (តារាងទី ៥៤) ។ ពួកគេមានជំនឿជឿជាក់ ៨៩% ថា ការធ្វើផែនការនៅក្នុងប្រទេសកម្ពុជា គឺបានបំពេញតំរូវការរបស់ស្ត្រី និងជនងាយរងគ្រោះបំផុតនៅក្នុងសហគមន៍ (តារាងទី ៥៥) ។ អ្នកផ្តល់ពត៌មាន ៧៩% មិនបានគិតថា មានស្ត្រីគ្រប់គ្រាន់នៅក្នុងតំណែង ធ្វើការសំរេចនូវគោលនយោបាយនៅក្នុងប្រទេសកម្ពុជាទេ (តារាងទី ៥៦) ។

អ្នកផ្តល់ពត៌មាន មិនមានការពេញចិត្តអំពីជំនឿរបស់ពួកគេ នៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់រដ្ឋាភិបាល ។ អ្នកផ្តល់ពត៌មាន ៦៦% មានជំនឿថា រដ្ឋាភិបាលកំពុងធ្វើការគ្រប់គ្រាន់ ដើម្បីពង្រឹងសេដ្ឋកិច្ច (តារាងទី ៥៧) ហើយ ៥៦% គិតថា មន្ត្រីរដ្ឋាភិបាលកំពុងធ្វើកិច្ចការគ្រប់គ្រាន់ ដើម្បីជួយសំរួលដល់អាជីវកម្មខ្នាតតូច (តារាងទី ៥៨) ។ ពួកគេមានទស្សនៈវេជ្ជមានអំពីបញ្ហាសន្តិសុខ ។ មន្ត្រី ៨៥% មានជំនឿថា ប្រជាពលរដ្ឋត្រូវបានគេអោយបញ្ចេញទស្សនៈ ជាសាធារណៈ ទោះបីពួកគេបញ្ចេញទស្សនៈរិះគន់រដ្ឋាភិបាលក៏ដោយ (តារាងទី ៥៩) ។ ទោះជាយ៉ាងណាក៏ដោយមន្ត្រី ៨៨% មានជំនឿថា រដ្ឋាភិបាលអាចធ្វើកិច្ចការបន្ថែមទៀត ដើម្បីធ្វើអោយប្រជាពលរដ្ឋមានសុវត្ថិភាព និងសន្តិសុខ (តារាងទី ៦០) ។

**58- តើលោក លោកស្រី ជឿថារដ្ឋាភិបាលកំពុងធ្វើការងារ ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋគ្រប់រូបដែរឬទេ ??**

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1743 | 87.2 |
| ទេ | 239 | 12 |
| គ្មានចំលើយ | 16 | 0.8 |
| សរុប | 1998 | 100 |

**59- តើលោក លោកស្រីជឿថា មន្ត្រីណាមួយ ដែលបានបញ្ជាក់ដូចខាងក្រោមនេះ នឹងលើកកំពស់ការអភិវឌ្ឍន៍មូលដ្ឋានបានប្រសើរជាងមុន ?**

| | ចំនួន | ភាគរយ |
|---|---|---|
| មន្ត្រីមូលដ្ឋាន ដែលជ្រើសរើសតាមរយៈការបោះឆ្នោតប្រជាធិបតេយ្យ ។ | 1928 | 96.5 |
| មន្ត្រីដែលតែងតាំង ។ | 49 | 2.5 |
| គ្មានចំលើយ | 21 | 1.1 |
| សរុប | 1998 | 100 |

| លេខសំនួរ | ចំនួនអ្នកឆ្លើយ ១៩៩៨ |
|---|---|

60- តើលោក លោកស្រី ជឿថា គួរតែមានតំណែលកំណត់ជាក់លាក់ សំរាប់សេវារបស់រដ្ឋាភិបាលដែររឺទេ ?

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1756 | 87.9 |
| ទេ | 217 | 10.9 |
| គ្មានចំលើយ | 25 | 1.3 |
| សរុប | 1998 | 100 |

61- តើលោក លោកស្រីជឿថា មានការទទួលខុសត្រូវខ្លាំងជាងមុន ទៅលើថវិកាតាំងពីការបោះឆ្នោតឃុំ/សង្កាត់ នៅឆ្នាំ ២០០២ ។

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1827 | 91.4 |
| ទេ | 152 | 7.6 |
| គ្មានចំលើយ | 19 | 1 |
| សរុប | 1998 | 100 |

62 -តើលោក លោកស្រីជឿថា ការបោះឆ្នោតក្រុមប្រឹក្សាឃុំ បានបង្កើននូវកំរិតនៃការចូលរួមរបស់
អ្នកភូមិក្នុងកិច្ចអភិវឌ្ឍន៍ដែររឺទេ ?

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1913 | 95.7 |
| ទេ | 70 | 3.5 |
| គ្មានចំលើយ | 15 | 0.8 |
| សរុប | 1998 | 100 |

63- តើលោក លោកស្រីជឿថា ការរៀបចំផែនការនៅក្នុងប្រទេសកម្ពុជា របស់លោក
លោកស្រីបង្ហាញនូវតំរូវការរបស់ស្ត្រី និងអ្នកទន់ខ្សោយបំផុតនៅក្នុងភូមិដែររឺទេ ?

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1776 | 88.9 |
| ទេ | 207 | 10.4 |
| គ្មានចំលើយ | 15 | 0.8 |
| សរុប | 1998 | 100 |

64- តើលោក លោកស្រី គិតថាមានចំនួនស្ត្រីគ្រប់គ្រាន់ដែររឺទេ នៅក្នុងមុខតំណែងនៃការ បង្កើតគោលនយោបាយនៅក្នុងប្រទេសកម្ពុជា ?

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 405 | 20.3 |
| ទេ | 1582 | 79.2 |
| គ្មានចំលើយ | 11 | 0.6 |
| សរុប | 1998 | 100 |

| លេខសំនួរ | ចំនួនអ្នកឆ្លើយ ១៩៩៨ |
|---|---|

65- តើរដ្ឋាភិបាលកំពុងធ្វើការងារគ្រប់គ្រាន់ ដើម្បីធ្វើអោយសេដ្ឋកិច្ចមានភាពរឹងមាំដែររឺទេ ?

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1325 | 66.3 |
| ទេ | 649 | 32.5 |
| គ្មានចំលើយ | 24 | 1.2 |
| សរុប | 1998 | 100 |

66- តើមន្ត្រីរាជការកំពុងធ្វើការងារគ្រប់គ្រាន់ ដើម្បីជួយសំរួលដល់ប្រជាពលរដ្ឋដែល ធ្វើមុខជំនួញខ្នាតតូចដែររឺទេ ?

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1127 | 56.4 |
| ទេ | 847 | 42.4 |
| គ្មានចំលើយ | 24 | 1.2 |
| សរុប | 1998 | 100 |

67- តើប្រជាពលរដ្ឋត្រូវបានអនុញ្ញាត អោយបញ្ចេញមតិ-យោបល់របស់ខ្លួនជាសាធារណៈដែររឺទេ?
ទោះបីពួកគេបញ្ចេញមតិ-យោបល់ រិះគន់រដ្ឋាភិបាលក៏ដោយ ។

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1704 | 85.3 |
| ទេ | 278 | 13.9 |
| គ្មានចំលើយ | 16 | 0.8 |
| សរុប | 1998 | 100 |

68- តើរដ្ឋាភិបាលអាចធ្វើអ្វីបន្ថែមទៀត ដើម្បីអោយប្រជាពលរដ្ឋទាំងអស់មានអារម្មណ៍ថា
ខ្លួនគេមានសុវត្ថិភាព និងសន្តិសុខ ដែររឺទេ ?

| | ចំនួន | ភាគរយ |
|---|---|---|
| បាទ / ចាស | 1753 | 87.7 |
| ទេ | 233 | 11.7 |
| គ្មានចំលើយ | 12 | 0.6 |
| សរុប | 1998 | 100 |

*ឃ-ការធ្វើវិភាគប្រៀបធៀបរវាងការធ្វើអង្កេតបន្តឆ្នាំ ២០០៤ និងការវាយតំលៃឆ្នាំ ២០០១ នៃចំណេះដឹង ឥរិយាបទ ការអនុវត្តន៍ និងជំនឿ ស្តីអំពីអភិបាលកិច្ចល្អ ។*

*(សូមចំណាំថា ១២សំនួរត្រូវបានកាត់ចេញពីបញ្ជីសំនួរធ្វើអង្កេតឆ្នាំ ២០០១ សំរាប់ធ្វើការអង្កេតឆ្នាំ ២០០៤ ) ចំពោះប្រធានបទមិនមានការទាក់ទងគ្នាទេ ។ សំនួរ ២៩ . ៣០ . ៤៦ . ៥៨ . ៦២ . ៦៣ . ៦៥ . ៦៨ . ៧២ . ៧៣ . ៧៤ និង ៧៧ គឺមាននៅក្នុងបញ្ជីសំនួរឆ្នាំ ២០០១ សំនួរទាំងនេះនឹងមិនយកធ្វើការប្រៀបធៀបទេ ) ។*

*លក្ខណៈនៃប្រជាពលរដ្ឋដែលធ្វើការអង្កេត*

ចំនួនមនុស្សដែលបានធ្វើអង្កេតទាំងនៅក្នុងឆ្នាំ ២០០៤ និងឆ្នាំ ២០០១ គឺមានអ្នកផ្តល់ពត៌មានចំនួន ១៥៥៨នាក់ នៅឆ្នាំ ២០០៤ និង ១៤៥៣នាក់ នៅឆ្នាំ ២០០១ ។ នៅឆ្នាំ ២០០៤ ភាគរយនៃចំនួនបុរស បើប្រៀបធៀបនឹងភាគរយនៃចំនួនស្ត្រី (តារាងទី១) គឺខ្ពស់ជាង ១០% ។ ភាគរយនេះ មិនបានឆ្លុះបញ្ចាំងអោយឃើញនូវភាពទន់ខ្សោយ នៃគោលបំណងនៃការធ្វើអង្កេត ដែលផ្តល់បញ្ជីសំណួរដល់ស្ត្រី ដែលជាមន្ត្រី ប៉ុន្តែវាជាការកាត់បន្ថយបន្តិចនៅចំនួនភាគរយទាំងស្រុងនៃស្ត្រីដែលជ្រើសរើសដោយការបោះឆ្នោត និងស្ត្រីតែងតាំងដោយមានឋានៈផ្លូវការ (ភាគរយទាប នៃស្ត្រី ត្រូវបានជ្រើសរើសដោយការបោះឆ្នោត អោយធ្វើជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់) ។ យើងដឹងថា នៅក្នុងចន្លោះអាយុ ១៨-៣៤ឆ្នាំ នៅឆ្នាំ ២០០៤ មាន ១៦% ហើយនៅឆ្នាំ ២០០១ មាន ១១% ។ ចំនួនលើសនៃមន្ត្រីវ័យក្មេង គឺប្រហែលជាដោយសារមានការជ្រើសរើសស្មៀនឃុំ-សង្កាត់ថ្មី ។ នៅក្នុងចន្លោះអាយុ ៣៥-៦៤ឆ្នាំ នៅឆ្នាំ ២០០៤ មាន ៧៥% ហើយនៅឆ្នាំ ២០០១ មាន ៨៦% ។ ចំណែកឯមន្ត្រីដែលមានអាយុលើសពី ៦៥ឆ្នាំ នៅឆ្នាំ ២០០៤ មាន ៥% ហើយនៅឆ្នាំ ២០០១ មាន ២% (តារាងទី២) ។ ដូច្នេះ ទោះបីជាមានចំនួនលើស នៃមន្ត្រីដែលជាប់ឆ្នោត បន្ទាប់ពីការបោះឆ្នោតឃុំ-សង្កាត់ ឆ្នាំ ២០០២ ក៏ដោយ វានៅជាករណីមួយ ដែលចំនួនភាគច្រើនលើសលុបនៃមន្ត្រីតែងតាំង និងមន្ត្រីជាប់ឆ្នោត គឺមានចន្លោះពី ៣៤-៦៥ ឆ្នាំ ហើយប្រហែលជាធ្លាប់បានទទួលនូវការជួយទំនុកបំរុងនៅក្រោមរដ្ឋាភិបាល ដែលរបបគ្រប់គ្រងតាមរបៀបប្រទេសវៀតណាម នាទស្សវត្ស ៨០ ។ ទោះបីជាពួកគេនៅក្រៅប្រទេសក៏ដោយ ក៏គ្មានជំរើសណាមួយដែរ ។ នៅទស្សវត្ស ៨០ គឺមានតែបក្សមួយគត់ រួមមានអ្នកឆ្វេងនិយមផ្នែកនយោបាយ ឆ្វេងនិយមផ្នែកសន្តិសុខ និងឆ្វេងនិយមផ្នែករដ្ឋបាល ចំពោះវិស័យអប់រំរបស់ពួកគេ នៅឆ្នាំ ២០០៤ និងឆ្នាំ ២០០១ គឺមានគំរូដូចគ្នា ដូចដែលបានបង្ហាញនៅក្នុងតារាង៣ ។ នៅក្នុងឆ្នាំ ២០០៤ ៣៨% បានបញ្ចប់បឋមសិក្សា ហើយនៅក្នុងឆ្នាំ ២០០១ ៣៩% បានបញ្ចប់បឋមសិក្សា ។ នៅឆ្នាំ ២០០៤ ២៦% បានសិក្សានៅអនុវិទ្យាល័យ ហើយនៅឆ្នាំ ២០០១ ៣០% បានសិក្សានៅអនុវិទ្យាល័យ ។ នៅឆ្នាំ ២០០៤ ២៧% បានសិក្សានៅវិទ្យាល័យ ហើយនៅឆ្នាំ ២០០១ ១៥% បានសិក្សានៅវិទ្យាល័យ ។ នៅឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មានចំនួន ៥%

បានសិក្សានៅសកលវិទ្យាល័យ ហើយនៅឆ្នាំ ២០០១ ៦% បានសិក្សានៅសកលវិទ្យាល័យ (តារាងទី៣) ។ ពួកគេបានទទួលនូវចំនួននៃការបណ្តុះបណ្តាលផ្នែកបច្ចេកទេសជំនាញវិជ្ជាជីវៈប្រហាក់ប្រហែលគ្នា (តារាងទី៤)។ ការបោះឆ្នោតឆ្នាំ ២០០២ មិនបានបញ្ចូលនៅក្រុមមន្ត្រីថ្មី និងមានការិតវប្បធម៌ខ្ពស់ជាងនេះទេ ។ គេបានសង្ស័យថា មន្ត្រីតែងតាំងដែលមានវ័យចំណាស់ជាច្រើន បានឈរឈ្មោះសំរាប់ការបោះឆ្នោត ប្រកបដោយជោគជ័យនៅឆ្នាំ ២០០២ ។

ចំពោះអ្នកផ្តល់ពត៌មាននៅក្នុងការអង្កេតទាំងពីរនេះ ប្រហែលជាមានចំនួនដដែលនៅឯថ្នាក់ជាតិ ២% នៅឆ្នាំ ២០០៤ និង ២% នៅឆ្នាំ ២០០១ មានចំនួនលើសគ្នា នៅឯថ្នាក់ខេត្ត (៦% នៅឆ្នាំ ២០០៤ ១៥%នៅឆ្នាំ ២០០១) មានចំនួនលើសពីគ្នានៅថ្នាក់ស្រុក (១៣% នៅឆ្នាំ ២០០៤ និង ២១% នៅឆ្នាំ ២០០១) ប៉ុន្តែនៅឆ្នាំ ២០០៤ មានចំនួនលើសច្រើននៅឯថ្នាក់ឃុំ-សង្កាត់ (ក្រុមប្រឹក្សាឃុំ-សង្កាត់ ៥៩% ស្មៀនឃុំ-សង្កាត់ ១៩% នៅឆ្នាំ ២០០៤ ហើយ ៥០% នៅឆ្នាំ ២០០១ រួមមានមេឃុំ និងស្មៀនឃុំ) (តារាងទី៥) ។ នៅឆ្នាំ ២០០១ ក្រសួងមហាផ្ទៃបានតែងតាំងអ្នកផ្តល់ពត៌មានទាំងអស់ ប៉ុន្តែនៅឆ្នាំ ២០០៤ ប្រជាពលរដ្ឋ បានបោះឆ្នោតជ្រើសរើសអ្នកផ្តល់ពត៌មានស្ទើរតែ ៦០% តាមលក្ខណៈប្រជាធិបតេយ្យ ។ លក្ខណៈខុសគ្នា និងលក្ខណៈប្រហាក់ប្រហែលគ្នា ឬទស្សនៈមានសារៈសំខាន់ណាស់ ចំពោះរយៈពេលក្នុងការបំរើការងារអោយរដ្ឋាភិបាល (តារាង ៦-៧) ។ នៅឆ្នាំ ២០០៤ ៣៧% បាននិយាយថា ពួកគេបានធ្វើការងារពី ២-៥ឆ្នាំ ហើយនៅឆ្នាំ ២០០១ មានតែ ១០% ដែលនិយាយថា ពួកគេធ្វើការពី ២ ទៅ ៥ឆ្នាំ ។ ចំនួនមន្ត្រីដែលបានចាប់ផ្តើមធ្វើការងារបំរើរដ្ឋាភិបាល តាំងពីមានការបោះឆ្នោតឆ្នាំ ២០០២ បានពន្យល់អំពីបញ្ហានេះ ។ អ្នកផ្តល់ពត៌មានដែលបានបំរើការងារអោយរដ្ឋាភិបាលចាប់ពី ៦-៤៥ឆ្នាំ មាន ៦១% នៅឆ្នាំ ២០០៤ ហើយ ៩៦% នៅឆ្នាំ ២០០១ យើងបានដឹងថា មន្ត្រីស្ទើរតែទាំងអស់ បានទទួលនូវការបណ្តុះបណ្តាលតាមគំរូប្រទេសវៀតណាម ហើយឥឡូវនេះយើងដឹងថា មន្ត្រីមានតែប្រហែល ៦០% ប៉ុណ្ណោះ នៅឆ្នាំ ២០០៤ នេះ ដែលធ្លាប់មានការបណ្តុះបណ្តាលទៅតាមគំរូប្រទេសវៀតណាម ។ ចំពោះអាយុរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ភាគច្រើន យើងមានមន្ទិលសង្ស័យថា ពួកគេភាគច្រើនមានជីវប្រវត្តិប្រហាក់ប្រហែលគ្នា អ្នកបានផ្តល់ពត៌មាននៅក្នុងការធ្វើអង្កេតទាំងពីរ ហាក់ដូចជាមានទ្រព្យសម្បត្តិផ្ទាល់ខ្លួន ។ នៅឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មាន ៨% បានអះអាងថា ពួកគេមិនផ្ទះផ្ទាល់ខ្លួន ហើយនៅឆ្នាំ ២០០១ មានតែ ៤% ប៉ុណ្ណោះ (នៅឆ្នាំ ២០០៤ ចំនួននៃស្មៀនឃុំវ័យក្មេង ដែលកំពុងរស់នៅជាមួយឪពុកម្តាយរបស់គេនៅឡើយ ) ហើយនៅឆ្នាំ ២០០៤ ៨៤% មានផ្ទះផ្ទាល់ខ្លួនមួយ ហើយនៅឆ្នាំ ២០០១ ៩៣% មានផ្ទះផ្ទាល់ខ្លួនមួយ (តារាងទី៨) ។ ទាក់ទងទៅនឹងកម្មសិទ្ធិដីធ្លី នៅឆ្នាំ ២០០៤ ១៥% បាននិយាយថា ពួកគេមិនមានដីដែលជាកម្មសិទ្ធិផ្ទាល់ខ្លួន ហើយនៅឆ្នាំ ២០០១ ២១%មិនមែនដីដែលជាកម្មសិទ្ធិផ្ទាល់ខ្លួន ។ អ្នកផ្តល់ពត៌មានផ្សេង

ទៀត នៅក្នុងការអង្កេតទាំងពីរ មានចំនួនដីដែលជាកម្មសិទ្ធិផ្សេងៗគ្នា ប៉ុន្តែនៅក្នុងឆ្នាំ ២០០៤ និងឆ្នាំ ២០០១ មានតែ ៣%ទេ ដែលមានដីលើសពី ៥ហិចតា ( តារាងទី៩) ។

តារាងទី១០ បើសួរអ្នកផ្តល់ពត៌មាន ថាតើពួកគេធ្លាប់បានទទួលនូវការបណ្តុះបណ្តាល ស្តីពីអភិបាលកិច្ចនោះទេ ។ នៅឆ្នាំ ២០០៤ ៨៥% បាននិយាយថា បាន ហើយឆ្នាំ ២០០១ មានតែ ៦១% ប៉ុណ្ណោះ ដែលបានទទួលនូវការបណ្តុះបណ្តាលស្តីពីអភិបាលកិច្ច ។ នៅឆ្នាំ ២០០៤ ៧៤% បាននិយាយថា ការបណ្តុះបណ្តាលបានផ្តល់អោយ ២ ឆ្នាំកន្លងទៅហើយ ហើយនៅឆ្នាំ ២០០១ ៥១% បាននិយាយថា ពួកគេបានទទួលនូវការបណ្តុះបណ្តាលស្តីអំពីអភិបាលកិច្ច ។ នៅឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មានប្រហែល ៩១% បាននិយាយថា វគ្គបណ្តុះបណ្តាលរបស់ពួកគេបានរៀបចំដោយភ្នាក់ងាររបស់រដ្ឋាភិបាល ហើយនៅឆ្នាំ ២០០១ មានតែ ៨០% ប៉ុណ្ណោះ ដែលនិយាយថា វគ្គបណ្តុះបណ្តាលរបស់ពួកគេបានរៀបចំ ដោយភ្នាក់ងាររបស់រដ្ឋាភិបាល ហើយ ២០%ផ្សេងទៀត បាននិយាយថា ការបណ្តុះបណ្តាលផ្តល់អោយដោយអង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និងស្ថាប័នផ្សេងៗទៀត (តារាងទី១២) ។ យ៉ាងណាក៏ដោយអ្វីដែលគួរអោយចាប់អារម្មណ៍នោះ គឺថានៅឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មាន ៥៦% បាននិយាយថា ពួកគេមិនបានទទួលនូវការបណ្តុះបណ្តាលគ្រប់គ្រាន់ ដើម្បីធ្វើការងាររបស់ពួកគេបានល្អ ហើយនៅឆ្នាំ ២០០១ មានតែចំនួន ៤២% ប៉ុណ្ណោះ មិនបានទទួលនូវការបណ្តុះបណ្តាលគ្រប់គ្រាន់ ដើម្បីធ្វើការងាររបស់ពួកគេបានល្អ ( តារាងទី១៣) ។

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|
| **9-ភេទ** | | |
| ប្រុស | 83.8%<br>1675 | 78.6%<br>1174 |
| ស្រី | 16.2%<br>323 | 21.4%<br>319 |
| **10-អាយុ** | | |
| 18-24 | 5.9%<br>118 | 1.1%<br>16 |
| 25-34 | 9.9%<br>197 | 9.8%<br>147 |
| 35-44 | 17.5%<br>350 | 22.6%<br>337 |
| 45-54 | 37.4%<br>747 | 48.7%<br>727 |
| 55-64 | 24%<br>480 | 15.1%<br>226 |

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|
| >65 | 5%<br>100 | 1.7%<br>26 |
| គ្មានចំលើយ | 0.3%<br>6 | 0.9%<br>13 |

11- កំរិតវប្បធម៌

| | | |
|---|---|---|
| មិនដែលរៀនសោះ | 0%<br>0 | 0.5%<br>8 |
| បឋមសិក្សា | 37.9%<br>757 | 38.9%<br>581 |
| អនុវិទ្យាល័យ | 26.3%<br>526 | 29.7%<br>444 |
| វិទ្យាល័យ | 27.2%<br>543 | 19.3%<br>288 |
| មធ្យមសិក្សាបច្ចេកទេស | 3.6%<br>72 | 5.4%<br>80 |
| ឧត្តមសិក្សា | 4%<br>79 | 5.3%<br>79 |
| អនុបណ្ឌិត / បណ្ឌិត | 0.9%<br>17 | 0.6%<br>9 |
| គ្មានចំលើយ | 0.2%<br>4 | 0.3%<br>4 |

12- តើធ្លាប់ឆ្លងកាត់វគ្គបណ្តុះបណ្តាល មុខវិជ្ជាជីវៈជំនាញបច្ចេកទេសអស់រយៈពេលប៉ុន្មាន ?

| | | |
|---|---|---|
| 1-29day | 12.3%<br>245 | 5.8%<br>87 |
| 1-11months | 33.4%<br>668 | 34.4%<br>514 |
| 1-3years | 12.5%<br>250 | 11.3%<br>169 |
| 4-8years | 20.7%<br>54 | 5.5%<br>82 |
| > 9years | 0.3%<br>6 | 0.3%<br>4 |
| មិនដែលរៀន | 38.8%<br>775 | 31.5%<br>471 |

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|
| គ្មានចំលើយ | 0%<br>0 | 11.1%<br>166 |

**13- តើ លោក លោកស្រី បំរើការងារនៅក្នុងជួររដ្ឋាភិបាលនេះថ្នាក់អ្វីដែរ ?**

| | | |
|---|---|---|
| ថ្នាក់ជាតិ | 1.8%<br>35 | 2.1%<br>32 |
| ថ្នាក់ខេត្ត | 5.5%<br>110 | 14.7%<br>219 |
| ថ្នាក់ស្រុក | 13.4%<br>268 | 20.6%<br>307 |
| ថ្នាក់ឃុំ | 0%<br>0 | 50.4%<br>752 |
| ថ្នាក់ឃុំ : ក្រុមប្រឹក្សាឃុំ/សង្កាត់ដែលទើបតែត្រូវបានបោះឆ្នោតជ្រើសរើស | 59.4%<br>1186 | 0%<br>0 |
| ថ្នាក់ឃុំ : ស្មៀនឃុំ/ស្មៀនសង្កាត់ | 19.1%<br>382 | 0%<br>0 |
| ថ្នាក់ភូមិ | 0%<br>0 | 7.5%<br>112 |
| សង្គមស៊ីវិល | 0%<br>0 | 2.1%<br>32 |
| គ្មានចំលើយ | 0.9%<br>17 | 2.6%<br>39 |

**14- តើលោក លោកស្រី បំរើការងារ ក្នុងជួររដ្ឋាភិបាលប៉ុន្មានឆ្នាំហើយ ?**

| | | |
|---|---|---|
| 1-12 ខែ | 1%<br>20 | 2.3%<br>34 |
| 2-5 ឆ្នាំ | 36.5%<br>730 | 9.6%<br>143 |
| 6-10 ឆ្នាំ | 7.6%<br>152 | 7.9%<br>118 |
| 11-19 ឆ្នាំ | 15.3%<br>306 | 27.8%<br>415 |
| 20-30 ឆ្នាំ | 36.4%<br>728 | 49%<br>731 |
| 31-45 ឆ្នាំ | 2.2%<br>43 | 1.4%<br>21 |

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|
| មិនមែនរដ្ឋាភិបាល | 0%<br>0 | 1.2%<br>18 |
| គ្មានចំលើយ | 1%<br>19 | 0.9%<br>13 |

**15- តើលោក លោកស្រី ចាប់ផ្ដើមបំរើការងារ ក្នុងជួររដ្ឋាភិបាលនៅឆ្នាំណា ?**

| | | |
|---|---|---|
| 1960-1969 | 1.6%<br>31 | 1.5%<br>23 |
| 1970-1979 | 20.6%<br>412 | 31.4%<br>469 |
| 1980-1989 | 30.5%<br>610 | 44.7%<br>668 |
| 1990-1995 | 5.6%<br>112 | 7.8%<br>117 |
| 1996-2001 | 13.4%<br>268 | 12.6%<br>188 |
| >2001 | 27.2%<br>544 | 0%<br>0 |
| គ្មានចំលើយ | 1.1%<br>21 | 1.9%<br>28 |

**16- តើលោក លោកស្រី មានផ្ទះផ្ទាល់ខ្លួនចំនួនប៉ុន្មាន ?**

| | | |
|---|---|---|
| អត់ផ្ទះ | 8.3%<br>165 | 3.6%<br>54 |
| 1 ផ្ទះ | 88.3%<br>1765 | 92.7%<br>1384 |
| 2 ផ្ទះ | 2.6%<br>51 | 2.6%<br>39 |
| 3 ផ្ទះ | 0.3%<br>6 | 0.3%<br>5 |
| 4 ផ្ទះ | 0.2%<br>4 | 0%<br>0 |
| 9 ផ្ទះ | 0.1%<br>1 | 0%<br>0 |
| គ្មានចំលើយ | 0.3%<br>6 | 0.8%<br>11 |

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
| --- | --- | --- |

17- តើលោក លោកស្រី មានដីប៉ុន្មានហិចតា រឺ ម៉ែត្រការ៉េ ?

| | | |
| --- | --- | --- |
| <1000 | 8.9%<br>178 | 2.3%<br>34 |
| 1001-5000 | 11.8%<br>236 | 9.8%<br>146 |
| 5001-8000 | 5.3%<br>106 | 3.5%<br>52 |
| 8001-9500 | 1.3%<br>25 | 0.7%<br>11 |
| 9501-10000 | 15.1%<br>301 | 16.3%<br>243 |
| 10001-12500 | 2%<br>39 | 0.9%<br>14 |
| 12501-15000 | 8.5%<br>170 | 7.8%<br>117 |
| 15001-20000 | 12.6%<br>251 | 15.9%<br>238 |
| 20001-30000 | 9.4%<br>188 | 9.7%<br>145 |
| 30001-50000 | 7.1%<br>142 | 8.8%<br>131 |
| >50000 | 3.2%<br>63 | 3.3%<br>50 |
| គ្មានដី | 15%<br>299 | 20.9%<br>312 |

18-តើលោក លោកស្រី ធ្លាប់បានរៀនវគ្គបណ្តុះបណ្តាលជាមួយកម្មវិធីសិលា ឬអង្គការក្រៅរដ្ឋាភិបាល NGO ស្តីអំពីអភិបាលកិច្ចល្អ ដែរឬទេ ?

| | | |
| --- | --- | --- |
| បាទ / ចាស | 85.3%<br>1705 | 60.5%<br>903 |
| ទេ | 13.9%<br>278 | 37.8%<br>565 |
| គ្មានចំលើយ | 0.8%<br>15 | 1.7%<br>25 |

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|

19- ប្រសិនបើធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាល តើទើបតែរយៈពេល ២ឆ្នាំកន្លងទៅនេះឬ ?

| | | |
|---|---|---|
| បាទ / ចាស | 73.6%<br>1471 | 50.8%<br>758 |
| ទេ | 24.5%<br>489 | 44.5%<br>665 |
| គ្មានចំលើយ | 1.9%<br>38 | 4.7%<br>70 |

20- តើអ្នកណាបណ្តុះបណ្តាល លោក លោកស្រី អោយចេះធ្វើការងារបច្ចុប្បន្ននេះ ?

| | | |
|---|---|---|
| រដ្ឋាភិបាល | 21.3%<br>425 | 70.7%<br>1056 |
| កម្មវិធីសិលា | 40%<br>800 | 9.7%<br>145 |
| ក្រសួងមហាផ្ទៃ | 13.8%<br>275 | 0%<br>0 |
| ថ្នាក់ជាតិ | 2.1%<br>41 | 0%<br>0 |
| ថ្នាក់ខេត្ត | 5.3%<br>106 | 0%<br>0 |
| ថ្នាក់ស្រុក | 8.8%<br>176 | 0%<br>0 |
| អង្គការក្រៅរដ្ឋាភិបាល | 3.7%<br>74 | 2.7%<br>40 |
| មេឃុំ | 1.1%<br>21 | 0.1%<br>1 |
| រដ្ឋាភិបាល + CDRI | 0%<br>0 | 0.1%<br>1 |
| Humans Rights NGO | 0%<br>0 | 2.6%<br>39 |
| Oxfam | 0%<br>0 | 0.1%<br>2 |
| Party / Company | 0%<br>0 | 0.2%<br>3 |
| UNFPA | 0%<br>0 | 0.1%<br>1 |

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|
| UNHCR | 0%<br>0 | 0.1%<br>1 |
| UNICEF | 0%<br>0 | 0.1%<br>2 |
| រដ្ឋាភិបាលវៀតណាម | 0%<br>0 | 0.1%<br>1 |
| អង្គការស្បៀងអាហារពិភពលោក | 0%<br>0 | 0.1%<br>1 |
| អង្គការទស្សនៈពិភពលោក | 0%<br>0 | 0.9%<br>13 |
| គណបក្សសមរង្ស៊ី | 0.1%<br>1 | 0%<br>0 |
| ឪពុកម្តាយ • ខ្លួនឯង | 0.1%<br>1 | 0.1%<br>1 |
| គណបក្សហ៊្វុនស៊ិនប៉ិច | 0.1%<br>2 | 0%<br>0 |
| គ្មានចំលើយ | 3.8%<br>76 | 12.4%<br>185 |

**21- តើលោក លោកស្រី បានទទួលការបណ្តុះ បណ្តាលគ្រប់គ្រាន់ ដើម្បីធ្វើការងារបច្ចុប្បន្នរបស់ លោក លោកស្រី បានល្អដែរឬទេ ?**

| | | |
|---|---|---|
| បាទ / ចាស | 43.7%<br>873 | 56.4%<br>842 |
| ទេ | 55.9%<br>1116 | 42.4%<br>633 |
| គ្មានចំលើយ | 0.5%<br>9 | 1.2%<br>18 |

## <u>ចំណេះដឹង</u>

ចំណេះដឹងគួរអោយកត់សំគាល់ផងដែរថា នៅឆ្នាំ ២០០៤ ចំនួនភាគរយ នៃអ្នកផ្តល់ពត៌មាន មានទស្សនៈច្បាស់លាស់ អំពីអត្ថន័យនៃអភិបាលកិច្ច (តារាង១៤) ។ នៅឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មាន ៩១% បាននិយាយថា អភិបាលកិច្ច គឺ ជាកិរិតដែលអំណាចត្រូវបានប្រើប្រាស់ ដើម្បីគ្រប់គ្រងធនធានរបស់ប្រទេស ហើយមួយចំនួនតូចបានផ្តល់នូវចំលើយផ្សេងៗគ្នា ។ នៅឆ្នាំ ២០០១ អ្នកផ្តល់ពត៌មាន ៨៥% បានផ្តល់ចំលើយដូចគ្នានេះដែរ ហើយ

៣១% បានឆ្លើយថា អភិបាលកិច្ច គឺជាការប្រើប្រាស់អំណាច ទៅតាមការចង្អុលបង្ហាញរបស់គណបក្ស គ្រប់គ្រង ហើយ ២៦% បានឆ្លើយថា ការដឹកនាំរបស់មនុស្សជាច្រើន តាមរយៈមនុស្សមួយចំនួនតូច ហើយ ២០% ទៀតបានឆ្លើយថា អភិបាលកិច្ច គឺកិរិតដែលអំណាចត្រូវបានប្រើប្រាស់ ដើម្បីផ្តល់ផលប្រយោជន៍ដល់សមាជិក គណបក្សនយោបាយ ។ តារាង ១៥ នៅឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មាន ៩១% បានឆ្លើយថា អភិបាលកិច្ចល្អ គឺការប្រើប្រាស់អំណាចតាមរយៈស្ថាប័នរដ្ឋ ដែលទទួលខុសត្រូវ និងមានតម្លាភាពចំពោះសាធារណៈជន ហើយ ៩៧% បានឆ្លើយថា ដំណើរការប្រព័ន្ធនយោបាយដែលផ្តល់ឱកាសដល់ប្រជាពលរដ្ឋគ្រប់ៗរូប ។ នៅឆ្នាំ ២០០១ អ្នកផ្តល់ពត៌មាន ៨៧% បានជ្រើសរើសយកចំលើយទី ១ ដូចគ្នា ហើយ ៦២% បានជ្រើសរើសយកចំលើយទី ២ ដូចគ្នាដែរ ។ ចំពោះសំនួរស្តីអំពីគោលការណ៍សំខាន់ៗបំផុត នៅក្នុងអភិបាលកិច្ចល្អ (តារាង១៦) ។ ចំលើយគឺខុសគ្នាបន្តិច ។ នៅឆ្នាំ ២០០៤ តម្លាភាពមាន (៨៦%) ការពិភាក្សាគ្នាមាន (៨០%) គណនេយ្យភាពមាន (៦៨%) ហើយការអភិវឌ្ឍន៍មាន (៦៨%) ត្រូវបានជ្រើសរើសជាគោលការណ៍សំខាន់បំផុត ។ នៅឆ្នាំ ២០០១ ការពិភាក្សា (៨៦%) តម្លាភាព (៨៣%) ការអភិវឌ្ឍន៏ (៨១%) ហើយការគោរព (៧៩%) ។

សំនួរស្តីពីគណនេយ្យភាព ក្នុងអភិបាលកិច្ច (តារាង១៧) បានទទួលនូវចំលើយត្រឹមត្រូវជាងមុន នៅឆ្នាំ ២០០៤ ដែលក្នុងនោះ អ្នកផ្តល់ពត៌មាន (៧៨%) បានឆ្លើយថា ការវាយតំលៃសកម្មភាពរបស់រដ្ឋាភិបាលធ្វើឡើងដោយប្រជាពលរដ្ឋ ហើយនៅឆ្នាំ ២០០១ (៧៧%) បានឆ្លើយថា វត្តមានទៀងទាត់របស់មន្ត្រីរដ្ឋាភិបាលនៅឯកន្លែងធ្វើការរបស់ពួកគេ ។ សំនួរស្តីពីការទស្សន៍ទាយទុកជាមុន នៅក្នុងអភិបាលកិច្ច (តារាង១៨) មានចំលើយខុសគ្នាបន្តិចរវាងឆ្នាំ ២០០៤ និងឆ្នាំ ២០០១ ។ នៅឆ្នាំ ២០០៤ មានអ្នកផ្តល់ពត៌មាន (៧៦%) ការអនុវត្តនីតិវិធាននៃច្បាប់ ហើយនៅឆ្នាំ ២០០១ អ្នកផ្តល់ពត៌មាន (៨៣%) បានឆ្លើយថា កិរិតនៃច្បាប់ ដែលត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន ។ ចំណេះដឹងអំពីការចូលរួមនៅក្នុងអភិបាលកិច្ច (តារាង១៩) ហាក់ដូចជា មិនមានការប្រែប្រួលនៅក្នុងការធ្វើអង្កេតនៅឆ្នាំ ២០០១ និងឆ្នាំ ២០០៤ ។ នៅឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មាន (៨៣%) បានឆ្លើយថា មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ គួរតែធ្វើការសំរេចលើគោលនយោបាយ ដើម្បីជាប្រយោជន៍របស់ប្រជាពលរដ្ឋ ហើយនៅឆ្នាំ ២០០១ មន្ត្រី (៨៦%) បានជ្រើសរើសយកចំលើយដូចគ្នានេះដែរ ។ សំនួរស្តីពីតម្លាភាព ក្នុងអភិបាលកិច្ច (តារាង២០) អ្នកផ្តល់ពត៌មានក្នុងការធ្វើអង្កេតទាំងពីរលើកនេះ បានផ្តល់នូវចំលើយ ប្រហាក់ប្រហែលគ្នា ។ នៅឆ្នាំ ២០០៤ មន្ត្រី ៨១% ឆ្លើយថា សាធារណៈជន អាចទទួលបាននូវពត៌មានរបស់រដ្ឋាភិបាល ដោយងាយស្រួល ហើយនៅឆ្នាំ ២០០១ មន្ត្រី ៨២% បានជ្រើសរើសយកចំលើយដូចគ្នានេះ ។ នៅឆ្នាំ ២០០៤ មន្ត្រី ៧៤% បានឆ្លើយថា ច្បាប់បញ្ញត្តិ និងសេចក្តីសំរេចរបស់រដ្ឋាភិបាលច្បាស់លាស់ ហើយ នៅឆ្នាំ ២០០១ មន្ត្រី ៨៧% បានឆ្លើយចំលើយនេះ។

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|

ចំពោះសំនួរក្នុងតារាង២១ ស្តីពីគោលបំណងចំបង នៃអភិបាលកិច្ច វិមជ្ឈការក្នុងប្រទេសកម្ពុជា នៅឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មាន ហាក់ដូចជាផ្តោតទៅលើកាតព្វកិច្ច ដោយ ៨៩% ឆ្លើយថា ពង្រឹងហេដ្ឋារចនាសម្ព័ន្ធជនបទ ។ នៅឆ្នាំ ២០០១ មន្ត្រី ៨២% បានឆ្លើយថា ពង្រឹងសមត្ថភាពរបស់អ្នកភូមិ ដើម្បីអោយពួកគេធ្វើការអភិវឌ្ឍន៍ ដោយខ្លួនឯង ។ ចំពោះគោលបំណងសំខាន់ៗ របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ (តារាង២២) អ្នកផ្តល់ពត៌មានទាំងនៅឆ្នាំ ២០០៤ និង ២០០១ មានទស្សនៈដូចៗគ្នា ។ នៅឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មាន ៨៧% បាននិយាយថា គោលបំណងចំបង គឺការកាត់បន្ថយភាពក្រីក្រ តាមរយៈការអភិវឌ្ឍន៍ ដោយមានការចូលរួម ហើយនៅឆ្នាំ ២០០១ អ្នកផ្តល់ពត៌មាន ៨៩% បានផ្តល់នូវចំលើយដូចគ្នានេះដែរ ។ មន្ត្រីនៅក្នុងការអង្កេតទាំងពីរ ៩៥% នៅឆ្នាំ ២០០៤ ហើយ ៩៥% នៅឆ្នាំ ២០០១ បានជឿជាក់ថា ចំនួនថវិកា និងចំនួនដង នៃការផ្តល់ថវិការបស់ឃុំ-សង្កាត់ ត្រូវបានអនុញ្ញាត្តិអោយសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋ បានដឹង (តារាង២៣) ។ អ្នកផ្តល់ពត៌មានទាំងនៅក្នុងការអង្កេតឆ្នាំ ២០០៤ និងឆ្នាំ ២០០១ ហាក់ដូចជាមិនបានយល់ច្បាស់ថាតើ នណាត្រួតពិនិត្យតាមដាន កិច្ចសន្យាទាំងអស់របស់ខេត្ត (តារាង២៤) ។ នៅឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មាន ៦១% បានគិតថា អភិបាលខេត្តត្រួតពិនិត្យ តាមដានកិច្ចសន្យារបស់ខេត្ត ហើយនៅឆ្នាំ ២០០១ មន្ត្រីភាគច្រើនបានគិតថា មន្ទីរអភិវឌ្ឍន៍ជនបទ ត្រួតពិនិត្យកិច្ចសន្យារបស់ខេត្ត ។ នៅឆ្នាំ ២០០៤ មន្ត្រី ៥១% បានឆ្លើយថា PRDC Excom ហើយនៅឆ្នាំ ២០០១ អ្នកផ្តល់ពត៌មាន ៥៨% បានជ្រើសរើសចំលើយដូចគ្នានេះដែរ ។ នៅក្នុងការអង្កេតទាំងពីរលើកនេះ អ្នកផ្តល់ពត៌មាន មិនអាចឆ្លើយពេញលេញនូវសំនួរ អំពីរូបមន្តសំរាប់ធ្វើវិភាជន៍មូលនិធិវិនិយោគសំរាប់ឃុំ-សង្កាត់ (តារាង២៥) ។ ទាំងនៅក្នុងការអង្កេតនៅឆ្នាំ ២០០៤ និងឆ្នាំ ២០០ មន្ត្រីបានគិតថា ការធ្វើវិភាជន៍ គឺអាស្រ័យលើចំនួនប្រជាពលរដ្ឋ (៨៦%) នៅក្នុងឆ្នាំ ២០០៤ ហើយ ៨៣% នៅក្នុងឆ្នាំ ២០០១ ។ ពួកគេទាំងអស់ ស្ទើរតែជ្រើសរើសយកចំលើយត្រូវ ។

**22- តើអភិបាលកិច្ចមានន័យយ៉ាងដូចម្តេចចំពោះលោក លោកស្រី ?**

| | | |
|---|---|---|
| ប្រើប្រាស់អំណាច ដោយផ្អែកទៅតាមការចង្អុលបង្ហាញរបស់គណបក្សគ្រប់គ្រង ។ | 11.6%<br>231 | 31.1%<br>464 |
| ប្រើប្រាស់អំណាចដោយផ្អែកទៅលើទស្សនៈផ្ទាល់របស់អ្នកណាម្នាក់ ។អំណាចដែលត្រូវបានប្រើប្រាស់ដើម្បីគ្រប់គ្រងធនធានរបស់ប្រទេស ។ | 4.2%<br>83 | 6.5%<br>97 |
| ការដឹកនាំរបស់មនុស្សជាច្រើន តាមរយៈមនុស្សតែពីរបីនាក់ ។ ប្រើប្រាស់អំណាចដោយផ្អែកទៅលើទស្សនៈផ្ទាល់របស់អ្នកណាម្នាក់ ។ | 90.9%<br>1817 | 84.6%<br>1263 |
| អំណាចដែលត្រូវបានប្រើប្រាស់ ដើម្បីគ្រប់គ្រងធនធានរបស់ប្រទេស ។ | 19.9%<br>397 | 26%<br>388 |

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|
| អំណាចដែលត្រូវបានប្រើប្រាស់ ដើម្បីផ្តល់ផលប្រយោជន៍ដល់សមាជិកគណបក្សនយោបាយ ។ | 6.7%<br>134 | 20.6%<br>307 |
| គ្មានចំលើយ | 1%<br>20 | 1.1%<br>16 |

23- តើលោក លោកស្រី យល់ថា អភិបាលកិច្ចល្អ គឺអ្វី ?

| | | |
|---|---|---|
| ការប្រើប្រាស់អំណាចតាមរយៈកងកំលាំងសន្តិសុខ និងប៉ូលីស | 4.9%<br>97 | 13.3%<br>199 |
| អនុវត្តនូវប្រព័ន្ធនយោបាយ ដែលផ្តល់ឱកាសដល់មនុស្សគ្រប់ៗគ្នា | 56.9%<br>1137 | 61.7%<br>921 |
| ការប្រើប្រាស់អំណាចតាមរយៈស្ថាប័នរដ្ឋ ដែលមានការទទួលខុសត្រូវ និងមានតម្លាភាពដល់សាធារណៈជនទូទៅ | 91.6%<br>1831 | 87.2%<br>1302 |
| ការប្រើប្រាស់អំណាចតាមរយៈស្ថាប័នគណបក្សនយោបាយ ។ | 3.4%<br>68 | 9.1%<br>136 |
| ការប្រើប្រាស់អំណាចតាមរយៈមន្ត្រីជាន់ខ្ពស់ដែលត្រូវបានតែងតាំង ។ | 6%<br>120 | 18.8%<br>281 |
| ការប្រើប្រាស់អំណាចតាមរយៈច្បាប់ ដែលអាចទទួលយកបាន និងត្រូវបានបន្តប្រតិបត្តិ ។ | 66.3%<br>1324 | 76.6%<br>1143 |
| គ្មានចំលើយ | 0.2%<br>4 | 0.3%<br>4 |

24-- តើលោក លោកស្រី យល់ថា គោលការណ៍សំខាន់បំផុតនៅក្នុងអភិបាលកិច្ចល្អ គឺអ្វី ?

| | | |
|---|---|---|
| ការពិភាក្សា | 79.8%<br>1594 | 85.7%<br>1279 |
| គោរពបទបញ្ជា | 43.4%<br>867 | 57.5%<br>858 |
| តម្លាភាព | 86.3%<br>1725 | 82.8%<br>1236 |
| គ្មានអំពើពុករលួយ | 64.7%<br>1293 | 79.4%<br>1185 |
| កិច្ចព្រមព្រៀង | 55.4%<br>1107 | 68.9%<br>1029 |
| ការគោរពគ្នា | 62.4%<br>1246 | 79.1%<br>1181 |

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|
| ការអភិវឌ្ឍន៍ | 68.2%<br>1362 | 80.6%<br>1203 |
| ផែនការចូលរួមនិងការធ្វើវិភាគទានពីសហគមន៍នៅតាមមូលដ្ឋាន | 64.2%<br>1283 | 70.7%<br>1056 |
| ការទទួលខុសត្រូវ | 68.4%<br>1367 | 77.8%<br>1161 |
| ការទស្សទាយទុកជាមុន | 17.2%<br>344 | 22%<br>329 |
| គ្មានចំលើយ | 0%<br>0 | 0.1%<br>1 |

**25- ការទទួលខុសត្រូវនៅក្នុងអភិបាលកិច្ច គឺ :**

| | | |
|---|---|---|
| កំរិតដែលមន្ត្រីរាជការ ត្រូវទទួលខុសត្រូវចំពោះឥរិយាបថរបស់ខ្លួន ។ | 67.1%<br>1340 | 58.5%<br>873 |
| ការគ្រប់គ្រងកិច្ចការរដ្ឋាភិបាលដោយមន្ត្រី តែងតាំង ។ | 17.7%<br>354 | 57.9%<br>864 |
| ការវាយតំលៃសកម្មភាពរបស់រដ្ឋាភិបាល ដោយប្រជាពលរដ្ឋ ។ | 78.3%<br>1564 | 69.3%<br>1034 |
| ការចូលមកធ្វើការយ៉ាងទៀងទាត់របស់មន្ត្រី នៅក្នុងការិយាល័យរបស់រដ្ឋាភិបាល ។ | 65.6%<br>1311 | 77.4%<br>1155 |
| កំរិតដែលចៅហ្វាយនាយសប្បាយចិត្ត ទៅនឹងការអនុវត្តន៍ការងាររបស់មន្ត្រីនានា ។ | 9.3%<br>185 | 27.1%<br>404 |
| គ្មានចំលើយ | 0.1%<br>2 | 0.3%<br>5 |

**26- ការទស្សទាយទុកជាមុននៅក្នុងអភិបាលកិច្ច គឺ :**

| | | |
|---|---|---|
| ការបន្តអនុវត្តន៍នូវប្រព័ន្ធដែលមាននាពេលបច្ចុប្បន្ន ។ | 64%<br>1279 | 67.4%<br>1007 |
| កំរិតនៃការដឹកនាំនិងច្បាប់ឆ្លុះបញ្ចាំងនូវទស្សនៈរបស់គណៈបក្សគ្រប់គ្រងនយោបាយ ។ | 11.5%<br>230 | 30.3%<br>452 |
| កំរិតនៃការដឹកនាំ និងច្បាប់ត្រូវបានបន្តប្រតិបត្តិ ។ | 74.5%<br>1489 | 82.7%<br>1234 |
| ការត្រឡប់ទៅយកច្បាប់នាទស្សវត្ស ៥០ និង ៦០ មកប្រើវិញ ។ | 12.1%<br>242 | 11.1%<br>165 |
| ការអនុវត្តន៍ច្បាប់ ។ | 76.2%<br>1522 | 73.3%<br>1094 |

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|
| គ្មានចំលើយ | 0.2%<br>4 | 0.5%<br>8 |

27- ការចូលរួមនៅក្នុងអភិបាលកិច្ច គឺ :

| | | |
|---|---|---|
| យុវជនទាំងអស់អាចចូលរួមក្នុងការសំរេចចិត្តរបស់រដ្ឋាភិបាល ។ | 50.5%<br>1008 | 62.5%<br>933 |
| ចំនួនដែលប្រជាពលរដ្ឋចូលរួម ក្នុងការសំរេចចិត្តរបស់រដ្ឋាភិបាល ។ | 56.5%<br>1128 | 68.3%<br>1020 |
| មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល គួរសំរេចនូវ គោលនយោបាយដែលជាប្រយោជន៍ដ៏ប្រសើរបំផុតរបស់ប្រជាជន ។ | 83.4%<br>1666 | 86.3%<br>1289 |
| ទស្សនៈដែលបានលើកឡើង មានឥទ្ធិពលក្នុងរដ្ឋាភិបាល ។ | 18.9%<br>377 | 67.4%<br>1006 |
| ស្នើអោយរដ្ឋាភិបាលជូនដំណឹងដល់មនុស្សគ្រប់គ្នា នូវច្បាប់អ្វីដែលពួកគេត្រូវតែគោរព។ | 68.4%<br>1367 | 76.8%<br>1146 |
| គ្មានចំលើយ | 0.2%<br>3 | 0.2%<br>3 |

28- តម្លាភាពនៅក្នុងអភិបាលកិច្ច គឺ :

| | | |
|---|---|---|
| ច្បាប់ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសំរេច ច្បាស់លាស់របស់រដ្ឋាភិបាល ។ | 73.8%<br>1475 | 86.5%<br>1292 |
| ជូនដំណឹងដល់សាធារណៈជន ស្តីពីបញ្ហា ទាំងឡាយលើកលែងតែអ្នកដែលបង្កអោយមានអស្ថេរភាព ។ | 45.7%<br>914 | 55.3%<br>826 |
| ត្រូវកំណត់តំលៃសំរាប់ការបំរើសេវាអោយបានច្បាស់លាស់ ។ | 64.3%<br>1284 | 67.6%<br>1010 |
| ពត៌មានផ្សេងៗរបស់រដ្ឋាភិបាល ត្រូវដាក់អោយ សាធារណៈជន បានដឹងដោយងាយ។ | 81.2%<br>1622 | 81.5%<br>1217 |
| ទុកលទ្ធភាពអោយមន្ត្រីជាន់ខ្ពស់ បង្កើតច្បាប់ និងបទបញ្ជាផ្ទៃក្នុង ។ | 20.1%<br>402 | 28.7%<br>428 |
| គ្មានចំលើយ | 0.2%<br>4 | 0.5%<br>8 |

29- តើអ្វីជាវត្ថុបំណងចំបង នៃអភិបាលកិច្ចវិមជ្ឈការ នៅក្នុងប្រទេសកម្ពុជា ?

| | | |
|---|---|---|
| រៀបចំផែនការវិមជ្ឈការ ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីម្ចាស់ជំនួយខាងក្រៅ ។ | 68.7%<br>1373 | 76.8%<br>1146 |
| កាត់បន្ថយភាពក្រីក្រនិងពង្រឹងលទ្ធិប្រជាធិបតេយ្យ | 88.7%<br>1772 | 78.6%<br>1173 |

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|
| ពង្រឹងអំណាចក្រុមប្រឹក្សាឃុំ/សង្កាត់ថ្មី ។ | 65.2%<br>1303 | 75.2%<br>1122 |
| ពង្រឹងសមត្ថភាពរបស់អ្នកភូមិ ដើម្បីអភិវឌ្ឍន៍ខ្លួនគេ ។ | 73.5%<br>1468 | 82%<br>1224 |
| បង្កើនអំណាចដល់អ្នកភូមិ ។ | 40%<br>799 | 52.4%<br>783 |
| បង្កើតគណៈកម្មាធិការប្រឹក្សាដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ ។ | 57%<br>1139 | 71%<br>1060 |
| ធ្វើផែនការចូលរួម និងវិភាគទាន ទៅតាមមូលដ្ឋាន ។ | 65.5%<br>1308 | 73.3%<br>1094 |
| គ្មានចំលើយ | 0.2%<br>3 | 0.5%<br>8 |

30- ក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលទើបជាប់ឆ្នោត តាមរយៈការបោះឆ្នោតនឹង :

| | | |
|---|---|---|
| ធ្វើអោយមានប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន | 85.7%<br>1713 | 80.8%<br>1206 |
| ផ្តល់សិទ្ធិអំណាចដល់អ្នកភូមិ ដើម្បីសំរេច នូវតំរូវការអភិវឌ្ឍន៍ផ្ទាល់របស់ពួកគេ ។ | 84.8%<br>1695 | 87.3%<br>1304 |
| ពង្រឹងសមាជិកភាពរបស់គណបក្សនយោបាយនៅថ្នាក់ទាប ។ | 12.2%<br>243 | 27.4%<br>409 |
| ត្រូវរកថវិកាបរទេស ។ | 26.8%<br>536 | 48.2%<br>720 |
| កាត់បន្ថយភាពក្រីក្រ តាមរយៈការអភិវឌ្ឍន៍ ដែលមានការចូលរួមពីសហគមន៍ ។ | 87.1%<br>1741 | 89%<br>1329 |
| គ្មានចំលើយ | 0.1%<br>2 | 0.5%<br>7 |

31- ចំនួនទឹកប្រាក់ និងចំនួនដងនៃការផ្តល់ថវិកា វិនិយោគនៃកម្មវិធីសិលា ឃុំ/សង្កាត់ ទទួលពីរដ្ឋាភិបាលកណ្តាល គឺត្រូវអោយដឹងដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ និងអ្នកបោះឆ្នោត

| | | |
|---|---|---|
| ពិត | 95%<br>1899 | 94.5%<br>1411 |
| មិនពិត | 4.1%<br>81 | 3.2%<br>48 |
| គ្មានចំលើយ | 0.9%<br>18 | 2.3%<br>34 |

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|

32- តើនរណាត្រួតពិនិត្យកុងត្រារបស់ខេត្ត ដែលមានការវិនិយោគរបស់ម្ចាស់ជំនួយ ?

| | | |
|---|---|---|
| អភិបាលខេត្ត | 61%<br>1218 | 60.5%<br>903 |
| អ្នកត្រួតពិនិត្យបញ្ជីចំណាយចំណូល | 43.6%<br>872 | 34.1%<br>509 |
| មន្ទីរអភិវឌ្ឍន៍ជនបទ | 39.5%<br>790 | 62.7%<br>936 |
| ក្រសួងមហាផ្ទៃ | 46.7%<br>933 | 35.6%<br>532 |
| គ.អ.ជ.ខ (PRDC) / គណៈកម្មាធិការប្រតិបត្តិ ( Excom ) | 51.3%<br>1024 | 58.4%<br>872 |
| មិនដឹង | 9.4%<br>187 | 9.4%<br>141 |
| គ្មានចំលើយ | 0.4%<br>7 | 1.5%<br>22 |

33- ថវិកាវិនិយោគឃុំ / សង្កាត់ ត្រូវបានបែងចែកសំខាន់ គឺផ្អែកទៅតាម :

| | | |
|---|---|---|
| ចំងាយផ្លូវពីឃុំទៅទីរួមខេត្ត ។ | 36%<br>720 | 60.1%<br>897 |
| ចំនួនប្រជាជននៅក្នុងឃុំ ។ | 85.6%<br>1711 | 82.6%<br>1233 |
| ជាតើឃុំនោះក្រដល់កំរិតណា | 57.2%<br>1143 | 75.5%<br>1127 |
| រូបមន្តកុំព្យូទ័រ | 7%<br>139 | 19.6%<br>293 |
| សេចក្តីសំរេចដោយអភិបាលខេត្ត | 31%<br>620 | 37.3%<br>557 |
| គ្មានចំលើយ | 0.8%<br>15 | 1.8%<br>27 |

## សវិយាបន

អ្នកផ្តល់ពត៌មាន នៅក្នុងការធ្វើអង្កេតទាំងពីរបានមានជំនឿថា គ្រប់ថ្នាក់ទាំងអស់របស់រដ្ឋាភិបាលគួរទទួលខុសត្រូវចំពោះកម្មភាពរបស់ពួកគេ ( តារាង២៦) ។ នៅក្នុងឆ្នាំ ២០០៤ ថ្នាក់ជាតិ ៧៩% ថ្នាក់ខេត្ត ៨០% ហើយថ្នាក់ឃុំ ៨២% ចំណែកឯនៅឆ្នាំ ២០០១ ថ្នាក់ជាតិ ៧១% ថ្នាក់ខេត្ត ៧៩% ថ្នាក់ឃុំ ៨៩% ។ គ្មានលក្ខណៈខុស

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|

ប្លែកច្រើនរវាងការធ្វើអង្កេតទាំងពីរ ចំពោះសំនួរដែលសួរថា នណាគួរមានសំលេងនៅក្នុងការធ្វើការងាររបស់រដ្ឋាភិបាល (តារាង២៧) នៅក្នុងឆ្នាំ ២០០៤ បុរសដែលមានអាយុលើសពី ១៨ឆ្នាំ ៩១% ស្ត្រីមិនទាន់រៀបអាពាហ៍ពិពាហ៍ ដែលមានអាយុលើសពី ១៨ (៨២%) ស្ត្រីរៀបអាពាហ៍ពិពាហ៍ហើយ (៦៨%) ហើយកងទ័ពភាគរយទាបជាងគេបំផុតគឺ ៣៧% ។ នៅក្នុងឆ្នាំ ២០០១ បុរសដែលមានអាយុលើសពី ១៨ឆ្នាំ (៩០%) ស្ត្រីមានអាយុលើសពី ១៨ឆ្នាំ (៨៥%) ស្ត្រីរៀបអាពាហ៍ពិពាហ៍ហើយ (៧៩%) ហើយកងទ័ព (៤២%) ។ ទាំងស្ត្រីរៀបអាពាហ៍ពិពាហ៍ហើយ និងទាំងកងទ័ព មានការថយចុះ ប៉ុន្តែមិនជាខ្លាំងណាស់ណាទេ ។ ទាំងពីរក្រុមមិនចាប់អារម្មណ៍អំពីសំនួរ ដែលសួរថា មានពេលខ្លះ ការអនុវត្តន៍ច្បាប់ធ្វើអោយយឺតយ៉ាវដល់ការអភិវឌ្ឍន៍ ឬក៏មានពេលខ្លះការសំរេចចិត្តគួរតែធ្វើដោយរដ្ឋាភិបាលជាជាងធ្វើជាសាធារណៈ (តារាង២៨-២៩) ទាំងពីរក្រុម ព្យាយាមបញ្ចេញទស្សនៈ ស្តីអំពីការចូលរួមនៅក្នុងឆ្នាំ ២០០៤ ទស្សនៈវេជ្ជមាន មាន ៦៨% និង ៦៦% ហើយនៅឆ្នាំ ២០០១ ទស្សនៈវេជ្ជមាន ៦៥% និង ៧១% ។

វាហាក់ដូចជា លំដាប់ឯកភាព នៃដំណើរការវិមជ្ឈការ (តារាង៣០) មានការកើនឡើង ៩២% ឆ្នាំ ២០០១ និង ៩៥% នៅឆ្នាំ ២០០៤ ចំពោះសំនួរដែលសួរអំពី ថាតើការអភិវឌ្ឍន៍រយៈពេលវែង នៅក្នុងប្រទេសកម្ពុជា អាចមានដែរឺទេ បើគ្មានក្រុមរបឹក្សាឃុំ-សង្កាត់ (តារាង៣១) ។ នៅក្នុងឆ្នាំ ២០០១ អ្នកផ្តល់ពត៌មានបានមានជំនឿថា ការអភិវឌ្ឍន៍បែបនោះ មិនអាចមានទេ (៦៧%) ហើយនៅឆ្នាំ ២០០៤ គឺ ៧៦% ។ ក៏មានការកើនឡើងផងដែរ ក្នុងរយៈពេល ៣ឆ្នាំ អំពីទស្សនៈដែលថា ទាំងមនុស្សចាស់ ទាំងស្ត្រី ដែលយល់អំពីការអភិវឌ្ឍន៍ គួរតែចូលរួមនៅក្នុងការធ្វើផែនការ និងថវិកាឃុំសង្កាត់ (តារាង៣២-៣៣) ។ នៅក្នុងឆ្នាំ ២០០១ ទស្សនៈឯកភាព អោយមនុស្សចាស់ និងស្ត្រី ចូលរួមក្នុងការអភិវឌ្ឍន៍ គឺ ៦៩% និង ៧៤% ។ ទស្សនៈគាំទ្រនេះ បានកើនដល់ ៧៦% និង ៨០% ។ អ្វីដែលគួរអោយ ចាប់អារម្មណ៍នោះ គឺថា ឥរិយាបថចំពោះវិធីសាស្ត្រចូលរួម ក្នុងការអភិវឌ្ឍន៍ (តារាង៣៤) មិនមានការផ្លាស់ប្តូរច្រើនទេ ។ នៅឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មាន ៨២% បានគិតថា បង្កើនការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាលនៅក្នុងដំណើរការអភិវឌ្ឍន៍ ហើយនៅឆ្នាំ ២០០១ មាន ៨២% ដែរ ។ ជំរើសដែលខ្ពស់បំផុត បន្ទាប់ទៀតនោះ គឺផ្តល់អំណាចដល់អ្នកភូមិ ដើម្បីអោយពួកគេធ្វើការសំរេចអំពីការអភិវឌ្ឍន៍របស់ពួកគេ ដែលនៅឆ្នាំ ២០០៤ ទស្សនៈគាំទ្រមាន ៦៨% ហើយនៅឆ្នាំ ២០០១ ទស្សនៈគាំទ្រ គឺ ៧៩% ។

ទស្សនៈដែលបានពង្រឹងនូវការគ្រប់គ្រងល្អ នៅក្នុងការអភិវឌ្ឍន៍ (តារាង៣៥) មានន័យថា ការពិភាក្សាបន្ថែមរវាងអ្នកភូមិ និងមន្ត្រីរដ្ឋាភិបាល ក្នុងការធ្វើសេចក្តីសំរេចអំពីការអភិវឌ្ឍន៍នោះ នៅឆ្នាំ ២០០១ មានទស្សនៈគាំទ្រ ៧០% ហើយនៅឆ្នាំ ២០០៤ ទស្សនៈគាំទ្រគឺ ៧៧% ។ ទស្សនៈគាំទ្រប្រហាក់ប្រហែលគ្នា សំរាប់និយមន័យ នៃការធ្វើផែនការល្អ (តារាង៣៦) នៅឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មាន ៨៤% បានគិតថា ការធ្វើផែនការល្អ គឺបញ្ចូលទស្សនៈ សេចក្តីសំរេច និងការចូលរួមដោយស្ម័គ្រចិត្តរបស់សហគមន៍ ដែលទទួលរងនូវឥទ្ធិពលដោយការធ្វើផែនការនោះ ។ នៅឆ្នាំ ២០០១ ទស្សនៈគាំទ្រប្រហាក់ប្រហែលគ្នា ហើយនៅឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មាន ៨៤% ទៀតបានគិតថា វាគឺជាការធ្វើផែនការច្បាស់លាស់ ហើយអាចអនុវត្តបាន ។ នៅឆ្នាំ ២០០១ ចំនួនភាគរយប្រហាក់ប្រហែលគ្នា បានគាំទ្រនូវទស្សនៈនោះ ចំពោះសំនួរដែលសួរនៅក្រោមតារាង ៣៧% ដែលបានសួរអំពីនិយមន័យ នៃ

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|

អ្នកដឹកនាំ ឬអ្នកគ្រប់គ្រងល្អ អ្នកផ្តល់ពត៌មាននៅក្នុងការអង្កេតទាំងពីរបានគិតថា យល់នូវបញ្ហាទាំងឡាយ ហើយមានទំនុកទុកចិត្តថា បញ្ហាទាំងនោះអាចត្រូវបានដោះស្រាយ (៨៥% នៅឆ្នាំ ២០០៤ ហើយ ៨៦% នៅឆ្នាំ ២០០១ )។ ហើយមានយុត្តិធម៌ និងការឃោគយល់គ្នាទៅវិញទៅមក (៨០%នៅឆ្នាំ ២០០៤ ហើយ ៨៦% នៅឆ្នាំ ២០០១) ។ អ្នកផ្តល់ពត៌មានមានអាទិភាពដូចគ្នា អំពីផលប្រយោជន៍ នៃអភិបាលកិច្ចល្អ (តារាង៣៨) ។ នៅឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មាន ៨៧% បានឆ្លើយថា ប្រទេសមានការអភិវឌ្ឍន៍ និងសន្តិសុខ ហើយនៅឆ្នាំ ២០០១ អ្នកផ្តល់ពត៌មាន ៨៥% បានគាំទ្រនូវចំលើយនេះ ទស្សនៈបានបញ្ចេញដូចគ្នា អំពីសំនួរដែលបានសួរនៅក្រោមតារាង ៣៩ អំពីមូលហេតុដែលស្ត្រីគួរចូលរួមក្នុងការអភិវឌ្ឍន៍ ។ នៅក្នុងឆ្នាំ ២០០៤ ចំលើយភាគច្រើនគឺ ៨៣% ដែលនិយាយថា វាដោយសារតែស្ត្រីគឺជាមាតានៃពិភពលោក ។ ទស្សនៈដដែល បានបញ្ចេញនូវឆ្នាំ ២០០១ ដោយអ្នកផ្តល់ពត៌មាន ៨៧% ។

**34- តើមន្ត្រីរបស់រដ្ឋាភិបាលថ្នាក់ណាខ្លះ ដែលគួរទទួលខុសត្រូវ ចំពោះសកម្មភាពរបស់ខ្លួន ?**

| | | |
|---|---|---|
| ថ្នាក់ជាតិ | 79%<br>1578 | 70.6%<br>1054 |
| ថ្នាក់ខេត្ត | 79.5%<br>1589 | 79%<br>1180 |
| ថ្នាក់ឃុំ | 81.6%<br>1631 | 89.1%<br>1330 |
| គ្មានចំលើយ | 0.7%<br>13 | 0.8%<br>12 |

**35- តើលោក លោកស្រីយល់ថា នរណាគួរតែមានសំលេង ក្នុងការងាររបស់រដ្ឋាភិបាល ?**

| | | |
|---|---|---|
| បុរសដែលមានអាយុលើសពី ១៨ឆ្នាំ | 90.9%<br>1816 | 90.3%<br>1363 |
| ស្ត្រីមានប្តី | 67.6%<br>1351 | 79%<br>1180 |
| ស្ត្រីគ្មានប្តី ដែលមានអាយុលើសពី ១៨ឆ្នាំ | 82.4%<br>1646 | 84.5%<br>1261 |
| គ្រូបាធ្យាយ | 59.1%<br>1181 | 76.4%<br>1140 |
| ជនពិការ | 45.5%<br>909 | 54.7%<br>816 |
| ទាហាន | 36.7%<br>734 | 42.2%<br>630 |
| ព្រះសង្ឃ | 43.4%<br>868 | 54.1%<br>808 |

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|
| គ្មានចំលើយ | 0.2%<br>4 | 0.8%<br>12 |

36- តើមានពេលខ្លះ ការប្រតិបត្តិច្បាប់ ធ្វើអោយយឺតដំណើរដល់ការអភិវឌ្ឍន៍ដែរឬទេ ?

| | | |
|---|---|---|
| បាទ / ចាស | 67.7%<br>1353 | 64.8%<br>967 |
| ទេ | 29.9%<br>597 | 32.9%<br>491 |
| គ្មានចំលើយ | 2.4%<br>48 | 2.3%<br>35 |

37- តើមានពេលខ្លះសេចក្តីសំរេចដែលធ្វើឡើងដោយរដ្ឋាភិបាលប្រសើរជាងធ្វើ ជាសាធារណៈដែរឬទេ ?

| | | |
|---|---|---|
| បាទ / ចាស | 65.9%<br>1316 | 71.4%<br>1066 |
| ទេ | 33.2%<br>664 | 26.1%<br>389 |
| គ្មានចំលើយ | 0.9%<br>18 | 2.5%<br>38 |

38- តើលោក លោកស្រីឯកភាពអំពីវិមជ្ឈការ ដែលអំណាចមួយចំនួន ត្រូវបានផ្ទេរពី រដ្ឋាភិបាលថ្នាក់ជាតិ ដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ដែរឬទេ ?

| | | |
|---|---|---|
| បាទ / ចាស | 94.9%<br>1897 | 91.9%<br>1372 |
| ទេ | 4.8%<br>96 | 6.9%<br>103 |
| គ្មានចំលើយ | 0.3%<br>5 | 1.2%<br>18 |

39- តើការអភិវឌ្ឍន៍ដែលមានរយៈពេលយូរនៅក្នុងប្រទេសកម្ពុជា អាចដំណើរការ បានដោយគ្មានក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលទើបនឹងជាប់ឆ្នោតថ្មីរឺទេ ?

| | | |
|---|---|---|
| បាទ / ចាស | 27%<br>540 | 31.3%<br>468 |
| ទេ | 72.4%<br>1446 | 66.9%<br>999 |
| គ្មានចំលើយ | 0.6%<br>12 | 1.7%<br>26 |

| វេលខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|

40 - នៅក្នុងប្រទេសកម្ពុជា ចាស់ព្រឹទ្ធាចារ្យមិនយល់ពីការអភិវឌ្ឍន៍ ដូច្នេះពួកគាត់មិនគួរអោយចូលរួមនៅក្នុងការរៀបចំផែនការ និងថវិកាឃុំ/សង្កាត់ ទេ ។

| | | |
|---|---|---|
| ពិត | 23.2%<br>464 | 28.9%<br>432 |
| មិនពិត | 76.1%<br>1521 | 69.4%<br>1036 |
| គ្មានចំលើយ | 0.7%<br>13 | 1.7%<br>25 |

41- នៅក្នុងប្រទេសកម្ពុជា ស្ត្រីមិនយល់ពីការអភិវឌ្ឍន៍ គេមិនគួរអោយពួកគាត់ចូលរួមនៅក្នុងការរៀបចំផែនការ និងថវិកាឃុំ/សង្កាត់ ទេ ។

| | | |
|---|---|---|
| ពិត | 19.2%<br>384 | 23.6%<br>353 |
| មិនពិត | 80.3%<br>1604 | 74.8%<br>1117 |
| គ្មានចំលើយ | 0.5%<br>10 | 1.5%<br>23 |

42- នៅក្នុងប្រទេសកម្ពុជា វិធីសាស្ត្រចូលរួមក្នុងការអភិវឌ្ឍន៍ មានន័យថា :

| | | |
|---|---|---|
| បង្កើនការចូលរួមពីមន្ត្រីរដ្ឋាភិបាលនៅក្នុងការអភិវឌ្ឍន៍ ។ | 65.7%<br>1313 | 74.9%<br>1118 |
| បង្កើនការចូលរួមពីអង្គការក្រៅរដ្ឋាភិបាល នៅក្នុងដំណើរការអភិវឌ្ឍន៍ ។ | 81.7%<br>1633 | 82.3%<br>1229 |
| រៃអង្គាសលុយ និងសុំកំលាំងពលកម្មពីអ្នកភូមិ ។ | 43.1%<br>862 | 46.2%<br>690 |
| ផ្តល់អំណាចដល់អ្នកភូមិដើម្បីធ្វើការសំរេចចិត្ត ស្តីពីការអភិវឌ្ឍន៍ផ្ទាល់ខ្លួនរបស់ពួកគេ ។ | 79.2%<br>1583 | 79.4%<br>1186 |
| បង្កើនការចូលរួមពីព្រះសង្ឃ និងអាចារ្យក្នុងការអភិវឌ្ឍន៍ ។ | 68.3%<br>1365 | 73.5%<br>1097 |
| សូមយកការរៀបរាប់ខាងលើនេះ ជាចំលើយ ។ | 48.2%<br>963 | 56%<br>836 |
| ការរៀបរាប់ខាងលើទាំងអស់ មិនមែនជាចំលើយ ។ | 3.3%<br>66 | 6%<br>90 |
| គ្មានចំលើយ | 0.2%<br>3 | 0.8%<br>12 |

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|

**43- ការគ្រប់គ្រងល្អ នៅក្នុងការអភិវឌ្ឍន៍ មានន័យថា :**

| | | |
|---|---|---|
| មានការពិគ្រោះពិភាក្សាថែមទៀត រវាងមន្ត្រីរដ្ឋាភិបាលថ្នាក់ខ្ពស់ និងមន្ត្រីឃុំ/សង្កាត់ ។ | 15.1%<br>301 | 18.8%<br>281 |
| មានការពិគ្រោះពិភាក្សាបន្ថែម រវាងអ្នកភូមិ និងមន្ត្រីឃុំ/សង្កាត់ ក្នុងការសំរេចចិត្ត ក្នុងកិច្ចអភិវឌ្ឍន៍ ។ | 77.2%<br>1542 | 69.9%<br>1043 |
| គ្មានចំលើយ | 7.8%<br>155 | 11.3%<br>169 |

**44- តើការរៀបចំផែនការល្អ គឺជាអ្វី ?**

| | | |
|---|---|---|
| ការរៀបចំផែនការដោយផ្អែកទៅលើការយល់ដឹង ពីគោលបំណងរបស់គណបក្សគ្រប់គ្រង ។ | 9.7%<br>194 | 21.8%<br>325 |
| ការរៀបចំផែនការ ដោយផ្អែកទៅលើទស្សនៈ និងសេចក្តីសំរេចផ្ទាល់ខ្លួនរបស់អភិបាលខេត្ត និងថ្នាក់ដឹកនាំឃុំ/សង្កាត់ - ស្រុក/ខណ្ឌ ។ | 38.3%<br>765 | 58.3%<br>870 |
| ការរៀបចំផែនការ ដែលរួមបញ្ចូលគ្នានូវគំនិតសេចក្តីសំរេច និងការចូលរួមដោយស្ម័គ្រចិត្តពីសហគមន៍ដែលទទួលឥទ្ធិពលពីផែនការ ។ | 84.1%<br>1681 | 82.6%<br>1233 |
| ការរៀបចំផែនការដែលមានលក្ខណៈច្បាស់លាស់ហើយដែលអាចយកមកអនុវត្តន៍បាន ។ | 83.5%<br>1669 | 84.3%<br>1258 |
| ការរៀបចំផែនការ និងការអនុវត្តន៍ដោយ ផ្អែកទៅលើគោលការណ៍របស់ព្រះពុទ្ធ ។ | 18.6%<br>371 | 25.7%<br>383 |
| គ្មានចំលើយ | 0.3%<br>6 | 1%<br>15 |

**45- តើគុណភាពចំបង នៃអ្នកគ្រប់គ្រងល្អ / ថ្នាក់ដឹកនាំល្អ គឺអ្វី ?**

| | | |
|---|---|---|
| យល់ពីបញ្ហា និងជឿជាក់ថា អាចដោះស្រាយបញ្ហាទាំងនោះបាន ។ | 84.5%<br>1689 | 86.2%<br>1287 |
| មិនជិតស្និទ្ធិជាមួយអ្នកដទៃ ។ | 7%<br>140 | 12.4%<br>185 |
| ប្រកាន់ភាពយុត្តិធម៌ និងយល់យោគដល់អ្នកដទៃ ។ | 79.7%<br>1592 | 86.3%<br>1289 |
| ធ្វើជាមនុស្សសំខាន់ ដើម្បីជួយសហសេវិក ។ | 37.1%<br>741 | 53.4%<br>798 |
| ចេះតែដាក់បទបញ្ជា តែមិនបានធ្វើជាគំរូល្អដល់អ្នកដទៃ ។ | 3.2%<br>64 | 5.7%<br>85 |
| គោរពអ្នកដទៃ ។ | 61.7%<br>1232 | 71.6%<br>1069 |

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|
| ធានាថាមនុស្សធ្វើការក្រោមបង្គាប់ទទួលប្រាក់ខែខ្ពស់ ។ | 12.1%<br>241 | 16.8%<br>251 |
| ជ្រើសរើសមនុស្សក្រោមបង្គាប់ដែលស្មោះត្រង់ ។ | 44%<br>880 | 69.9%<br>1044 |
| គ្មានចំលើយ | 0.3%<br>5 | 1.1%<br>16 |

**46- តើអត្ថប្រយោជន៍ចំបង នៃអភិបាលកិច្ចល្អ គឺអ្វី ?**

| | | |
|---|---|---|
| ប្រជាពលរដ្ឋពេញចិត្តចំពោះតំណាងរបស់ពួកគាត់នៅក្នុងជួររដ្ឋាភិបាល ។ | 75.4%<br>1507 | 83.5%<br>1246 |
| ប្រទេសមានការអភិវឌ្ឍន៍ និងសន្តិសុខ ។ | 87%<br>1738 | 88.8%<br>1326 |
| ថ្នាក់ដឹកនាំ និងមនុស្សក្រោមបញ្ជា ទទួលអត្ថប្រយោជន៍ច្រើន ។ | 19.5%<br>390 | 32.6%<br>486 |
| ប្រជាពលរដ្ឋនឹងមិនរិះគន់អ្នកដឹកនាំរបស់ពួកគេ ។ | 38.6%<br>771 | 57.1%<br>852 |
| អ្នកដឹកនាំនឹងត្រូវបោះឆ្នោតជ្រើសរើសសារជាថ្មី ។ | 51%<br>1018 | 61%<br>911 |
| គ្មានចំលើយ | 0.4%<br>7 | 1.4%<br>21 |

**47-ហេតុអ្វីបានជាស្ត្រី ត្រូវតែចូលរួម ក្នុងការអភិវឌ្ឍន៍ ?**

| | | |
|---|---|---|
| ស្ត្រីមានចំនួនច្រើន ។ | 57%<br>1139 | 70.5%<br>1052 |
| ស្ត្រីគឺជាផ្នែកនៃសង្គម ដែលក្រីក្រ និងទន់ខ្សោយជាងគេបំផុត ។ | 65.7%<br>1313 | 67.3%<br>1005 |
| ស្ត្រីជាមាតានៃពិភពលោក ។ | 82.6%<br>1651 | 86.9%<br>1297 |
| ប្រាក់ខែរបស់ស្ត្រីមិនគ្រប់គ្រាន់ ។ | 30.8%<br>615 | 38.6%<br>569 |
| ទស្សនៈរបស់ស្ត្រីមិនត្រូវបានចាត់ទុកជាអាទិភាពហើយត្រូវគេមើលរំលងប្រសិនបើមិនមានការយកចិត្តទុកដាក់យ៉ាងពិសេសដល់ពួកគេ ។ | 50.3%<br>1004 | 55.5%<br>828 |
| គ្មានចំលើយ | 0.3%<br>5 | 1.7%<br>25 |

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|

**ការអនុវត្តន៍**

នៅក្នុងឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មានហាក់ដូចជាមិនសូវមានជំនឿថា ការអនុវត្តន៍ ការគ្រប់គ្រងបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា មានភាពត្រឹមត្រូវសំរាប់រយៈពេល ៥ឆ្នាំក្រោយ (តារាង៤០) នៅឆ្នាំ ២០០១ ទស្សនៈនេះ ត្រូវបានគាំទ្រដោយអ្នកផ្តល់ពត៌មាន ៨៥% ហើយនៅឆ្នាំ ២០០៤ ទស្សនៈនេះត្រូវបានគាំទ្រដោយអ្នកផ្តល់ពត៌មាន ៨៣% ។ មានការថយចុះចំនួនតិចតួច ចំពោះចំលើយដែលសួរថា តើរដ្ឋាភិបាលកំពុងបង្កើនមធ្យោបាយ ដែលធ្វើអោយប្រជាពលរដ្ឋកម្ពុជាទាំងអស់ អាចចូលរួមក្នុងការធ្វើគោលនយោបាយដែររឺទេ (តារាង៤១) នៅឆ្នាំ ២០០១ អ្នកផ្តល់ពត៌មាន ៨៦% បានឆ្លើយគាំទ្រ ហើយនៅឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មាន ៨៤% បានឆ្លើយឯកភាព ។ មានការថយចុះនូវចំនួនតិចតួច ដូចដែលបានឃើញនៅខាងក្រោមតារាង ៤២ ដែលសំនួរសួរថា តើច្បាប់ទាំងអស់ ត្រូវបានគេអនុវត្តយ៉ាងខ្ជាប់ខ្ជួនដែររឺទេនៅក្នុងប្រទេសកម្ពុជា ។ នៅក្នុងឆ្នាំ ២០០១ អ្នកផ្តល់ពត៌ មាន ៨៧% បាននិយាយថា ច្បាប់ទាំងអស់ ត្រូវបានគេគោរពយ៉ាងខ្ជាប់ខ្ជួន ប៉ុន្តែនៅក្នុងឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មាន តែ ៨៥% ប៉ុណ្ណោះដែលនិយាយបែបនោះ ។ ចំនួនអ្នកផ្តល់ពត៌មានប្រហាក់ប្រហែលគ្នានេះដែរ បានឆ្លើយបដិសេធ ពីសំនួរដែលសួរថា តើពួកគេបានទទួលពត៌មានគ្រប់គ្រាន់អំពីការចំណាយរបស់រដ្ឋាភិបាលដែររឺទេ (តារាង៤៣) ។ នៅឆ្នាំ ២០០១ អ្នកផ្តល់ពត៌មាន ៦៩% បាននិយាយថា ពួកគេមិនបានទទួលពត៌មានគ្រប់គ្រាន់ទេ ហើយនៅឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មានជិត ៧១% បានឆ្លើយបដិសេធដូចគ្នាដែរ ។

ទោះបីយ៉ាងណាក៏ដោយ ក៏មន្ត្រីមួយចំនួនតូច ក៏មានទស្សនៈច្បាស់លាស់អំពីចំលើយរបស់ពួកគេចំពោះសំនួរដែលសួរអំពីអំពើពុករលួយ (តារាង៤៤-៤៨) ។ ក្នុងការឆ្លើយចំពោះសំនួរ ដែលសួរថា តើការសូកប៉ាន់ជាមធ្យោបាយសាមញ្ញ ដើម្បីអោយគេធ្វើការងារអ្វីមួយអោយបាន នៅក្នុងប្រទេសកម្ពុជាដែររឺទេ (តារាង៤៤) នៅឆ្នាំ ២០០១ អ្នកផ្តល់ពត៌មាន ៦០% បានឆ្លើយឯកភាព ហើយនៅឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មានតែ ៥៨% ប៉ុណ្ណោះ ដែលបានឆ្លើយឯកភាព ។ ចំពោះសំនួរសួរថា តើអ្នកម៉ៅការ ត្រូវតែបង់កំរៃជើងសារ ដើម្បីអោយបានកិច្ចសន្យាដែររឺទេ ? (តារាង៤៥) នៅឆ្នាំ ២០០១ អ្នកផ្តល់ពត៌មាន ៦៩% បានឆ្លើយថា អ្នកម៉ៅការត្រូវបង់កំរៃជើងសារ ដើម្បីអោយបានកិច្ចសន្យា ហើយនៅឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មានតែ ៥០% ប៉ុណ្ណោះ ដែលបានផ្តល់នូវចំលើយវិជ្ជមាន ។ ក្នុងការឆ្លើយតបទៅនឹងសំនួរ ដែលសួរថា តើវាការទទួលយកបានដែររឺទេ ដែលមន្ត្រីរដ្ឋាភិបាលមានប្រាក់ខែតិចតួច ត្រូវទទួលយកកំរៃជើងសារ (តារាង៤៦) នៅឆ្នាំ ២០០១ មន្ត្រី ៦៣% បានគិតថា វាជាការដែលអាចទទួលយកបាន ហើយនៅឆ្នាំ ២០០៤ មន្ត្រី ៥៣% បានគិតដូច្នេះ ។ ក្នុងការឆ្លើយតបទៅនឹងសំនួរសួរថា តើប្រព័ន្ធហិរញ្ញវត្ថុកម្មវិធីសិលាបច្ចុប្បន្ន មានន័យថា ជនណាដែលចង់លួចថវិកាពីគំរោង ជននោះនឹងត្រូវបានចាប់ខ្លួន (តារាង៤៧) ។ នៅឆ្នាំ ២០០១ អ្នកផ្តល់ពត៌មាន ៧៨% បានគិតថា វាជាការពិតមែនហើយ ហើយនៅឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មានតែ ៧១% ប៉ុណ្ណោះ បានគិតបែបនោះ ។ នៅក្នុងការអង្កេតឆ្នាំ ២០០១ និងឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មានបានគិតថា កិច្ចសន្យាការងារ គួរត្រូវបានផ្តល់អោយតាមតំលៃទាបបំផុត ហើយដោយមានគុណភាពល្អ (៧០% នៅក្នុងឆ្នាំ ២០០១ ហើយជិត ៧០% នៅឆ្នាំ ២០០៤) (តារាង៤៩) ។

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|

48- តើការអនុវត្តន៍ទៅលើការគ្រប់គ្រង របស់រដ្ឋាភិបាលពេលបច្ចុប្បន្ន នៅក្នុងប្រទេស
កម្ពុជា មានលក្ខណៈសមស្របសំរាប់រយៈពេល ០៥ ឆ្នាំ ទៅមុខទៀតវិទេ ?

| | | |
|---|---|---|
| បាទ / ចាស | 83.3%<br>1664 | 85.3%<br>1273 |
| ទេ | 15.3%<br>306 | 12.3%<br>183 |
| គ្មានចំលើយ | 1.4%<br>28 | 2.5%<br>37 |

49- តើរដ្ឋាភិបាល កំពុងបង្កើនមធ្យោបាយដែលអាចអោយ ប្រជាជនកម្ពុជាចូល
រួមចំណែកក្នុងការបង្កើតគោលនយោបាយដែរវិទេ ?

| | | |
|---|---|---|
| បាទ / ចាស | 83.8%<br>1674 | 85.6%<br>1278 |
| ទេ | 15%<br>300 | 11.9%<br>177 |
| គ្មានចំលើយ | 1.2%<br>24 | 2.5%<br>38 |

50- តើច្បាប់ទាំងអស់ត្រូវបានបន្តប្រតិបត្តិនៅក្នុងប្រទេសកម្ពុជាដែរវិទេ ?

| | | |
|---|---|---|
| បាទ / ចាស | 84.7%<br>1693 | 87.1%<br>1300 |
| ទេ | 14.1%<br>281 | 10.1%<br>151 |
| គ្មានចំលើយ | 1.2%<br>24 | 2.8%<br>42 |

51- តើលោក លោកស្រី បានទទួលពត៌មានគ្រប់គ្រាន់ អំពីការចំណាយ របស់រដ្ឋាភិបាលដែរវិទេ ?

| | | |
|---|---|---|
| បាទ / ចាស | 28.3%<br>566 | 28.5%<br>425 |
| ទេ | 70.5%<br>1408 | 68.9%<br>1029 |
| គ្មានចំលើយ | 1.2%<br>24 | 2.6%<br>39 |

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|

52- ការសូកបាន់គឺជាមធ្យោបាយដ៏សាមញ្ញទៅហើយ ដើម្បីអោយគេធ្វើអ្វីមួយនៅក្នុងប្រទេសកម្ពុជា ។

| | | |
|---|---|---|
| ពិត | 57.5%<br>1149 | 60.3%<br>900 |
| មិនពិត | 40.6%<br>812 | 36.9%<br>551 |
| គ្មានចំលើយ | 1.9%<br>37 | 2.8%<br>42 |

53- អ្នកម៉ៅការ ត្រូវចំណាយ កំរៃជើងសារ (កុំមុយស្យុង) ដើម្បីបានកុងត្រាមកធ្វើ ។

| | | |
|---|---|---|
| ពិត | 50.4%<br>1006 | 69%<br>1030 |
| មិនពិត | 47.6%<br>951 | 28.5%<br>425 |
| គ្មានចំលើយ | 2.1%<br>41 | 2.5%<br>38 |

54- ជាការត្រឹមត្រូវហើយចំពោះមន្ត្រីរាជការដែលមានប្រាក់ខែតិច បានទទួលប្រាក់កំរៃជើងសារ ។

| | | |
|---|---|---|
| បាទ / ចាស | 52.7%<br>1052 | 63.4%<br>947 |
| ទេ | 45.8%<br>916 | 33%<br>993 |
| គ្មានចំលើយ | 1.5%<br>30 | 3.5%<br>53 |

55- ប្រព័ន្ធហិរញ្ញវត្ថុបច្ចុប្បន្នរបស់កម្មវិធីសិលាមានន័យថា មនុស្សដែលចង់លួចថវិកា ពីគំរោង នឹងត្រូវចាប់ខ្លួន ។

| | | |
|---|---|---|
| ពិត | 70.9%<br>1416 | 78%<br>1164 |
| មិនពិត | 27.7%<br>553 | 19.3%<br>288 |
| គ្មានចំលើយ | 1.5%<br>29 | 2.7%<br>41 |

56- តើការជ្រើសរើសយកនរណាម្នាក់ សំរាប់ម៉ៅការ ដោយសារពួកគេមានទំនាក់ទំនងជាមួយមន្ត្រីមានអំណាច តើអាចទទួលយកបានដែររឺទេ ?

| | | |
|---|---|---|
| បាទ / ចាស | 18.3%<br>365 | 18.6%<br>277 |
| ទេ | 80.8%<br>1614 | 79%<br>1180 |

| **លេខសំនួរ** | **2004**<br>ចំនួនអ្នកឆ្លើយ 1998 | **2001**<br>ចំនួនអ្នកឆ្លើយ 1493 |
| --- | --- | --- |
| គ្មានចំលើយ | 1%<br>19 | 2.4%<br>36 |

57- កិច្ចសន្យាការងារដែលត្រូវទទួលរ៉ាប់រងនៅតាមឃុំ/សង្កាត់ គួរតែត្រូវបាន :

| | | |
| --- | --- | --- |
| ប្រគល់ទៅអោយអ្នកម៉ៅការដែលល្អបំផុតនៅក្នុងតំបន់ ។ | 59.3%<br>1185 | 67.1%<br>1002 |
| ផ្សព្វផ្សាយតាមប្រព័ន្ធឃោសនា ។ | 50.9%<br>1017 | 68.8%<br>1027 |
| ប្រគល់ទៅអោយអ្នកទុកចិត្ត ដែលអាច ទទួលខុសត្រូវលើការងារនេះបាន ។ | 49.4%<br>988 | 62.5%<br>933 |
| ផ្សព្វផ្សាយលើក្ដារប្រកាសពត៌មាន នៅតាមការិយាល័យរបស់រដ្ឋាភិបាល ។ | 48.6%<br>972 | 52.6%<br>786 |
| ប្រគល់ទៅអោយអ្នកម៉ៅការដែលត្រូវការការងារធ្វើ ។ | 16.7%<br>333 | 28.4%<br>424 |
| ប្រគល់ទៅអោយអ្នកម៉ៅការ ដែលត្រូវបានសំរេចជ្រើសរើសដោយមានការឯកភាព ។ | 60.9%<br>1217 | 63.8%<br>953 |
| ប្រគល់ជូនដោយការយកតំលៃទាប ប៉ុន្តែផ្ដល់គុណភាពជាក់លាក់ ។ | 69.8%<br>1395 | 70%<br>1045 |
| គ្មានចំលើយ | 0.5%<br>9 | 2.3%<br>35 |

## ជំនឿ

នៅក្នុងចំណោមអ្នកផ្ដល់ពត៌មានទាំងអស់ ហាក់ដូចជាមានជំនឿយ៉ាងមុតមាំថា រដ្ឋាភិបាលកំពុងធ្វើការងារបច្ចុប្បន្ន ដើម្បីជាប្រយោជន៍របស់ប្រជាពលរដ្ឋរបស់ខ្លួន (តារាង៥០) នៅឆ្នាំ ២០០១ អ្នកផ្ដល់ពត៌មាន ៨៤% បានគិតដូច្នេះមែន ហើយនៅឆ្នាំ ២០០៤ នេះ អ្នកផ្ដល់ពត៌មាន ៨៧% បានគិតដូច្នេះដែរ ។ មានទស្សនៈយ៉ាងមុតមាំផងដែរថា រដ្ឋាភិបាលមូលដ្ឋានដែលជ្រើសរើសដោយការបោះឆ្នោតប្រជាធិបតេយ្យ និងពង្រឹងការអភិវឌ្ឍន៍មូលដ្ឋានបានប្រសើរជាងមន្ត្រីតែងតាំង (តារាង៥១) ។ នៅឆ្នាំ ២០០១ អ្នកផ្ដល់ពត៌មាន ៩៣% បានគិតដូច្នោះ ហើយនៅឆ្នាំ ២០០៤ អ្នកផ្ដល់ពត៌មាន ៩៧% បានគិតដូច្នោះដែរ ។ មន្ត្រីកាន់តែមានជំនឿផងដែរថា គួរតែមានតំលៃកំណត់សំរាប់សេវាទាំងអស់របស់រដ្ឋាភិបាល (តារាង៥២) ។ នៅឆ្នាំ ២០០១ អ្នកផ្ដល់ពត៌មាន ៨៥% បានគិតថា គួរតែមានតំលៃកំណត់សំរាប់សេវាទាំងអស់របស់រដ្ឋាភិបាល ហើយនៅឆ្នាំ ២០០៤ អ្នកផ្ដល់ពត៌មានជិត ៨៨% បានគិតដូច្នោះដែរ ។ មន្ត្រីកាន់តែមានជំនឿផងដែរថា មានការទទួលខុសត្រូវចំពោះមូលនិធិឃុំសង្កាត់ប្រសើរជាងមុន តាំងពីបោះឆ្នោតឆ្នាំ ២០០២ មក (តារាង៥៣) ។ នៅឆ្នាំ ២០០១ អ្នកផ្ដល់ពត៌មាន ៨៩% បានគិតដូច្នោះ ហើយនៅឆ្នាំ ២០០៤ អ្នកផ្ដល់ពត៌មាន ៩១% បានគិតដូច្នោះដែរ ។ មានទស្សនៈមួយទៀត ដែលនិយាយថា ការធ្វើផែនការនៅប្រទេសកម្ពុជា គឺ

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|

បង្ហាញអោយឃើញតំរូវការរបស់ស្ត្រី និងជនងាយរងគ្រោះបំផុតនៅក្នុងភូមិ (តារាង៥៥) នៅឆ្នាំ ២០០១ អ្នកផ្តល់ពត៌មាន ៨៥% បានឯកភាពចំពោះចំលើយនោះ ហើយនៅឆ្នាំ ២០០៤ ៩០% បានឯកភាពដូច្នោះដែរ ។ ទោះជាយ៉ាងណាក៏ដោយមានជំរើសមួយ ក្នុងការឆ្លើយនូវសំនួរដែលសួរថា តើមានស្ត្រីគ្រប់គ្រាន់នៅក្នុងតួនាទីសំរេចគោលនយោបាយនៅក្នុងប្រទេសកម្ពុជាដែររឺទេ (តារាង៥៦) ។ នៅឆ្នាំ ២០០១ អ្នកផ្តល់ពត៌មាន ៥៨% បានគិតថា គ្មានស្ត្រីគ្រប់គ្រាន់នៅក្នុងតួនាទីសំរេចគោលនយោបាយនៅក្នុងប្រទេសកម្ពុជាទេ ហើយនៅឆ្នាំ ២០០៤ អ្នកផ្តល់ពត៌មាន ៧៩% បានគិតដូច្នោះដែរ ។

មានលក្ខណៈខុសគ្នាច្រើនផងដែរ នៅក្នុងទស្សនៈឆ្នាំ ២០០១ និងឆ្នាំ ២០០៤ អំពីតួនាទីរបស់រដ្ឋាភិបាលនៅក្នុងផ្នែកសេដ្ឋកិច្ច និងសន្តិសុខ ។ តារាង ៥៧ ខាងក្រោម អ្នកផ្តល់ពត៌មានត្រូវបានសួរថា តើរដ្ឋាភិបាលកំពុងធ្វើកិច្ចការគ្រប់គ្រាន់ ដើម្បីពង្រឹងសេដ្ឋកិច្ចដែររឺទេ ក្នុងឆ្នាំ ២០០១ ២៤% បាននិយាយថា រដ្ឋាភិបាលកំពុងធ្វើការគ្រប់គ្រាន់ដើម្បីពង្រឹងសេដ្ឋកិច្ច ហើយនៅឆ្នាំ ២០០៤ ប្រហែល ៦៦% បានគិតដូច្នោះដែរ ។ ចំពោះសំនួរសួរថា តើមន្ត្រីកំពុងធ្វើការគ្រប់គ្រាន់ ដើម្បីជួយសំរួលដល់អាជីវកម្មខ្នាតតូចដែររឺទេ (តារាង ៥៨) នៅឆ្នាំ ២០០១ ២២% បាននិយាយថា មន្ត្រីកំពុងតែធ្វើកិច្ចការគ្រប់គ្រាន់ ដើម្បីជួយសំរួលដល់អាជីវកម្មខ្នាតតូច ហើយនៅឆ្នាំ ២០០៤ ៥៦% បានគិតដូច្នោះដែរ ទាក់ទងបញ្ហាសន្តិសុខ តារាង ៥៩% សួរថា តើប្រជាពលរដ្ឋត្រូវបានគេអនុញ្ញាតអោយបញ្ចេញទស្សនៈរបស់ពួកគេជាសាធារណៈដែររឺទេ ទោះបីពួកគេបញ្ចេញទស្សនៈរិះគន់រដ្ឋាភិបាលក៏ដោយនោះ នៅឆ្នាំ ២០០១ ២៩% បានគិតដូច្នោះ ប៉ុន្តែនៅឆ្នាំ ២០០៤ ៨៥% ក៏បានគិតដូច្នោះដែរ ។ តារាង ៦០ ខាងក្រោម អ្នកផ្តល់ពត៌មានក៏បានសួរថាតើរដ្ឋាភិបាលអាចធ្វើបន្ថែមទៀត ដើម្បីអោយប្រជាពលរដ្ឋមានសុវត្ថិភាព និងសន្តិសុខដែររឺទេ នៅឆ្នាំ ២០០១ មន្ត្រី ៣៣% បាននិយាយថា ពួកគេគិតថា រដ្ឋាភិបាលអាចធ្វើបន្ថែមទៀត ដើម្បីអោយប្រជាពលរដ្ឋមានសុវត្ថិភាព និងសន្តិសុខ ហើយនៅឆ្នាំ ២០០៤ ៨៨% ក៏បានគិតដូច្នោះដែរ ។

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|

**58- តើលោក លោកស្រី ជឿថារដ្ឋាភិបាលកំពុងធ្វើការងារ ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋគ្រប់រូបដែររឺទេ ??**

| | | |
|---|---|---|
| បាទ / ចាស | 87.2%<br>1743 | 84.1%<br>1255 |
| ទេ | 12%<br>239 | 12.7%<br>190 |
| គ្មានចំលើយ | 0.8%<br>16 | 3.2%<br>48 |

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|

59- តើលោក លោកស្រីជឿថា មន្ត្រីណាមួយ ដែលបានបញ្ជាក់ដូចខាងក្រោមនេះ នឹងលើកកំពស់ការអភិវឌ្ឍន៍មូលដ្ឋានបានប្រសើរជាងមុន ?

| | | |
|---|---|---|
| បាទ / ចាស | 96.5%<br>1928 | 92.6%<br>1383 |
| ទេ | 2.5%<br>49 | 3.3%<br>50 |
| គ្មានចំលើយ | 1.1%<br>21 | 4%<br>60 |

60- តើលោក លោកស្រី ជឿថា គួរតែមានតំណែកំណត់ជាក់លាក់ សំរាប់សេវារបស់រដ្ឋាភិបាលដែរឬទេ ?

| | | |
|---|---|---|
| មន្ត្រីមូលដ្ឋាន ដែលជ្រើសរើសតាមរយៈ ការបោះឆ្នោតប្រជាធិបតេយ្យ ។ | 87.9%<br>1756 | 84.9%<br>1267 |
| មន្ត្រីដែលតែងតាំង ។ | 10.9%<br>217 | 11.5%<br>172 |
| គ្មានចំលើយ | 1.3%<br>25 | 3.6%<br>54 |

61- តើលោក លោកស្រីជឿថា មានការទទួលខុសត្រូវខ្លាំងជាងមុន ទៅលើថវិកាតាំងពីការបោះឆ្នោតឃុំ/សង្កាត់ នៅឆ្នាំ ២០០២ ។

| | | |
|---|---|---|
| បាទ / ចាស | 91.4%<br>1827 | 88.9%<br>1327 |
| ទេ | 7.6%<br>152 | 7.8%<br>117 |
| គ្មានចំលើយ | 1%<br>19 | 3.3%<br>49 |

62 -តើលោក លោកស្រីជឿថា ការបោះឆ្នោតក្រុមប្រឹក្សាឃុំ បានបង្កើននូវកំរិតនៃការចូលរួមរបស់ អ្នកភូមិក្នុងកិច្ចអភិវឌ្ឍន៍ដែរឬទេ ?

| | | |
|---|---|---|
| បាទ / ចាស | 95.7%<br>1913 | 94.6%<br>1413 |
| ទេ | 3.5%<br>70 | 2.2%<br>33 |
| គ្មានចំលើយ | 0.8%<br>15 | 3.1%<br>47 |

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|

63- តើលោក លោកស្រីជឿថា ការរៀបចំផែនការនៅក្នុងប្រទេសកម្ពុជា របស់លោក លោកស្រីបង្ហាញនូវតំរូវការរបស់ស្ត្រី និងអ្នកទន់ខ្សោយបំផុតនៅក្នុងភូមិដែររឺទេ ?

| | | |
|---|---|---|
| បាទ / ចាស | 88.9%<br>1776 | 85.4%<br>1275 |
| ទេ | 10.4%<br>207 | 11.3%<br>168 |
| គ្មានចំលើយ | 0.8%<br>15 | 3.3%<br>50 |

64- តើលោក លោកស្រី គិតថាមានចំនួនស្ត្រីគ្រប់គ្រាន់ដែររឺទេ នៅក្នុងមុខតំណែងនៃការ បង្កើតគោលនយោបាយនៅក្នុងប្រទេសកម្ពុជា ?

| | | |
|---|---|---|
| បាទ / ចាស | 20.3%<br>405 | 38.2%<br>570 |
| ទេ | 79.2%<br>1582 | 58.2%<br>869 |
| គ្មានចំលើយ | 0.6%<br>11 | 3.6%<br>54 |

65- តើរដ្ឋាភិបាលកំពុងធ្វើការងារគ្រប់គ្រាន់ ដើម្បីធ្វើអោយសេដ្ឋកិច្ចមានភាពរឹងមាំដែររឺទេ ?

| | | |
|---|---|---|
| បាទ / ចាស | 66.3%<br>1325 | 24.4%<br>365 |
| ទេ | 32.5%<br>649 | 10.4%<br>155 |
| គ្មានចំលើយ | 1.2%<br>24 | 2%<br>30 |

66- តើមន្ត្រីរាជការកំពុងធ្វើការងារគ្រប់គ្រាន់ ដើម្បីជួយសំរួលដល់ប្រជាពលរដ្ឋដែល ធ្វើមុខជំនួញខ្នាតតូចដែររឺទេ ?

| | | |
|---|---|---|
| បាទ / ចាស | 56.4%<br>1127 | 22.4%<br>335 |
| ទេ | 42.4%<br>847 | 12%<br>179 |
| គ្មានចំលើយ | 1.2%<br>24 | 65.6%<br>979 |

| លេខសំនួរ | 2004<br>ចំនួនអ្នកឆ្លើយ 1998 | 2001<br>ចំនួនអ្នកឆ្លើយ 1493 |
|---|---|---|

67- តើប្រជាពលរដ្ឋត្រូវបានអនុញ្ញាតិ អោយបញ្ចេញមតិ-យោបល់របស់ខ្លួនជាសាធារណៈដែររឺទេ?
ទោះបីពួកគេបញ្ចេញមតិ-យោបល់ រិះគន់រដ្ឋាភិបាលក៏ដោយ ។

| | | |
|---|---|---|
| បាទ / ចាស | 85.3%<br>1704 | 29.3%<br>438 |
| ទេ | 13.9%<br>278 | 5.5%<br>82 |
| គ្មានចំលើយ | 0.8%<br>16 | 65.2%<br>973 |

68- តើរដ្ឋាភិបាលអាចធ្វើអ្វីបន្ថែមទៀត ដើម្បីអោយប្រជាពលរដ្ឋទាំងអស់មានអារម្មណ៍ថា ខ្លួនគេមានសុវត្ថិភាព និងសន្តិសុខ ដែររឺទេ ?

| | | |
|---|---|---|
| បាទ / ចាស | 87.7%<br>1753 | 33%<br>492 |
| ទេ | 11.7%<br>233 | 1.9%<br>29 |
| គ្មានចំលើយ | 0.6%<br>12 | 65.1%<br>972 |

## ង- ការប្រៀបធៀបលទ្ធផលនៅក្នុងខេត្តផ្សេងគ្នា ចំនួន ៧ នៅឆ្នាំ ២០០៤

| លេខសំណួរ | បាត់ដំបង<br>ចំនួនអ្នកឆ្លើយ<br>271 | ពោធិ៍សាត់<br>ចំនួនអ្នកឆ្លើយ<br>262 | តាកែវ<br>ចំនួនអ្នកឆ្លើយ<br>425 | កំពង់ចាម<br>ចំនួនអ្នកឆ្លើយ<br>348 | កំពង់ស្ពឺ<br>ចំនួនអ្នកឆ្លើយ<br>294 | កំពង់ឆ្នាំង<br>ចំនួនអ្នកឆ្លើយ<br>335 | ភ្នំពេញ<br>ចំនួនអ្នកឆ្លើយ<br>63 | សរុប<br>ចំនួនអ្នកឆ្លើយ<br>1998 |
|---|---|---|---|---|---|---|---|---|
| **9-ភេទ** | | | | | | | | |
| ប្រុស | 83%<br>225 | 86.3%<br>226 | 86.6%<br>368 | 78.4%<br>273 | 86.7%<br>255 | 80.9%<br>271 | 90.5%<br>57 | 83.8%<br>1675 |
| ស្រី | 17%<br>46 | 13.7%<br>36 | 13.4%<br>57 | 21.6%<br>75 | 13.3%<br>39 | 19.1%<br>64 | 9.5%<br>6 | 16.2%<br>323 |
| **10-អាយុ** | | | | | | | | |
| 18-24 | 8.1%<br>22 | 5.3%<br>14 | 9.2%<br>39 | 5.7%<br>20 | 2.4%<br>7 | 3%<br>10 | 9.5%<br>6 | 5.9%<br>118 |
| 25-34 | 9.2%<br>25 | 2.7%<br>7 | 8.5%<br>36 | 8%<br>28 | 11.2%<br>33 | 12.8%<br>43 | 39.7%<br>25 | 9.9%<br>197 |
| 35-44 | 16.2%<br>44 | 18.3%<br>48 | 15.3%<br>65 | 20.4%<br>71 | 18%<br>53 | 17.6%<br>59 | 15.9%<br>10 | 17.5%<br>350 |
| 45-54 | 35.1%<br>95 | 42.4%<br>111 | 33.6%<br>143 | 39.9%<br>139 | 36.7%<br>108 | 40%<br>134 | 27%<br>17 | 37.4%<br>747 |
| 55-64 | 25.5%<br>69 | 21.8%<br>57 | 26.6%<br>113 | 22.4%<br>78 | 27.2%<br>80 | 23.3%<br>78 | 7.9%<br>5 | 24%<br>480 |
| >65 | 5.9%<br>16 | 9.5%<br>25 | 5.4%<br>23 | 3.4%<br>12 | 4.4%<br>13 | 3.3%<br>11 | 0%<br>0 | 5%<br>100 |
| គ្មានចំលើយ | 0%<br>0 | 0%<br>0 | 1.4%<br>6 | 0%<br>0 | 0%<br>0 | 0%<br>0 | 0%<br>0 | 0.3%<br>6 |
| **11- កំរិតវប្បធម៌** | | | | | | | | |
| បឋមសិក្សា | 30.6%<br>83 | 41.6%<br>109 | 34.1%<br>145 | 41.1%<br>143 | 47.3%<br>139 | 40.9%<br>137 | 1.6%<br>1 | 37.9%<br>757 |
| អនុវិទ្យាល័យ | 26.2%<br>71 | 29%<br>76 | 29.6%<br>126 | 25%<br>87 | 26.9%<br>79 | 24.8%<br>83 | 6.3%<br>4 | 26.3%<br>526 |
